**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et de Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការប្ដឹងតវ៉ាក្នុងរឿងក្ដីព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហួ ឆាង**

**ខុង ជិយោវ៉ារ៉ា**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទ **ហួ ឆាង** និងខ្ញុំបាទ **ខុង ឌីយ៉ោហ្វ៉ារ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្ដែងនូវកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកឪពុក អ្នកម្ដាយ ដែលបានផ្ដល់កំណើតចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា ផ្ដល់នូវសេចក្ដីស្រឡាញ់ប្រកបដោយព្រហ្មវិហារធម៌អប់រំទូន្មានប្រៀនប្រដៅឲ្យកូន ប្រព្រឹត្តតែអំពើល្អទៅតាមគន្លងធម៌គ្រប់បែបយ៉ាង និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ទាំងស្មារតី និងថវិកាឲ្យកូនបានសិក្សារៀនសូត្ររហូតដល់បច្ចុប្បន្ននេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្ដម **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យយើងខ្ញុំបានចូលសិក្សារនៅសាកលវិទ្យាល័យនេះ និងបង្ករលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។ ជាពិសេសសូមថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ **ឌួន ម៉ុនធី** ជាសាស្ត្រាចារ្យណែនាំ ដែលបានឆ្លៀតឱកាសដ៏មានតម្លៃនិងដ៏មមាញឹកកក្នុងការបង្ហាត់បង្រៀនផ្ដល់ការណែនាំ ថែមទាំងបានផ្ដល់ឯកសារមួយចំនួនដល់យើងខ្ញុំ ដើម្បីរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះឡើង។ ព្រមទាំងថ្នាក់ដឹកនាំ បុគ្គលិកសិក្សា នៅសាកលវិទ្យល័យភូមិនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលបានបង្ករលក្ខណៈងាយស្រួល ដល់ការសិក្សារបស់យើងខ្ញុំ។

ជាចុងក្រោយ យើងខ្ញុំសូមជូនពរដល់ លោកឪពុក អ្នកម្ដាយ លោកឯកឧត្ដម លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ សូមឲ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

អត្ថបទសារណាបញ្ចប់ការសិក្សាដែលបានធ្វើការស្រាវជ្រាវក្រោមប្រធានបទស្តីពី: **"នីតិវិធីនៃការចុះឈ្មោះអាពាហ៍ពិពាហ៍ក្នុងរឿងក្តីព្រហ្មទណ្ឌ"** មួយនេះដែលស្ថិតក្នុងដៃមិត្តអ្នកអាន ក៏ដូចលោក លោកស្រី សាស្ត្រាចារ្យ ដែលកំពុងតែពិនិត្យមើលលើខ្លឹមសារនៃអត្ថបទក្នុងពេលនេះ យើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គង និងការខ្វះខាតដែលកើតមានឡើង ដោយហេតុថាយើងខ្ញុំទាំងអស់គ្នាពុំមានចំណេះដឹង ក៏ដូចជាបទពិសោធការងារជាក់ស្តែងនៅមានកម្រិត។

ការសរសេរសារណានេះ គឺជាការសរសេរដកស្រង់ និងយោងតាមអត្ថបទច្បាប់ដែលកំពង់នៅជាធរមាន បញ្ចូលនូវគំនិតដែលបានមកពីការសិក្សារៀនសូត្រកន្លងមក និងសង្កេតមើលការអនុវត្តជាក់ស្តែងនាពេលកន្លងមកតែប៉ុណ្ណោះ។

ម្យ៉ាងវិញទៀតការសរសេរអត្ថបទនេះឡើង យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា នឹងអាចចូលរួមជាវិភាគទានដល់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវ ដែលបាននឹងកំពុងជួបប្រទះនូវកង្វះខាតនាពេលបច្ចុប្បន្ននេះ ហើយក៏ជាឯកសារស្រាវជ្រាវបែបវិទ្យាសាស្ត្រមួយថ្មីថែមទៀត ដែលបំពេញសេចក្តីត្រូវការដល់អ្នកសិក្សាជំនាន់ក្រោយ។

បើទោះបីជាសារណាមួយនេះកើតចេញពីការខិតខំព្យាយាម យ៉ាងយកចិត្តទុកដាក់យ៉ាងណាក៏ដោយក៏អាចនៅមានកំហុសដោយអចេតនាណាមួយ ដែលអាចមានការខ្វះចន្លោះ នៅផ្នែកណាមួយជាពុំខាន។ ហេតុនេះយើងខ្ញុំសុំទទួលការរិះគន់ទាំងឡាយណា ក្នុងន័យជួយស្ថាបនានូវការស្រាវជ្រាវមួយនេះ ឲ្យកាន់តែប្រសើរឡើងបន្ថែមទៀតដោយសេចក្តីសោមនស្សរីករាយ។ ហើយក៏សុំអភ័យទោសជាមុននូវរាល់កំហុសដែលកើតមានឡើងទាំងផ្នែកបច្ចេកទេស និងខ្លឹមសារមួយចំនួននៃអត្ថបទនេះផងដែរ។

ជាចុងបញ្ចប់យើងខ្ញុំសូមជូនពរមិត្តអ្នកអាន និង លោកសាស្ត្រាចារ្យជួបប្រទះតែសេចក្តីសុខ និងមានសុភាពល្អ ដើម្បីជួយលើកស្ទួយនូវការសិក្សាយល់ដឹងដល់កូនខ្មែរជំនាន់ក្រោយឲ្យទទួលបាននូវចំណេះដឹងប្រកបដោយប្រសិទ្ធិភាព និងភាពកាន់តែប្រសើរឡើងមួយកំរិតទៀតជាក់ជាមិនខាន។

# មាតិកា

ទំព័រ


សេចក្តីផ្តើម ........ ១

ជំពូកទី ១ ការប្តឹងតវ៉ាចំពោះកិច្ចនីតិវិធី ........ ៥

ផ្នែកទី ១ ៖ ការប្តឹងតវ៉ាចំពោះចំណាត់ការរបស់អយ្យការ ........ ៥

កថាខណ្ឌទី ១ ៖ ការប្តឹងតវ៉ាចំពោះការតម្កល់រឿងទុកឥតចាត់ការ ........ ៥

ក. សញ្ញាណទូទៅ ........ ៥

ខ. រយៈពេលនៃការប្តឹងតវ៉ា ........ ៥

កថាភាគទី ២ ៖ អានុភាពនៃការប្តឹងតវ៉ាចំពោះការតម្កល់រឿងទុកឥតចាត់ការ ........ ៦

ផ្នែកទី ២ ៖ ការប្តឹងតវ៉ានៅដំណាក់កាលចៅក្រមស៊ើបសួរ ........ ៦

កថាខណ្ឌទី ១ ៖ ការប្តឹងតវ៉ាពីអនីយ័តភាពនៃកិច្ចនីតិវិធី ........ ៧

ក. សញ្ញាណទូទៅ ........ ៧

ខ. នីតិវិធីនៃការស្នើសុំមោឃភាព ........ ៨

កថាខណ្ឌទី ២ ៖ បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ........ ១២

ក. និយមន័យ ........ ១២

ខ. សិទ្ធិប្តឹងឧទ្ធរណ៍ ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ........ ១៣

គ. រយៈពេលប្តឹងឧទ្ធរណ៍ ........ ១៦

ឃ.ទម្រង់នៃការប្រកាសប្តឹងឧទ្ធរណ៍ ........ ១៧

ង. អានុភាពនៃបណ្តឹងឧទ្ធរណ៍ ........ ១៨

ជំពូកទី ២ ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់សាលាដម្រះក្តីជាន់ទាប ........ ២០

ផ្នែកទី ១ ៖ សញ្ញាណទូទៅ ........ ២០

កថាខណ្ឌទី ១ ៖ ប្រភេទសាលក្រម ........ ២១

ក. សាលក្រមចំពោះមុខ ........ ២១

ខ. សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ ........ ២២

គ. សាលក្រមកំបាំងមុខ ........ ២២
ផ្នែកទី ២ ៖ ការប្តឹងតវ៉ាចំពោះសាលក្រមរបស់សាលាដំបូងរាជធានី-ខេត្ត ........ ២៣
កថាខណ្ឌទី ១ ៖ បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ........ ២៣
ក. បុគ្គលដែលមានសិទ្ធិធ្វើបណ្តឹងទាស់ ........ ២៣
ខ. រយៈពេលធ្វើបណ្តឹងទាស់ ........ ២៤
គ. ទម្រង់ និងភាពដែលអាចទទួលយកបាននៃបណ្តឹងទាស់ ........ ២៥
ឃ. អានុភាពនៃបណ្តឹងទាស់ ........ ២៦
កថាខណ្ឌទី ១ ៖ បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម ........ ២៦
ក.បុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម ........ ២៧
ខ. រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម ........ ២៧
គ. ទម្រង់នៃការប្រកាសប្តឹងឧទ្ធរណ៍ចំពោះសាលក្រម ........ ២៨
ឃ. អានុភាពនៃបណ្តឹងឧទ្ធរណ៍ ........ ៣០
ជំពូកទី ៣ ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់សាលាជម្រះក្តីជាន់ខ្ពស់ ........ ៣១
ផ្នែកទី ១ ៖ ការប្តឹងតវ៉ាចំពោះសាលដីកាសាលាឧទ្ធរណ៍ ........ ៣១
កថាខណ្ឌទី ១ ៖ បណ្តឹងទាស់ចំពោះសាលដីកាចេញដោយកំបាំងមុខ ........ ៣១
ក.បុគ្គលដែលអាចធ្វើបណ្តឹងទាស់ ........ ៣១
ខ. រយៈពេលធ្វើបណ្តឹងទាស់ ........ ៣១
គ. ទម្រង់ និងភាពដែលអាចទទួលយកបាននៃបណ្តឹងទាស់ ........ ៣២
ឃ. អានុភាពនៃបណ្តឹងទាស់ ........ ៣២
កថាខណ្ឌទី ១ ៖ បណ្តឹងសាទុក្ខ ........ ៣៣
ក.បុគ្គលដែលអាចធ្វើបណ្តឹងសាទុក្ខ ........ ៣៤
ខ.មូលហេតុនៃបណ្តឹងសាទុក្ខ ........ ៣៤
គ.រយៈពេលធ្វើបណ្តឹងសាទុក្ខ ........ ៣៥
ឃ.ទម្រង់នៃការប្រកាសបណ្តឹងសាទុក្ខ ........ ៣៥

ខ.អានុភាពនៃបណ្ដឹងសាទុក្ខ.....................................................................................................៣៦
ផ្នែកទី ២ ៖ បណ្ដឹងសើរើរឿងក្ដីព្រហ្មទណ្ឌ....................................................................................៣៧
កថាខណ្ឌទី ១ ៖ សញ្ញាណទូទៅនៃបណ្ដឹងសើរើ.................................................................................៣៧
ក-និយមន័យ..............................................................................................................................៣៨
ខ-បុគ្គលដែលអាចប្ដឹងសើរើរឿងក្ដីជាសិទ្ធិរបស់..............................................................................៣៨
គ-មូលហេតុនៃការប្ដឹងសើរើ..........................................................................................................៣៩
កថាខណ្ឌទី ២ ៖ គោលការណ៍ទូទៅនៃបណ្ដឹងសើរើ...........................................................................៣៩
ក-ការដាក់ពាក្យបណ្ដឹងសើរើ.........................................................................................................៤០
ខ-អានុភាពនៃបណ្ដឹងសើរើ............................................................................................................៤០
គ-ការបញ្ជូនសំណុំរឿងទៅតុលាការកំពូល.......................................................................................៤០
ឃ-ការជំនុំជម្រះនៃសំណុំរឿងសើរើ..................................................................................................៤១
ង-សារប្រយោជន៍នៃបណ្ដឹងសើរើ....................................................................................................៤២
ច-សិទ្ធិទទួលបានជំនួយផ្នែកច្បាប់....................................................................................................៤៣
សេចក្ដីសន្និដ្ឋាន...........................................................................................................................៤៤
អនុសាសន៍...................................................................................................................................៤៦
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាន៦១២មាត្រា ក្រមនេះត្រូវអនុវត្តភ្លាម ចំពោះគ្រប់កិច្ចនីតិវិធីក្រោយក្រមនេះចូលជាធរមាន។ ការអនុវត្តភ្លាមនូវបទប្បញ្ញត្តិនៃក្រមនេះ ពុំមានអានុភាពលើសុពលភាពនៃកិច្ចនីតិវិធីទាំងឡាយដែលត្រូវបានបំពេញរួចរាល់ហើយ ដោយអនុលោមតាមច្បាប់ចាស់ឡើយ។

"នីតិវិធីព្រហ្មទណ្ឌសំដៅដោយផ្ទាល់ដល់រឿងក្តីព្រហ្មទណ្ឌ ពោលគឺរបៀបរៀបចំដំណើរនៃការប្រព្រឹត្ត ឬប្រតិបត្តិរបស់សង្គមមនុស្សតបទៅនឹងអំពើ ភាពរឹករវ សកម្មភាពដែលច្បាប់បញ្ញត្តិថាជាបទល្មើស។ នីតិវិធីព្រហ្មទណ្ឌ វាមិនមែនគ្រាន់តែជាផ្នែកមួយនៃដំណើរការនីតិវិធីរបស់តុលាការ ឬសាលាជំនុំជម្រះក្តីតែមួយមុខនោះទេ ប៉ុន្តែវាជាបណ្តុំនៃវិធានដែលកំណត់នូវ សិទ្ធិ កាតព្វកិច្ចរបស់បុគ្គល ឬភាគីដែលបានចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងដំណើរការរបស់សាលាជំនុំជម្រះក្តី និងសកម្មភាពរបស់តុលាការព្រហ្មទណ្ឌ ចាប់តាំងពីពេលដែលមានការសង្ស័យថាជាបទល្មើសកើតឡើង រហូតដល់ពេលដែលចារី សហចារី អ្នកសមគំនិត អ្នកផ្តើមគំនិត នៃការប្រព្រឹត្តបទល្មើសដែលត្រូវបានកំណត់អត្តសញ្ញាណ ការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ ការជំនុំជម្រះ ផ្តន្ទាទោស និងការអនុវត្តទោស"[1]។ អាចនិយាយបានថា រឿងក្តីព្រហ្មទណ្ឌ គឺជាប្រតិកម្មតាមផ្លូវតុលាការរបស់សង្គម នៅពេលណាមានការរំលោភបំពានច្បាប់ សង្គមនឹងមានប្រតិកម្មមួយ ចាប់ពីពេលដែលបទល្មើសបានប្រព្រឹត្ត រហូតដល់ការដាក់ទណ្ឌកម្ម។

នៅប្រទេសកម្ពុជា គេសង្កេតឃើញថាមានច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌមុនឆ្នាំ ១៩៩២ ,នីតិវិធីព្រហ្មទណ្ឌនៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ,ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើដោយក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣ ច្បាប់ស្តីពីរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៨៩៩/០៩ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៩ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣៦,៣៨,៩០និង៩១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០២/០០៥ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ ដែលច្បាប់ទាំងអស់នេះត្រូវបាននិរាករណ៍ដោយក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើដោយព្រះក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧[2]។ ក្រៅពីនេះ គេសង្កេតឃើញមាន

[1] សៀវភៅនិតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ ខាន់ សុខា និង ឌី លីឡា

[2] មាត្រា៦១១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ច្បាប់ពិសេសជាច្រើនទៀតដែលបំពេញបន្ថែម សម្រាប់បទល្មើសពិសេសមួយចំនួន ដូចជាច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ព្រៃឈើ ច្បាប់ស្តីពីការត្រួតពិនិត្យអាវុធជាតិផ្ទុះ ។ល។ បន្ថែមពីលើច្បាប់ គេឃើញមានសារាចរ សេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ និងសេចក្តីណែនាំរបស់តុលាការកំពូល ដើម្បីជម្រុញឱ្យការអនុវត្តនីតិវិធីកាន់តែមានប្រសិទ្ធភាពក្នុងកាលៈទេសៈបច្ចុប្បន្នដែលច្បាប់ជាធរមាន នៅមានការខ្វះខាតត្រង់ចំណុចខ្លះនៅឡើយ។

ក្នុងរឿងក្តីព្រហ្មទណ្ឌ បណ្តឹងដែលអាចកើតមានឡើង មានពីរប្រភេទដែលមានកំណត់យ៉ាងច្បាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងពីរផ្សេងគ្នា។ បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។ ចំពោះបណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឲ្យបានជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល[3]។

ក្នុងរឿងក្តីព្រហ្មទណ្ឌ ចំពោះនីតិវិធី គឺមានលក្ខណៈវែងអន្លាយហើយមានលក្ខណៈស្មុគស្មាញ ដែលជាទូទៅដំណើរការនីតិវិធីព្រហ្មទណ្ឌ ពីដំណាក់កាលមួយទៅដំណាក់កាលមួយត្រូវតែអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ នៅពេលមានបទល្មើសកើតឡើង ឬក៏បានដឹងថាមានបទល្មើសកើតឡើង នីតិវិធីត្រូវចាប់ផ្តើមពីការស៊ើបអង្កេត (ស៊ើងអង្កេតជាក់ស្តែង និងស៊ើបអង្កេតបឋម) ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌។ បន្ទាប់ពីការស៊ើបអង្កេត ឈានចូលដល់ការចោទរបស់ព្រះរាជអាជ្ញា ដែលការចោទប្រកាន់អាចធ្វើតាម **ការបើកការស៊ើបសួរ** (ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ), **ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**, **ការបង្ហាញខ្លួនភ្លាម**។ បន្ទាប់មកឈានដល់ដំណាក់កាលការស៊ើបសួរ ដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឲ្យឃើញការពិតដោយអនុលោមតាមច្បាប់។ ចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក។ នៅពេលដែលចៅក្រមស៊ើបសួរបិទការស៊ើបសួរ ដោយចេញដីកាដំណោះស្រាយ (ដីកាលើកលែងការចោទប្រកាន់ និងដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ)។

ជារួមនីតិវិធីព្រហ្មទណ្ឌ គឺជាសំណុំដែលគ្រប់គ្រងការរៀបចំនិងការប្រព្រឹត្តទៅ ការវិនិច្ឆ័យរបស់តុលាការ និងការរកយុត្តិធម៌ជូនប្រជាពលរដ្ឋ។ នីតវិធីព្រហ្មទណ្ឌមានគោលដៅកំណត់សមត្ថកិច្ច និងការប្រព្រឹត្តទៅរបស់យុត្តាធិការព្រហ្មទណ្ឌ ការពិនិត្យបទល្មើស (ការចោទប្រកាន់ជនល្មើស ការស្រាវជ្រាវជនល្មើស ការស្វែងរកភស្តុតាង នីតិវិធីនៃការជំនុំជម្រះក្តី ការបើកផ្លូវប្តឹងតវ៉ា ការសម្រេច

[3] មាត្រា២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សេចក្ដីរបស់យុត្តាធិការព្រហ្មទណ្ឌ បែបបទនៃការអនុវត្តទោស ជាដើម។ចំពោះគោលបំណងរបស់នីតិព្រហ្មទណ្ឌ គឺធានាប្រសិទ្ធិភាព ការបង្ក្រាប និងសិទ្ធិសេរីភាពដល់បុគ្គលពាក់ព័ន្ធផ្សេងៗ ។

**-ចំណោទបញ្ហានៃការស្រាវជ្រាវ:** ដោយសារការជម្រះក្ដី ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធីច្បាប់ជាធរមាន ហេតុដូច្នេះ មុខពេលជំនុំជម្រះក្ដី ក្នុងរឿងក្ដីព្រហ្មទណ្ឌ ៖

-តើមានការប្ដឹងតវ៉ាចំពោះចំណាត់ការលើកិច្ចនីតិវិធីណាមួយ(ដីកាសម្រេចរបស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបដែរ ឬទេ?)

-រីឯក្រោយពេលតុលាការព្រហ្មទណ្ឌចេញសេចក្ដីសម្រេច(សាលក្រម ឬសាលដីកា) តើបណ្ដឹងប្រឆាំងនឹងសាលក្រមសាលាដំបូង និងសាលដីកាសាលាឧទ្ធរណ៍ ត្រូវធ្វើឡើងយ៉ាងដូចម្ដេច?

-ហើយចំពោះសាលក្រមសាលាដំបូង សាលដីកាសាលាឧទ្ធរណ៍ និងសាលដីកាតុលាការកំពូលបានចូលជាស្ថាពរហើយមានអាជ្ញាអស់ជំនុំ តើអាចធ្វើការប្ដឹងសើរើយ៉ាងដូចម្ដេច?

**-គោលបំណងនៃការស្រាវជ្រាវ:** ការកំណត់យកប្រធានបទស្ដីពី "**នីតិវិធីនៃការប្ដឹងតវ៉ាក្នុងរឿងក្ដីព្រហ្មទណ្ឌ**" មកសរសេរនៅក្នុងសារណាបញ្ចប់ការសិក្សានេះ ក្នុងគោលបំណងចម្បងដើម្បីពិនិត្យលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន រួចធ្វើការសិក្សាលើការអនុវត្តជាក់ស្ដែងលើផ្លូវប្ដឹងតវ៉ាក្នុងដំណាក់មួយៗរបស់ភាគីពាក់ព័ន្ធ ក្នុងរឿងក្ដីព្រហ្មទណ្ឌ ហើយធ្វើការប្រៀបធៀបរកគុណសម្បត្តិ និងគុណវិបត្តិ ដើម្បីស្វែងរកដំណោះស្រាយបង្កើតគោលនយោបាយកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

**-អត្ថប្រយោជន៍ពាក់ព័ន្ធនឹងប្រធានបទ:** សារណាបញ្ចប់ការសិក្សានេះ មិនត្រឹមតែជាឯកសារសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយនោះទេ ប៉ុន្តែជាព័ត៌មានដ៏សំខាន់សម្រាប់ជូនដល់អ្នកពាក់ព័ន្ធក្នុងរឿងក្ដីព្រហ្មទណ្ឌ ចំពោះសិទ្ធិសេរីភាព និងកាតព្វកិច្ចមួយចំនួន ដែលអាចពិនិត្យលទ្ធភាពក្នុងការសិក្សាអំពីផលវិជ្ជមាន និងផលអវិជ្ជមាននៃការអនុវត្តច្បាប់ដែលមានស្រាប់ និងអាចច្បិចយកអនុសាសន៍ដែលផ្ដល់ជូនណាមួយ ជាប្រយោជន៍ដល់ការធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ដល់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរនាពេលអនាគត។

**-វិធីសាស្ត្រនៃការប្រមូលព័ត៌មាន:** ការស្រាវជ្រាវលើប្រធានបទនេះ គឺផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាន និងធ្វើការស្រាវជ្រាវបន្ថែមតាមរយៈប្រព័ន្ធអ៊ីនធ័រណេត (Internet) សៀវភៅមេរៀនទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌមួយចំនួន ក៏ដូចជាបានចុះអនុវត្តស្រាវជ្រាវជាក់ស្ដែងនៅសាលដំបូងរាជធានីភ្នំពេញដោយការសង្កេត ធ្វើបទសម្ភាសន៍ជាមួយក្រឡាបញ្ជីទទួលបន្ទុកលើសំណុំរឿង មន្ត្រីបុគ្គលិកជាប់ព័ន្ធ និងធ្វើការពិភាក្សាពិគ្រោះយោបល់ដោះស្រាយបញ្ហាជាក់ស្ដែងដែលជាប់គាំងជាមួយគ្រូដឹកនាំសារណា និងសហសេរិកផ្សេងទៀត។

**-វិសាលភាពនៃប្រធានបទសារណា:** ដើម្បីឱ្យការស្រាវជ្រាវប្រព្រឹត្តទៅបានល្អ និងអាចធ្វើការវិភាគបានគ្រប់ជ្រុងជ្រោយ វិសាលភាពនៃការស្រាវជ្រាវលើប្រធានបទស្ដីពី **នីតិវិធីនៃការប្ដឹងតវ៉ាក្នុងរឿង**

**ក្តីព្រហ្មទណ្ឌ** គឺត្រូវផ្តោតការយកចិត្តទុកដាក់លើ នីតិវិធីប្តឹងតវ៉ានៅសាលាដំបូង (ពាក់ព័ន្ធនឹងកិច្ចនីតិវិធីរបស់ព្រះរាជអាជ្ញា, ចៅក្រមស៊ើបសួរ និងបណ្តឹងប្រឆាំងនឹងសាលក្រម) នៅសាលាឧទ្ធរណ៍ (បណ្តឹងប្រឆាំងនឹងសាលដីកា) និងតុលាការកំពូល (បណ្តឹងសារទុក្ខ និងបណ្តឹងសើរើ) តែប៉ុណ្ណោះ មិនបានធ្វើការសិក្សាឱ្យស៊ីជម្រៅចំពោះតុលាការយោធាឡើយ។

**-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ:** ដូច្នេះសារណានេះត្រូវបានធ្វើឡើងដោយចែកចេញជាបីជំពូក ដែលជំពូកទី១ សិក្សាលើការប្តឹងតវ៉ាចំពោះកិច្ចនិតិវីធី ដែលផ្នែកទី១ បង្ហាញពីការប្តឹងតវ៉ាលើចំណាត់ការរបស់អយ្យការ និងផ្នែកទី២ បង្ហាញពីការប្តឹងតវ៉ានៅជំណាក់កាលចៅក្រមស៊ើបសួរ។ ជំពូកទី២ សិក្សាលើការប្តឹងតវ៉ាចំពោះសាលក្រមរបស់សាលាដំបូង ដែលផ្នែកទី១ បង្ហាញពីសញ្ញាណទូទៅនៃសាលក្រម និងផ្នែកទី២ បង្ហាញពីការប្តឹងតវ៉ាចំពោះសាលក្រមសាលដំបូង។ ជំពូកទី៣ សិក្សាលើការប្តឹងតវ៉ាទៅសាលាជម្រះក្តីជាន់ខ្ពស់ ដែលផ្នែកទី១ បង្ហាញពីការប្តឹងតវ៉ាចំពោះសាលដីការបស់សាលាឧទ្ធរណ៍ និងផ្នែកទី២ បង្ហាញពីបណ្តឹងសើរើរឿងក្តីព្រហ្មទណ្ឌ។ អត្ថន័យ និងអត្ថរសនៃកិច្ចការស្រាវជ្រាវនេះមានសេចក្តីខ្លឹមសារដូចតទៅនេះ៖

# ជំពូកទី ១
# ការប្ដឹងតវ៉ាចំពោះកិច្ចនីតិវិធី

## ផ្នែកទី ១ ៖ ការប្ដឹងតវ៉ាចំពោះចំណាត់ការរបស់អយ្យការ

ដើម្បីងាយស្រួលដល់ការសិក្សាអំពីការប្ដឹងតវ៉ានៅដំណាក់កាលអយ្យការ យើងខ្ញុំបានធ្វើការសិក្សាទៅលើ ការប្ដឹងចំពោះការតម្កល់រឿងទុកឥតចាត់ការ ក្នុងកថាខណ្ឌទី១ និងអានុភាពនៃការប្ដឹងតវ៉ាចំពោះការតម្កល់រឿងទុកឥតចាត់ការ ក្នុងកថាខណ្ឌទី២ ដូចខាងក្រោម៖

### កថាខណ្ឌទី ១ ៖ ការប្ដឹងតវ៉ាចំពោះការតម្កល់រឿងទុកឥតចាត់ការ

#### ក. សញ្ញាណទូទៅ

កាលណាព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្ដឹង និងពាក្យបរិហាដែលខ្លួនបានទទួលដោយផ្ទាល់ ឬ ដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក បើយល់ឃើញថាមាននត្ថិភាពនៃបទល្មើស (អវត្តមានបទល្មើស ឬមិនមែនជាបទល្មើសព្រហ្មទណ្ឌ) ពុំមានបន្ទុកគ្រប់គ្រាន់ ដើម្បីបង្ហាញពីពិរុទ្ធភាពរបស់ចារី ហើយការស្រាវជ្រាវបន្ថែមដែលអាចនឹងត្រូវធ្វើហាក់ដូចជា គ្មានប្រយោជន៍ និងគ្មានប្រសិទ្ធភាព ការផុតរលត់នៃបណ្ដឹងអាជ្ញា ដូច្នេះព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ[4]។ ប្រសិនបើជនរងគ្រោះមិនសុខចិត្តនឹងសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ ដោយយល់ឃើញថាសេចក្ដីសម្រេចនោះធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ឬជនដែលពាក់ព័ន្ធ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលឧទ្ធរណ៍បាន។

#### ខ. រយៈពេលនៃការប្ដឹងតវ៉ា

សេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ មិនអាចជៀសផុតពីការប្ដឹងតវ៉ានោះទេ។ ហេតុនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងកំណត់ថា កាលណាបណ្ដឹងណាមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្ដឹងអំពីសេចក្ដីសម្រេចរបស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចុះពាក្យបណ្ដឹងក្នុងបញ្ជី[5]។

ប្រសិនបើអ្នកប្ដឹងមិនសុខចិត្តនឹងសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។ ការតវ៉ានេះត្រូវធ្វើក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ការតវ៉ានេះត្រូវធ្វើតាមបណ្ដឹងសាមញ្ញ នៅអង្គការអយ្យការដែលពាក់ព័ន្ធ។ បន្ទាប់មកសំណុំរឿងត្រូវបានបញ្ជូនភ្លាម ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដោយតំណាងអយ្យការអមសាលាដំបូង។

---

[4] មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[5] មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**កថាភាគទី ២ ៖ អានុភាពនៃការប្តឹងតវ៉ាចំពោះការតម្កល់រឿងទុកឥតចាត់ការ**

ក្នុងករណីដែលជនរងគ្រោះនៃបទល្មើស បានដាក់ពាក្យបណ្តឹងទៅព្រះរាជអាជ្ញា ហើយកន្លងផុតរយៈពេល ២ (ពីរ) ខែហើយ មិនមានឆ្លើយតប ឬ ទទួលដំណឹងពីចំណាត់ការរបស់ព្រះរាជអាជ្ញាលើពាក្យបណ្តឹងនោះ ដែលបង្ហាញពីភាពអសកម្មរបស់អង្គអយ្យការអមសាលាដំបូង។ អ្នកប្តឹងអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ស្នើសុំឲ្យធ្វើអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់ពីបទល្មើសនោះបាន[6]។

នេះបង្ហាញឱ្យឃើញថាក្រមនីតិវិធីព្រហ្មទណ្ឌ បានបើកសិទ្ធិឱ្យភាគីជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិធ្វើការតវ៉ាក្នុងរយៈពេល២ (ពីរ) ខែលើភាពអសកម្ម ឬភាពមិនអើពើរបស់ព្រះរាជអាជ្ញា ដែលមិនបានធ្វើចំណាត់ការលើបណ្តឹងរបស់ខ្លួន។ មួយវិញទៀតការតវ៉ាសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ អាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។

ប្រសិនបើអគ្គព្រះរាជអាជ្ញាយល់ឃើញថា ការប្តឹងតវ៉ាមានមូលហេតុត្រឹមត្រូវ នោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលដំបូង ឱ្យធ្វើការចោទប្រកាន់។

អគ្គព្រះរាជអាជ្ញាធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ។ នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ រួចហើយអគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីសេចក្តីសម្រេចនេះទៅអ្នកប្តឹងតវ៉ា[7]។

ម្យ៉ាងទៀតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលក្នុងសំណុំរឿង ឲ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ ប៉ុន្តែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ឲ្យធ្វើការតម្កល់ទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ[8]។

**ផ្នែកទី ២ ៖ ការប្តឹងតវ៉ានៅដំណាក់កាលចៅក្រមស៊ើបសួរ**

ការសិក្សាអំពីការប្តឹងតវ៉ានៅដំណាក់ការចៅក្រមស៊ើបសួរ យើងខ្ញុំបានធ្វើការសិក្សាលើលក្ខណៈទូទៅនៃការប្តឹងតវ៉ាពីនិយ័តភាពនៃកិច្ចនីតិវិធី កថាខណ្ឌទី១ និងកថាខណ្ឌទី២ បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ។

[6] មាត្រា៤១ កថាខណ្ឌទី១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[7] មាត្រា៤១ កថាខណ្ឌទី៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[8] មាត្រា៤១ កថាខណ្ឌទ១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## កថាខណ្ឌទី ១ ៖ ការប្ដឹងតវ៉ាពីអនីយ័តភាពនៃកិច្ចនីតិវិធី

### ក. សញ្ញាណទូទៅ

នៅក្នុងដំណាក់ការនៃការស៊ើបសួរ បានបើកសិទ្ធិឱ្យភាគីក្នុងរឿងក្ដីព្រហ្មទណ្ឌមានសិទ្ធិលើកឡើងពីភាពមិនប្រក្រតីនៃកិច្ចនីតិវិធី ឬកិច្ចនីតិវិធីដែលពុំបានបំពេញល័ក្ខខ័ណ្ឌក្នុងក្របខណ្ឌច្បាប់បានតម្រូវ ឬនិយាយម្យ៉ាងទៀតថា កិច្ចនោះពុំបំពេញត្រឹមត្រូវតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ "មានតែសភាស៊ើបសួរប៉ុណ្ណោះ ដែលមានសមត្ថកិច្ច ដើម្បីពិនិត្យមោឃភាពនៃលិខិតនៃនិតិវិធី"[9]។ ហើយជាគោលការណ៍ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ សភាស៊ើបសួរមិនអាចទទួលសំណុំរឿងយកមកពិនិត្យ ឬយកមកដោះស្រាយដោយខ្លួនឯងបានទេ ត្រូវមានអ្នកប្ដឹង។ ការត្រួតពិនិត្យនិយ័តភាពនៃនីតិវិធី បើសិនជាមានកិច្ចណាមួយមិនត្រឹមត្រូវ ឬករណីរកឃើញកំហុស សភាស៊ើបសួរ ត្រូវចាត់ទុកកិច្ចនោះគ្មានសុពលភាព បានន័យថាអាចសុំមោឃកម្មបាន។ សំណួរអាចចោទសួរបានថាអ្វីទៅជាបណ្ដឹងសុំមោឃភាព? តើអ្នកណាខ្លះមានសិទ្ធិធ្វើបណ្ដឹងសុំមោឃភាពបាន?

បណ្ដឹងសុំមោឃភាពមានន័យថា ជាបណ្ដឹងសុំមោឃភាពទៅលើកិច្ចណាមួយថាមិនត្រឹមត្រូវហើយ ដែលបណ្ដឹងនេះអាចធ្វើឡើងដោយចៅក្រមស៊ើបសួរ ដោយព្រះរាជអាជ្ញា ដោយជនត្រូវចោទ និងដោយដើមបណ្ដឹងរដ្ឋប្បវេណី។ នៅពេលដែលសភាស៊ើបសួរពិនិត្យទៅឃើញថា កិច្ចនោះមានភាពមិនប្រក្រតី ហើយកិច្ចនោះអនុវត្តខុសជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា កិច្ចនោះនឹងធ្វើឱ្យប៉ះពាល់ទៅដល់សិទ្ធិការពារខ្លួន កិច្ចនោះអាចធ្វើឱ្យប៉ះពាល់ទៅដល់អ្វីដែលច្បាប់ចែងថាប្រសិនបើធ្វើខុសនឹងត្រូវមោឃភាព។ ដូច្នេះគេមានសិទ្ធិប្ដឹងទៅសភាស៊ើបសួរ ហើយដែលចំណុចនេះ អាចធ្វើការផ្ទៀងផ្ទាត់បាននៅក្នុង មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានចែងច្បាស់ថា នៅក្នុងក្របខណ្ឌដែលភាគីយល់ឃើញថាលិខិតណាមួយនៃនីតិវិធីមានមោឃភាព នោះភាគីអាចប្ដឹងទៅសភាស៊ើបសួរ។ ត្រង់ចំណុចនេះ មិនត្រឹមតែគេពិនិត្យឃើញលិខិត ឬ កិច្ចស៊ើបសួរទេ និយាយរួមគឺ កិច្ចនីតិវិធីទាំងអស់ដែលភាគីពិនិត្យឃើញមានបញ្ហា ឬមានកំហុសនីតិវិធី។ ដូច្នេះ ភាគីអាចលើកករណីនេះប្ដឹងទៅសភាស៊ើបសួរបានផងដែរ សំដៅដល់កិច្ចស៊ើបអង្កេត កិច្ចស៊ើបសួរ ហើយក៏រួមបញ្ចូលកិច្ចនៃការចោទប្រកាន់។ ឧទាហរណ៍ គេប្ដឹងប្រឆាំងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលជាកិច្ចចោទប្រកាន់មួយ។

នៅរាល់ពេលដែលទទួលបានបណ្ដឹង សភាស៊ើបសួរពិនិត្យមើលនិយ័តភាពនៃនីតិវិធី និងការប្រព្រឹត្តទៅដ៏ល្អនៃនីតិវិធីនេះ។ កាលណាពិនិត្យឃើញថាមូលហេតុនៃមោឃភាព សភាស៊ើបសួរអាច

[9] មាត្រា២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចាត់ទុកជាមោឃៈដោយឯកឯងនូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។ នេះគឺជាក្រុបខណ្ឌសភាស៊ើបសួរអាចមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យនិយ័តភាព។ ប៉ុន្តែនៅមានល័ក្ខខ័ណ្ឌមួយទៀត គឺទាក់ទងជាមួយនឹងដំណាក់កាលថាតើក្នុងដំណាក់កាលណាខ្លះដែលគេអាចស្នើសុំមោឃភាព។ ក្រមនីតិវិធីបានបញ្ជាក់ថាការស្នើសុំមោឃភាពនៃកិច្ចនីតិវិធីណាមួយត្រូវធ្វើឱ្យបានមុនការបិទការស៊ើបសួរដែលចូលជាស្ថាពរ និយាយម្យ៉ាងទៀតថាមិនអាចសុំមោឃភាពនៃកិច្ចស៊ើបអង្កេត កិច្ចចោទប្រកាន់ កិច្ចស៊ើបសួរបានទេ នៅចំពោះមុខសមត្ថកិច្ចនៃតុលាការជំនុំជម្រះ[10]។ ដូចនេះ បើកាលណាឆ្លងចូលដំណាក់កាលជំនុំជម្រះហើយ គេមិនអាចសុំមោឃភាពនៃកិច្ចនីតិវិធីស៊ើបសួរបានទៀតឡើយ។

មួយវិញទៀត តាមមាត្រា២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កថាខណ្ឌចុងក្រោយ ចែងថា ដីកាដែលអាចត្រូវប្តឹងឧទ្ធរណ៍បាន មិនអាចធ្វើជាកម្មវត្ថុនៃបណ្តឹងសុំមោឃភាពបានឡើយ។ បានសេចក្តីថា ដីការបស់ចៅក្រមស៊ើបសួរ ដែលអាចធ្វើការប្តឹងឧទ្ធរណ៍មិនអាចប្តឹងសុំមោឃភាពបានឡើយ។ ឧទាហរណ៍ ជនជាប់ចោទមិនអាចប្តឹងសុំមោឃភាពដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នបានឡើយ ដោយសារវាជាដីកាសម្រេច ដែលបើកផ្លូវឲ្យជនជាប់ចោទធ្វើការប្តឹងឧទ្ធរណ៍ មិនមែនបើកផ្លូវប្តឹងសុំមោឃភាពនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ននោះឡើយ។

### ខ. នីតិវិធីនៃការស្នើសុំមោឃភាព

ក្នុងករណីនេះ ពាក្យសុំឲ្យត្រួតពិនិត្យពីនិយ័តភាពនៃកិច្ចនីតិវិធី ត្រូវចុះបញ្ជីនៅការិយាល័យនៃសភាស៊ើបសួរ។ ភ្លាមនោះក្រឡាបញ្ជីសុំឱ្យចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងនៃនីតិវិធីមកឲ្យខ្លួនភ្លាម[11]។

ដូចដែលបានលើកឡើងពីខាងដើម គឺថាកិច្ចនេះមានចែងនៅក្នុងមាត្រា ២៥៣ ដែលថាភាគីអាចស្នើសុំបានគ្រប់កិច្ចទាំងអស់ដើម្បីឱ្យសភាស៊ើបសួរពិនិត្យលើនិយ័តភាព ហើយបើករកឃើញនូវកំហុសអាចប្រកាសអំពីមោឃភាព។ នៅក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់ពីដីកា ឬកិច្ចដែលអាចសុំមោឃភាពបាន ហើយតើកិច្ចណាខ្លះដែលវាប៉ះពាល់ធ្ងន់ធ្ងរ ហើយដែលក្រមនីតិវិធីតម្រូវថាត្រូវតែធ្វើហើយមិនធ្វើគឺអាចនាំឲ្យមានមោឃភាព។ យើងសង្កេតឃើញថាកិច្ចដែលអាចត្រូវមោឃភាពមានពីរផ្នែកគឺ:

### ខ.១. កិច្ចដែលត្រូវគោរពតាមអត្ថបទច្បាប់

កិច្ចដែលត្រូវតែធ្វើតាមអត្ថបទច្បាប់ ហើយបើមិនធ្វើតាមត្រូវមោឃភាព បានសេចក្តីថាច្បាប់ចែងតែម្តងថានៅក្នុងការបមពេញកិច្ចនេះគឺត្រូវធ្វើអនុវត្តតាមរបៀបនោះ ហើយច្បាប់ចែងទៀតថាប្រសិនបើមិនធ្វើតាមទេ ត្រូវចាត់ទុកថាកិច្ចនោះគ្មានសុពលភាពន័យថាអាចសុំមោឃកម្មបាន។ យោងតាមមាត្រា ៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះកិច្ចនីតិវិធីនៃការបើកការស៊ើបសួរ ព្រះរាជ

[10] មាត្រា២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[11] មាត្រា២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អាជ្ញាត្រូវបើកការស៊ើបសួរតាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ។ នៅក្នុងដីកានេះមានបញ្ជាក់យ៉ាងច្បាស់នូវៈ

-សេចក្តីសង្ខេបនៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

-ឈ្មោះបុគ្គលដែលរងការស៊ើបសួរ។

ព្រមទាំងមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ដោយព្រះរាជអាជ្ញាទៀតផង។ ហើយទម្រង់ដែលបានលើកឡើងខាងលើនេះទាមទារឱ្យគោរពជាដាច់ខាត បើមិនដូច្នេះទេ ដីការបញ្ជូនរឿងឱ្យស៊ើបសួរត្រូវទុកជាមោឃៈ (នេះជាលក្ខណៈមោឃភាពដាច់ខាតនៃនីតិវិធីបើកការស៊ើបសួរដែលធ្វើឡើងដោយតំណាងអយ្យការ)។ ក្រមនីតិវិធីព្រហ្មទណ្ឌទាក់ទងនឹងកិច្ចស៊ើបសួរ ក៏បានចែងកំណត់ថានៅក្នុងមាត្រា២៥២ វិធាន និងទម្រង់ការដែលចែងដោយមាត្រាខាងក្រោមស្តីពីអំពីបទប្បញ្ញត្តិទូទៅនៃនីតិវិធីស៊ើបសួរមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នោះទេ នៃឱ្យមានមោឃភាពនៃនីតិវិធីៈ

- មាត្រា ១២២ (ការបើការស៊ើបសួរ)
- មាត្រា១២៣ (សមត្ថកិច្ចដែនដី)
- កថាខណ្ឌទី៣ នៃមាត្រា១២៤ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)
- កថាខណ្ឌទី១ និងទី ២ នៃមាត្រា១២៥ (វិសាលភាពនៃការប្តឹង)
- មាត្រា១២៨ (ជំនួយរបស់ក្រឡាបញ្ជី)

ត្រង់ចំណុចនេះឧទាហរណ៍ ក្រឡាបញ្ជីគឺជាជំនួយការរបស់ចៅក្រមស៊ើបសួរ។ ស្រាប់តែនៅក្នុងក្របខ័ណ្ឌនៃកិច្ចស៊ើបសួរ ក្រឡាបញ្ជីបានធ្វើកិច្ចស៊ើបសួរដែលជាកិច្ចត្រូវធ្វើដោយចៅក្រមស៊ើបសួរនោះគេអាចស្នើសុំមោឃភាពបាន ដោយសារក្រមនីតិវិធីព្រហ្មទណ្ឌ តម្រូវមិនឲ្យក្រឡាបញ្ជីធ្វើកិច្ចទាំងឡាយណាដែលជាកិច្ចរបស់ចៅក្រមនោះឡើយ[12]។

ចំពោះនៅដំណាក់ស៊ើបអង្កេត យើងសង្កេតឃើញមានមាត្រាចំនួនពីរដែលចែងកំណត់អំពីមោឃភាព កាលបើមិនគោរពវិធានបញ្ញត្តិ គឺមាន មាត្រា ១០៩ និងមាត្រា ១១៧៖

+មាត្រា១០៩ វិធាន និងទម្រង់ការដែលបានបញ្ញត្តនៅមាត្រាៈ

- មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)
- មាត្រា ៩១ (ការឆែកឆេរ)
- មាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង)

[12] មាត្រា១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ)
- មាត្រា ៩៤ (បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង)
- មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)
- មាត្រា ៩៦ (ការឃាត់ខ្លួន)
- មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)
- មាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)
- មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
- មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៦ (ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង)
- មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ)

មានលក្ខណៈដាចខាត់ត្រូវតែគោរព បើមិនដូច្នេះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។

+មាត្រា ១១៧ ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋមវិធាន និងទម្រង់ការដែលចែងនៅក្នុងមាត្រាៈ

- មាត្រា ៩៦ (ការឃាត់ខ្លួន)
- មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)
- មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
- មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា ១១៣ (ការឆែកឆេរ)
- មាត្រា១១៤ (ការបញ្ជូនឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម)

មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នោះទេនាំឱ្យមានមោឃភាពនៃនីតិវិធី។ នៅក្នុងក្រមនីតិវិធីនេះបានចែងនូវចំណុចមួយចំនួនថា បើសិនជាមិនធ្វើតាមនៅក្នុង ករណីមួយចំនួន គឺច្បាប់ចែងថាត្រូវតែធ្វើមោឃភាព។ ទាំងនេះគេហៅថា កិច្ចដែលគោរពតាមអត្ថបទច្បាប់ ឬ តាមការកំណត់របស់ច្បាប់។

**ខ.២. កិច្ចដែលមិនបានកំណត់ដោយច្បាប់**

កិច្ចដែលមិនបានកំណត់ដោយច្បាប់មានន័យថា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមិនបានចែងថា បើមិនគោរពតាមគឺត្រូវមោឃភាពនោះទេ។ កិច្ចនោះគឺសំដៅដល់កិច្ចទាំងឡាយដែលប៉ះពាល់ធ្ងន់ធ្ងរបំផុតគឺការសុំមោឃភាពដោយសារ ការប៉ះពាល់ធ្ងន់ធ្ងរទៅដល់សិទ្ធិការពារខ្លួន។ ចំណុចនេះបានបញ្ញត្តិនៅក្នុងមាត្រា២៥២ កថាខណ្ឌចុងក្រោយចែងថាៈ នាំឱ្យមានមោឃភាពផងដែរ កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនីតិ

ព្រហ្មទណ្ឌនេះ ឬបទប្បញ្ញត្តិទាំងឡាយស្តីពីនីតិវិធីព្រហ្មទណ្ឌធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលទទួលរងការបំពាននេះ។ ច្បាប់បានកំណត់ទៀតថាតើវិធានការយ៉ាងម៉េចដែលហៅថាវិធាន ឬទម្រង់ការដែលមានលក្ខណៈសំខាន់។ សំខាន់នោះគឺសំដៅថាជាវិធាន ឬទម្រង់ការដែលមានបំណងធានាការពារការគោរពសិទ្ធិការពារខ្លួន។

ដូចនេះ មានបទប្បញ្ញត្តិមួយចំនួន ច្បាប់មិនចែងថា បើមិនបំពេញធ្វើតាមទម្រង់ការទេ ត្រូវមោឃភាពនោះទេ។ ប៉ុន្តែផ្ទុយមកវិញ ការបំពាននេះវាធ្វើឲ្យប៉ះពាល់ទៅដល់ប្រយោជន៍ ឬសិទ្ធិការពារខ្លួនរបស់ភាគី។ ដូចនេះគេអាចសុំមោឃភាពបាន ឧទាហរណ៍ ដូចជា ការស្តាប់ចម្លើយសាក្សីជាដើម។

ជាទូទៅ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយសាក្សីបាន។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌនេះបានចែងថា បើសាក្សីនោះមានតម្រុយពិរុទ្ធភាពដែលបញ្ជាក់ថាបានចូលរួមប្រព្រឹត្តបទល្មើស នោះចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយក្នុងនាមជាសាក្សីបានទេ។ ចៅក្រមស៊ើបសួរត្រូវដាក់ជននោះឱ្យស្ថិតនៅក្រោមការពិនិត្យ។ នៅក្នុងដំណាក់កាលស៊ើបសួរនេះ ដើម្បីបំលែងជននោះពីសាក្សីឱ្យទៅជាជនត្រូវចោទដើម្បីជននោះអាចប្រើប្រាស់នូវសិទ្ធិការពារខ្លួនក្នុងនាមជាភាគី។ នៅក្នុងករណីនេះ ប្រសិនចៅក្រមចង់ស្តាប់ចម្លើយសាក្សីដែលមានតម្រុយពិរុទ្ធភាពប្រភេទនេះ នោះចៅក្រមត្រូវបំលែងឋានៈជននោះពីសាក្សីទៅជាជនត្រូវចោទតាមរយៈការសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ[13]។

ជាគោលការណ៍ ដើម្បីអាចឱ្យសភាស៊ើបសួរអាចពិនិត្យអំពីករណីនេះបានគឺ ជាទូទៅភាគីធ្វើបណ្តឹងសុំមោឃភាពដែលទាមទារដោយភាគីត្រូវតែបំពេញលក្ខខណ្ឌមួយចំនួនហើយ ល័ក្ខខ័ណ្ឌនោះមានចែងនៅក្នុងមាត្រា២៧៩ ដែលបណ្តឹងសុំត្រូវមានៈ

– សំអាងហេតុមិនមែនដាក់បណ្តឹងចោលនោះទេគឺ ត្រូវមានសំអាងហេតុមានហេតុផលពន្យល់ថាកិច្ចនោះមានភាពមិនប្រក្រតីខុសច្បាប់ហើយប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់ភាគី។

– ទាមទារឱ្យមានមូលកភាពយ៉ាងជាក់ស្តែង គឺសំដៅដល់មូលដ្ឋានទាំងឡាយដែលនាំឱ្យសន្និដ្ឋានថាពិតជានាំឱ្យមានការប្រព្រឹត្តខុសជាមួយនឹងនីតិវិធី។

– មិនអាចសុំមោឃភាពចំពោះកិច្ចដែលគេអាចប្តឹងឧទ្ធរណ៍បានទេពោលគឺ ប្រសិនបើកិច្ចនោះអាចប្តឹងឧទ្ធរណ៍បានត្រូវតែប្តឹងឧទ្ធរណ៍ គឺមិនត្រូវប្តឹងសុំមោឃភាពនោះទេ។

### ខ.៣. អានុភាពមោឃកម្ម

នៅពេលដែលសភាស៊ើបសួរពិនិត្យឃើញថាកិច្ចរបស់ចៅក្រមស៊ើបសួរ ឬកិច្ចនៃនីតិវិធីណាមួយមានបញ្ហាខុសជាមួយច្បាប់ នោះសភាស៊ើបសួរធ្វើការសម្រេចធ្វើមោឃភាពលើកិច្ចនោះ។ សភាស៊ើបសួរក៏អាចសម្រេចផងដែរ ថាតើមោឃភាពនេះត្រូវអនុវត្តទៅលើកិច្ច ឬ លិខិតផ្សេងទៀតដែរឬទេ

[13] មាត្រា ១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បានន័យថានៅពេលដែលសភាស៊ើបសួរសម្រេចមោឃភាពទៅលើកិច្ចនៃនីតិវិធីតាមពាក្យប្ដឹងសុំមោឃកម្មរួចហើយសភាស៊ើបសួរត្រូវពិនិត្យទៅលើកិច្ចដទៃទៀតដែលមានការពាក់ព័ន្ធ។ ដោយឈរលើមូលដ្ឋាននេះ សភាស៊ើបសួរត្រូវសម្រេចរាល់កិច្ចផ្សេងទៀតដែលពាក់ព័ន្ធ ហើយដែលត្រូវធ្វើមោឃភាពដូចគ្នា។ ដូច្នេះ សភាស៊ើបសួរត្រូវសម្រេមើលថាតើកិច្ចនោះតែឯកឯងទេដែលខុស នោះសភាស៊ើបសួរសម្រេចតែកិច្ចមួយនោះទៅ។ ប៉ុន្តែ ប្រសិនបើមានកិច្ចផ្សេងទៀត ហើយដែលវាខុសដែរ នោះសភាស៊ើបសួរអាចសម្រេចពិនិត្យអំពីមោឃភាពទៅលើកិច្ចនោះបានដូចគ្នា។ កិច្ច ឬលិខិតដែលត្រូវបានសម្រេចមោឃភាពនេះ ត្រូវដក់ចេញពីសំណុំរឿងនៃនីតិវិធីហើយត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ[14]។

## កថាខណ្ឌទី ២ ៖ បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ គឺជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (ទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍) ទៅនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរនៅសាលាដំបូង ដើម្បីទាមទារឲ្យវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ ភាពមិនត្រឹមត្រូវ នៃដីកាសម្រេចនោះ។ ក្នុងករណីដែលបុគ្គលណាមួយមិនសុខចិត្ត នឹងសេចក្ដីសម្រេចខាងលើ ឬ យល់ឃើញថាការចេញសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរមិនត្រឹមត្រូវ ដូច្នេះបុគ្គលនោះអាចដាក់ពាក្យបណ្ដឹងឧទ្ធរណ៍របស់ខ្លួនបាន។ ម្យ៉ាងទៀត គ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ រួមទាំងដីកាដំណោះស្រាយ អាចត្រូវបានប្ដឹងឧទ្ធរណ៍ ប៉ុន្តែក៏អាចប្ដឹងសភាស៊ើបសួរទៅនឹងកិច្ចមួយចំនួនទៀតរបស់ចៅក្រមស៊ើបសួររួមមាន៖ បណ្ដឹងតវ៉ានឹងសេចក្ដីសម្រេច បណ្ដឹងសុំឲ្យមោឃៈកិច្ច និងពាក្យសុំឱ្យសម្រេចជំនួសដូចជា៖ ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា ទៅចៅក្រមស៊ើបសួរ ប៉ុន្តែចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេលដែលកំណត់ក្នុងច្បាប់ទេ ដូច្នេះហើយព្រះរាជអាជ្ញាអាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំ ទៅសភាស៊ើបសួរឲ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន។

### ក. និយមន័យ

### ក.១ បណ្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍ គឺជាពាក្យបណ្ដឹងតវ៉ារបស់ភាគីណាមួយ ដែលប្ដឹងសុំឲ្យកែប្រែសេចក្ដីសម្រេច ឬ សាលក្រមរបស់សាលាដំបូង (តុលាការរាជធានី-ខេត្ត) ដែលភាគីនោះពុំសុខចិត្តដោយយល់ឃើញថាសេចក្ដីសម្រេច ឬ សាលក្រមនោះ ធ្វើឲ្យខូចប្រយោជដល់ខ្លួន។

### ក.២ ដីកាសម្រេច

[14] មាត្រា ២៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដីកា គឺជាសេចក្តីសម្រេចដែលតុលាការ ឬ ចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ហើយមិនមែនជាសាលក្រមទេ។

**ក.៣ ចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរ គឺជាចៅក្រមដែលទទួលបន្ទុកស៊ើបអង្កេត ស្រាវជ្រាវរកការពិតចំពោះបទល្មើសព្រហ្មទណ្ឌ ដែលព្រះរាជអាជ្ញាផ្តើមធ្វើការចោទប្រកាន់ រួចធ្វើការបញ្ជូនមក។

សរុបសេចក្តីមក បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (សភាស៊ើបសួរនៃសាលាឧទ្ធរណ៍) ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរនៅសាលាដំបូង ដើម្បីទាមទារឲ្យវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ ភាពមិនត្រឹមត្រូវនៃដីកានោះ។

**ខ. សិទ្ធិប្តឹងឧទ្ធរណ៍ ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ**

**ខ.១ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា**

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានផ្តល់សិទ្ធិធំទូលាយណាស់សម្រាប់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា អាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរបាន[15]។

**ខ.២ ជនត្រូវចោទ**

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានផ្តល់សិទ្ធិឲ្យជនត្រូវចោទ អាចធ្វើការប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរបានទេ ហើយដីកាសម្រេចដែលជនត្រូវចោទអាចប្តឹងឧទ្ធរណ៍បានមានដូចខាងក្រោម[16]៖

***១. ដីកាបដិសេធពាក្យសុំឲ្យធ្វើកិច្ចស៊ើបសួរ***

ជាទូទៅនៅពេលដែលជនត្រូវចោទបានស្នើសុំឲ្យ ចៅក្រមស៊ើបសួរធ្វើការបំពេញកិច្ចនៅចំណុចណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់ខ្លួន តែចៅក្រមស៊ើបសួរមិនបានសម្រេចធ្វើតាមការស្នើសុំនោះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធដោយមានសំអាងហេតុក្នុងចិរវេលាមួយខែ បន្ទាប់ពីបានទទួលពាក្យសុំ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

***២. ដីកាមិនព្រមប្រគល់វត្ថុដែលចាប់ឲ្យទៅម្ចាស់ដើមវិញ***

នៅពេលដែលជនត្រូវចោទ ដាក់ពាក្យសុំឲ្យចៅក្រមស៊ើបសួរធ្វើការប្រគល់វត្ថុដែលចាប់យកមកឲ្យខ្លួនវិញ តែចៅក្រមស៊ើបសួរមិនបានសម្រេចតាមការស្នើសុំរបស់ជនត្រូវចោទទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ជនត្រូវចោទដែលជាអ្នកដាក់ពាក្យសុំ។

[15] មាត្រា ២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[16] មាត្រា ២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

*៣. ដីកាបដិសេធពាក្យសុំធ្វើកោសលវិច័យ*

ក្នុងករណីដែលជនត្រូវចោទយល់ឃើញថា ការធ្វើកោសលវិច័យមានប្រយោជន៍សម្រាប់ខ្លួន នោះជនត្រូវចោទអាចដាក់ពាក្យសុំឲ្យធ្វើកោសលវិច័យទៅចៅក្រមស៊ើបសួរ ប៉ុន្តែបើចៅក្រមស៊ើបសួរបដិសេធក្នុងការស្នើសុំរបស់ជនត្រូវចោទនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ក្នុងរយៈពេលមួយខែ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ។

*៤. ដីកាបដិសេធពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬសុំឲ្យធ្វើប្រតិកោសលវិច័យ*

កាលណាជនត្រូវចោទយល់ឃើញថា ការធ្វើកោសលវិច័យបន្ថែម មានប្រយោជន៍សម្រាប់ខ្លួន នោះ ជនត្រូវចោទអាចដាក់ពាក្យសុំទៅចៅក្រមស៊ើបសួរ ប៉ុន្តែបើចៅក្រមស៊ើបសួរបដិសេធក្នុងការធ្វើកោសលវិច័យបន្ថែមនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុក្នុងរយៈពេលមួយខែ ហើយត្រូវជូនដំណឹងជាបន្ទាន់ទៅដល់ជនត្រូវចោទដែលបានដាក់ពាក្យស្នើសុំនោះ។

*៥. ដីកាស្តីពីរឿងឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ*

នៅពេលដែលចៅក្រមស៊ើបសួរ ធ្វើចំណាត់ការរបស់ខ្លួនដែលទាក់ទងនិងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ លើជនត្រូវចោទដោយចេញដីកាសម្រេចដែលអាចឲ្យជនត្រូវចោទធ្វើការប្តឹងឧទ្ធរណ៍បានមានដូចខាងក្រោម៖

ក. ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

ខ. ដីកាសម្រេចពន្យាពេលការឃុំខ្លួនបណ្តោះអាសន្ន

គ. ដីកាសម្រេចមិនព្រមដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន

ឃ. ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោយការត្រួតពិនិត្យតាមផ្លូវតុលាការ

ង. ដីកាសម្រេចមិនព្រមកែប្រែ ឬលើកលែងការត្រួតពិនិត្យតាមផ្លូវតុលាការ

ច. ដីកាសម្រេចរក្សាទុកជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

**ខ.៣ ដើមបណ្តឹងរដ្ឋប្បវេណី**

ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានផ្តល់សិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការប្តឹងឧទ្ធរណ៍លើគ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរនោះទេ។ សិទ្ធិទាំងនោះគឺមានព្រំដែនកម្រិត ដោយដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើបណ្តឹងឧទ្ធរណ៍ទៅលើដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ[17] ដូចខាងក្រោម៖

*១. ដីកាបដិសេធពាក្យសុំឲ្យធ្វើកិច្ចស៊ើបសួរ*

ជាគោលការណ៍ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យ ចៅក្រមស៊ើបសួរធ្វើការបំពេញកិច្ចនៅចំណុចណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់ខ្លួន តែចៅក្រមស៊ើប

[17] មាត្រា ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សួរមិនបានធ្វើការសម្រេចតាមការស្នើសុំនោះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធ ដោយមានសំអាងហេតុ ក្នុងចិរវេលាមួយខែបន្ទាប់ពីទទួលពាក្យសុំនោះ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

*២. ដីកាមិនព្រមស៊ើបសួរ*

នៅក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ពាក្យបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅមុខចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរធ្វើការបញ្ជូនបណ្តឹងនោះទៅព្រះរាជអាជ្ញា ដើម្បីឲ្យព្រះរាជអាជ្ញា ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមកចៅក្រមស៊ើបសួរវិញ។ នៅពេលចៅក្រមស៊ើបសួរ បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរហើយ តែមិនព្រមស៊ើបសួរនោះ ចៅក្រមស៊ើបសួរ ត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ និងធ្វើការជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

*៣. ដីកាកំណត់ចំនួនទឹកប្រាក់កក់*

ករណីដែលចៅក្រមស៊ើបសួរបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចៅក្រមស៊ើបសួរយល់ឃើញថា ដោយផ្អែកទៅលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរអាចកំណត់តាមដីកាសម្រេច នូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់។

*៤. ដីកាប្រកាសមិនព្រមទទួលពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*

នៅពេលដែលចៅក្រមស៊ើបសួរ បានកំណត់រយៈពេលឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការបង់ប្រាក់តម្កល់ទុកសម្រាប់ធ្វើការស៊ើបសួរ តែដើមបណ្តឹងរដ្ឋប្បវេណីមិនបានធ្វើការបង់ប្រាក់តាមការកំណត់ទេនោះ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចមិនព្រមទទួលពាក្យបណ្តឹង ដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

**៥. ដីកាផ្តន្ទាទោសដើមបណ្តឹងរដ្ឋប្បវេណី**

ក្នុងករណីដែលចៅក្រមស៊ើបសួរ បានបើកការស៊ើបសួរតាមពាក្យបណ្តឹង ដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយការស៊ើបសួរទៅត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ ដោយចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីដោយរំលោភបំពាន និងបានអូសបន្លាយពេលវេលាយូរនោះ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចឲ្យដើមបណ្តឹងរដ្ឋប្បវេណី បង់ប្រាក់ពិន័យមិនឲ្យលើសប្រាក់កម្កល់ទេ និងត្រូវជូនដំណឹងបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

*៦. ដីកាមិនព្រមប្រគល់សងវត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ*

នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ពាក្យសុំឲ្យចៅក្រមស៊ើបសួរធ្វើការប្រគល់វត្ថុដែលចាប់យកមកឲ្យខ្លួនវិញ តែចៅក្រមស៊ើបសួរមិនបានសម្រេចតាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋ

ប្បវេណីទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាអ្នកដាក់ពាក្យសុំ។

*៧. ដីកាបដិសេធពាក្យសុំធ្វើកោសលវិច័យ*

នៅក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ការធ្វើកោសលវិច័យមានប្រយោជន៍សម្រាប់ខ្លួននោះ ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យសុំឲ្យធ្វើកោសលវិច័យទៅចៅក្រមស៊ើបសួរ ប៉ុន្តែបើចៅក្រមស៊ើបសួរបដិសេធក្នុងការស្នើសុំនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុក្នុងរយៈពេលមួយខែ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

*៨. ដីកាបដិសេធពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬសុំឲ្យធ្វើប្រតិកោសលវិច័យ*

កាលណាដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថាការធ្វើកោសលវិច័យបន្ថែម មានប្រយោជន៍សម្រាប់ខ្លួននោះ ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យស្នើសុំទៅចៅក្រមស៊ើបសួរ តែបើចៅក្រមស៊ើបសួរបដិសេដក្នុងការធ្វើកោសលវិច័យបន្ថែមនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ក្នុងរយៈពេលមួយខែ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

*៩. ដីកាដំណោះស្រាយ*

នៅពេលដែលចៅក្រមស៊ើបសួរ បានបិទការស៊ើបសួររបស់ខ្លួន ហើយបញ្ជូនសំណុំរឿងទៅអយ្យការ ដើម្បីឲ្យអយ្យការធ្វើដីកាសន្និដ្ឋានស្ថាពរ រួចចៅក្រមស៊ើបសួរធ្វើការចេញដីកាដំណោះស្រាយដើម្បីបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬ លើកលែងចោទប្រកាន់ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវធ្វើការជូនពត៌មានទៅព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីករណីដែលមាន។

**ខ.៤ បុគ្គលនៅក្រៅនីតិវិធីស៊ើបសួរ**

គ្រប់បុគ្គលនៅក្រៅនីតិវិធីស៊ើបសួរ ដែលអនុលោមតាមមាត្រា ១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដែលសុំឲ្យប្រគល់សងមកខ្លួនវិញនូវវត្ថុដែលចាប់យក អាចប្តឹងឧទ្ធរណ៍ចំពោះដីការសម្រេចរបស់ចៅក្រមស៊ើបសួរដែលបដិសេធពាក្យសុំនេះ។

**គ. រយៈពេលប្តឹងឧទ្ធរណ៍**

នៅពេលមានពាក្យបណ្តឹងឧទ្ធរណ៍ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវធ្វើក្នុងរយៈពេល ១(មួយ)ខែ យ៉ាងយូរគិតពីពេលដែលចៅក្រមស៊ើបសួរចេញដីកាសម្រេចនោះ។

ចំពោះពាក្យបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ ចាប់ពីថ្ងៃដែលចៅក្រមស៊ើបសួរធ្វើការជូនដំណឹងអំពីដីកាសម្រេចនេះ។

សូមធ្វើការបញ្ជាក់ពាក្យ "ដីកា" ដែលកំណត់ក្នុងច្បាប់ សំដៅទៅលើដីកាសម្រេចរបស់ចៅក្រមស៊ើបសួរតែមួយគត់ ដូចជាករណី ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។

ច្បាប់បានកំណត់យ៉ាងច្បាស់លាស់ អំពីរយៈពេលសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍ របស់ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងគ្រប់បុគ្គលនៅក្រៅនីតិវិធីស៊ើបសួរ ត្រូវធ្វើក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃដែលបានធ្វើការជូនដំណឹងពីដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ។ ប្រសិនបើការជូនដំណឹង ធ្វើឡើងដោយការប្រគល់សេចក្តីចម្លងនៃដីកាសម្រេចដោយមានចំណារទទួលនោះ រយៈពេលបណ្តឹងឧទ្ធរណ៍ផ្តើមគិតចាប់ពីកាលបរិច្ឆេទនៃចំណារទទួលនោះ។

ការដោះលែងជនត្រូវចោទ ដែលជាប់ឃុំឲ្យមានសេរីភាព មានន័យថា កាលណាចៅក្រមស៊ើបសួរសម្រេចឲ្យដោះលែងជនត្រូវចោទដែលជាប់ឃុំបណ្តោះអាសន្នបានលុះត្រាតែផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ប៉ុន្តែលើកលែងតែ ព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងជនត្រូវចោទនោះភ្លាមផងដែរ។ ចំពោះសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញាត្រូវដាក់បញ្ចូលក្នុងសំណុំរឿងនៃនីតិវិធី។ ត្រូវធ្វើដូចគ្នាផងដែរ ចំពោះដីកាលើកលែងចោទប្រកាន់ កាលណាដីកាសម្រេចនេះមានអានុភាពនាំឲ្យដោះលែងជនត្រូវចោទដែលជាប់ឃុំ។ ប៉ុន្តែក្នុងករណីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា អំពីដីកាដោះលែងឲ្យនៅក្រៅឃុំ ឬ លើកលែងចោទប្រកាន់នោះ។ ជនត្រូវចោទដែលជាប់ឃុំត្រូវបានរក្សាទុកក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្តឹងឧទ្ធរណ៍។

**ឃ.ទម្រង់នៃការប្រកាសប្តឹងឧទ្ធរណ៍**

**ឃ.១ ទីកន្លែងដាក់ពាក្យបណ្តឹង**

ពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើតាមការប្រកាសប្តឹងនៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង។ មានន័យថា បុគ្គលដែលច្បាប់កំណត់ថាអាចធ្វើបណ្តឹងឧទ្ធរណ៍បាន ត្រូវធ្វើពាក្យបណ្តឹងឧទ្ធរណ៍របស់ខ្លួនឲ្យបានត្រឹមត្រូវ ហើយបណ្តឹងឧទ្ធរណ៍ ត្រូវប្រកាសប្តឹងនៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូងដែលចេញសេចក្តីសម្រេចនោះតែម្តង ហើយពាក្យបណ្តឹងឧទ្ធរណ៍ដាច់ខាតត្រូវចុះក្នុងបញ្ជីនៃបណ្តឹងឧទ្ធរណ៍របស់តុលាការជាន់ដំបូងនោះជាកំណត់។

ប៉ុន្តែបើបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវមានបញ្ជីបណ្តឹងឧទ្ធរណ៍ និងពាក្យសុំនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ កាលណាសភាស៊ើបសួរ ត្រូវបានប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំ នៅក្រឡាបញ្ជីនៃសភាស៊ើបសួរ សុំឲ្យក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរផ្ញើរមកឲ្យខ្លួននូវសំណុំរឿងនៃនីតិវិធី ឬសំណុំរឿងបង្ការទុក។

មេធាវីរបស់ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬគ្រប់បុគ្គលនៅក្រៅនីតិវិធី ពាក្យបណ្តឹងឧទ្ធរណ៍អាចត្រូវធ្វើបានលុះត្រាតែមេធាវីត្រូវតែមានភ្ជាប់ជាមួយលិខិតផ្ទេរសិទ្ធិរបស់បុគ្គលមកជាមួយ ហើយមេធាវីត្រូវប្រកាសប្តឹងឧទ្ធរណ៍នៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូងនោះដែរ។

ជនត្រូវចោទ ដែលត្រូវបានឃុំខ្លួន បណ្តឹងឧទ្ធរណ៍ត្រូវធ្វើតាមការប្រកាសប្តឹងនៅមុខ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវប្រគល់ភ្លាមនូវលិខិតប្តឹងឧទ្ធរណ៍មួយច្បាប់ជូនទៅ ក្រឡាបញ្ជីនៃតុលាការជាន់ដំបូង ហើយលិខិតនេះត្រូវចុះនៅក្នុងបញ្ជីនៃបណ្តឹងឧទ្ធរណ៍។

**ឃ.២ ការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍**

កាលណាបានទទួលបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៅតុលាការជាន់ដំបូងត្រូវជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរ។ មានន័យថា ក្រឡាបញ្ជីមិនអាចបំពេញកិច្ចណាមួយដោយឯងៗ ដោយមិនមានការជូនដំណឹងដល់ចៅក្រមរបស់ខ្លួនបានឡើយ បើទោះបីជាពាក្យបណ្តឹងឧទ្ធរណ៍ ជាកិច្ចការរបស់ក្រឡាបញ្ជីត្រូវបំពេញ។ បន្ទាប់ពីក្រឡាបញ្ជីរៀបចំធ្វើសេចក្តីចម្លងផ្សេងៗទាក់ទងទៅនឹងសំណុំរឿងដាច់ខាតក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដោយមានសេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់ជាមួយផង។ សេចក្តីចម្លងនេះ ត្រូវធ្វើដោយក្រឡាបញ្ជីនៃតុលាការជាន់ដំបូងក្រោយពីបានឃើញនិទ្ទេសដែលចុះបញ្ជីបណ្តឹងឧទ្ធរណ៍។

ចំពោះបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ក្រឡាបញ្ជីនៃសភាស៊ើបសួរ សុំឲ្យក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរ ផ្ញើមកឲ្យខ្លួននូវសំណុំរឿងនៃនីតិវិធី។

ពាក្យបណ្តឹងឧទ្ធរណ៍ទៅនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ក្រឡាបញ្ជីត្រូវរៀបចំសំណុំរឿងបញ្ជូនទៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ នៅក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីមានពាក្យបណ្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈដែលមិនអាចជំនះបាន។

កាលណាសំណុំរឿងបង្ការទុក ត្រូវបានធ្វើឡើងស្របតាមមាត្រា១២៩ (មុខងាររបស់ក្រឡាបញ្ជី) នៃក្រមនេះ នោះចៅក្រមស៊ើបសួររក្សាទុកសំណុំរឿងដើម។សំណុំរឿងបង្ការទុកត្រូវបញ្ជូនទៅសភាស៊ើបសួរ។ មានន័យថា ក្រឡាបញ្ជីត្រូវចម្លងលិខិតនីមួយៗនៃសំណុំរឿងតាម លទ្ធភាពដែលអាចធ្វើទៅបាន ហើយត្រូវតែបញ្ជាក់ថា ត្រឹមត្រូវតាមលិខិតដើមដោយក្រឡាបញ្ជី។

ប៉ុន្តែក្នុងករណី មានបណ្តឹងឧទ្ធរណ៍ចំពោះ ដីកាណាមួយក្រៅពីដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចបន្តការស៊ើបសួររបស់ខ្លួនបាន លើកលែងតែ មានសេចក្តីសម្រេចផ្ទុយរបស់ប្រធានសភាស៊ើបសួរ។ សេចក្តីសម្រេចនេះមិនអាចតវ៉ាបានឡើយ។ ពីព្រោះថា ដីកាដំណោះស្រាយ អាចជាដីកាលើកលែងចោទប្រកាន់ ឬ ដីកាបញ្ជូនសំណុំរឿងទៅជំណុំជម្រះ ដូច្នេះហើយចៅក្រមមិនអាចបន្តស៊ើបសួរទៅលើសេចក្តីសម្រេចដដែល ដែលនាំឲ្យខាតបង់ពេលវេលាច្រើន និងធ្វើឲ្យសំណុំរឿងរាំងស្ទះ។

**ខ. អានុភាពនៃបណ្តឹងឧទ្ធរណ៍**

ជនត្រូវចោទ ដែលជាប់ឃុំបណ្តោះអាសន្ន ត្រូវបានរក្សាទុកនៅក្នុងពន្ធនាគារ រហូតដល់ផុតរយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ទើបចៅក្រមស៊ើបសួរអាចសម្រេចដោះលែងជនត្រូវចោទឲ្យមាន

សេរីភាពបាន និងមានការយល់ព្រមពីព្រះរាជអាជ្ញា។ ករណីបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីដីកាដោះលែងឲ្យនៅក្រៅឃុំ ឬលើកលែងចោទប្រកាន់ជនត្រូវចោទត្រូវបានរក្សាទុកក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរសម្រេចអំពីបណ្ដឹងឧទ្ធរណ៍[18]។

ការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ពុំនាំឱ្យនីតិវិធីនៃការស៊ើបសួរត្រូវផ្អាកទេ លើកលែងតែបណ្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។ ប៉ុន្តែប្រធានសភាស៊ើបសួរអាចសម្រេចឱ្យផ្អាកនីតិវិធីនៃការស៊ើបសួរបានដែរ ក្នុងករណីនេះ។ សេចក្ដីសម្រេចនេះមិនអាចប្ដឹងតវ៉ាបានឡើយ (មាត្រា២៧៥)។ ក្នុងរឿងឃុំខ្លួនបណ្ដោះអាសន្ន សាលីការរបស់សភាស៊ើបសួរ ត្រូវសម្រេចចេញនៅក្នុងរយៈពេល១៥(ដប់ប្រាំ) ថ្ងៃបន្ទាប់ពីបានទទួលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ បើផុតរយៈពេលនេះ ជនត្រូវចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំ លើកលែងតែក្នុងករណីដែលមានចេញបង្គាប់ឱ្យធ្វើការផ្ទៀងផ្ទាត់ ឬក្នុងករណីមានកាលៈទេសៈដែលមិនអាចមើលឃើញជាមុន ឬមិនអាចជំនះបាននោះ បង្កជាឧបសគ្គមិនឱ្យប្រកាសសាលដីកាបាននៅក្នុងរយៈពេលនេះ[19]។

[18] មាត្រា ២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[19] មាត្រា ២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

# ជំពូកទី ២
# ការប្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចរបស់សាលាជម្រះក្ដីជាន់ទាប

## ផ្នែកទី ១ ៖ សញ្ញាណទូទៅ

សាលក្រម គឺជាសេចក្ដីសម្រេចចុងក្រោយរបស់សាលាដំបូងរាជធានី-ខេត្ត។

តុលាការព្រហ្មទណ្ឌនៃសាលាដំបូងជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌទាំងឡាយ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌ លើកលែងតែមានបទប្បញ្ញត្តិច្បាប់ចែងផ្សេងពីនេះ។ តុលាការព្រហ្មទណ្ឌនៃសាលាដំបូងជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌ ដោយចៅក្រមទោល ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុវលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌ[20]។

សាលាដំបូងជំនុំជម្រះគ្រប់បទល្មើសទាំងអស់ ដូចជា បទឧក្រិដ្ឋ បទមជ្ឈិម បទលហុ។ សាលាដំបូងសម្រេចជាក្រុមសមូហភាពដែលមានចៅក្រម ៣ (បី) រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទង។ សាលាដំបូងសម្រេចជាចៅក្រមទោលចំពោះ បទមជ្ឈិម និងបទលហុ[21]។

ក្នុងរឿងក្ដីព្រហ្មទណ្ឌ សាលាដំបូងត្រូវបានទទួលបណ្ដឹងដោយៈ

-ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ

-ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា

-កំណត់ហេតុស្ដីពីការចូលបង្ហាញខ្លួនភ្លាមដេលធ្វើដោយព្រះរាជអាជ្ញា។

គ្រប់បុគ្គលដែលត្រូវបានបញ្ជូនទៅចំពោះមុខតុលាការតាមនីតិវិធីណាមួយដូចខាងលើនេះ មានឈ្មោះថាជនជាប់ចោទ[22]។

សាលក្រមត្រូវសម្រេចចេញនៅពេលសវនាការ ដែលធ្វើការពិភាក្សាចេញដោយ ឬនៅពេលសវនាការលើកក្រោយ។ នៅក្នុងករណីខាងក្រោយនេះ ប្រធានសវនាការជូនដំណឹងដល់ភាគីទាំងឡាយដែលមានវត្តមាន អំពីថ្ងៃដែលត្រូវប្រកាសសាលក្រម។ តុលាការសម្រេចសេចក្ដីបានតែទៅលើអំពើទាំងឡាយ ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីការបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ កំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម[23]។ នៅក្នុងសាលក្រមតែមួយជាមួយរឿងព្រហ្មទណ្ឌ តុលាការសម្រេចអំពីផលប្រយោជនរដ្ឋប្បវេណី។ តុលាការវិនិច្ឆ័យអំពីភាពអាចទទួលបាននៃការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយសម្រេចអំពីពាក្យប្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទៅ

[20] មាត្រា ២០ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

[21] មាត្រា ២៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[22] មាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[23] មាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

លើជនជាប់ចោទ និងលើអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។ កាលណាតុលាការមិនទាន់អាចសម្រេចបានលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីទេ តុលាការអាចបង្អង់ទៅសវនាការលើកក្រោយ និងអាចសម្រេចឱ្យប្រគល់ប្រាក់បណ្តោះអាសន្ន។ បុគ្គលដែលត្រូវផ្តន្ទាទោសក្នុងបទល្មើសតែមួយជាមួយគ្នានោះ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព។

តុលាការប្រកាសសាលក្រមដែលមានកំណត់ពីពិរុទ្ធភាព និងប្រកាសទោសដែលបានកំណត់ដោយច្បាប់។ បើតុលាការយល់ឃើញថាអំពើមិនមែនជាបទល្មើស ឬ ជនជាប់ចោទមិនមានពិរុទ្ធភាព តុលាការប្រកាសសាលក្រមឱ្យរួចផុតពីបទចោទប្រកាន់។ ក្នុងករណីដែលមានទោសជាប់ពន្ធនាគារ តុលាការអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួន បើសិនជនជាប់ចោទមានវត្តមាននៅសវនាការ ឬដីកាបង្គាប់ឱ្យចាប់ខ្លួនបើសិនជនជាប់ចោទអវត្តមាន[24]។

នៅក្នុងគ្រប់ករណីទាំងអស់ សាលក្រមត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ[25]។ គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ។ ផ្នែកនៃសេចក្តីសម្រេចត្រូវអានដោយសម្លេងខ្លាំងៗ ដោយប្រធានសវនាការ[26]។

តាមរយៈការលើកឡើងខាងលើ តើសាលក្រមព្រហ្មទណ្ឌមានប៉ុន្មានប្រភេទ?

**កថាខណ្ឌទី ១ ៖ ប្រភេទសាលក្រម**

អនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងកំណត់បែងចែកសាលក្រមត្រូវបានគេកំណត់ជាបីប្រភេទសំខាន់ៗ៖

**ក. សាលក្រមចំពោះមុខ**

សាលក្រមចំពោះមុខ គឺជាសាលក្រមដែលជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ។ សាលក្រមនៅតែជាសាលក្រមចំពោះមុខដដែល ទោះបីជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ[27]។ នៅតែជាសាលក្រមចំពោះមុខដែរ កាលណាជនជាប់ទោទត្រូវបានសួរចម្លើយនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣០៩ "ប្រសិនបើដោយមូលហេតុស្ថានភាព ឬ ដោយមូលហេតុធ្ងន់ធ្ងរ ដែលឱ្យជនជាប់ចោទ មិនអាចចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការបានទេ ប្រធានសវនាការអាចបង្គាប់ឱ្យសួរជនជាប់ចោទ នៅទីកន្លែងដែលជននោះនៅ។

អានុភាននៃសាលក្រមចំពោះមុខនេះ មិនត្រូវឱ្យដំណឹងដល់ជនជាប់ចោទនោះទេ។ សាលក្រមចំពោះមុខនេះអាចប្តឹងឧទ្ធរណ៍បាន។

---

[24] មាត្រា ៣៥០, ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[25] មាត្រា ៣១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[26] មាត្រា ៣៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[27] មាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី គឺជាសាលក្រមដែលចេញចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីចូលបង្ហាញខ្លួននៅពេលសវនាការ ឬ មានអ្នកតំណាងដោយត្រឹមត្រូវនោះ សាលក្រមត្រូវតែជាសាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីនេះ[28]។

អានុភាពនៃសាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី មិនត្រូវជូនដំណឹងដល់សាមីខ្លួនទេ។ សាលក្រមនេះអាចប្ដឹងឧទ្ធរណ៍បាន។

សាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺជាសាលក្រមដែលបុគ្គលដែលកោះហៅក្នុងឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណីចូលបង្ហាញខ្លួននៅពេលសវនាការ ឬ ក៏មានអ្នកតំណាងដោយត្រឹមត្រូវ សាលក្រមនោះជាសាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី[29]។

អានុភាពនៃសាលក្រមចំពោះមុខនេះ មិនត្រូវឱ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ។ សាលក្រមនេះអាចត្រូវប្ដឹងឧទ្ធរណ៍បាន។

**ខ. សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ**

សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ គឺជាសាលក្រមដែលជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែ សាមីខ្លួនបានដឹងអំពីការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ បានដឹងពីការកោះហៅហើយនោះ សាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ។

សាលក្រមដែលចាត់ទុកថាចំពោះមុខនេះ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទ។ សាលក្រមនេះ អាចត្រូវប្ដឹងឧទ្ធរណ៍បាន។

**គ. សាលក្រមកំបាំងមុខ**

សាលក្រមកំបាំងមុខជនជាប់ចោទ គឺជាសាលក្រមដែលជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយនិងប្រសិនបើគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាមីខ្លួនដឹងពីការបញ្ជូនទៅជំនុំជម្រះ ឬ បានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទនេះ។ សាលក្រមនេះអាចប្ដឹងទាស់បាន[30]។

សាលក្រមកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី គឺជាសាលក្រមដែលដើមបណ្ដឹងរដ្ឋប្បវេណីមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ សាលក្រមត្រូវប្រកាស

---

[28] មាត្រា ៣៦៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[29] មាត្រា ៣៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[30] មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដោយកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខនេះ ត្រូវជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមនេះអាចប្តឹងទាស់បាន[31]។

សាលក្រមកំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺជាសាលក្រមដែលបុគ្គលកោះហៅក្នុងឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនចូលបង្ហាញខ្លួននៅសវនាការ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ សាលក្រមត្រូវសម្រេចដោយកំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមនកំបាំងមុខនេះត្រូវឱ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមនេះ អាចប្តឹងទាស់បាន[32]។

## ផ្នែកទី ២៖ ការប្តឹងតវ៉ាចំពោះសាលក្រមរបស់សាលាដំបូងរាជធានី-ខេត្ត

ការសិក្សាអំពីការប្តឹងតវ៉ាចំពោះសាលក្រមរបស់សាលាដំបូងរាជធានី-ខេត្ត យើងខ្ញុំបានធ្វើការសិក្សាលើបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ កថាខណ្ឌទី១ និងកថាខណ្ឌទី២ បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម។

### កថាខណ្ឌទី ១៖ បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ

បណ្តឹងទាស់ គឺជាបណ្តឹងដែលធ្វើប្រឆាំងទៅនឹងសាលក្រមកំបាំងមុខ ក្រោយពីសាលក្រមត្រូវបានប្រកាស ភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌអាចប្តឹងទាស់បាន ក្នុងករណីដែលសាលក្រមនោះត្រូវបានសម្រេចដោយកំបាំងមុខខ្លួន។

#### ក. បុគ្គលដែលមានសិទ្ធិធ្វើបណ្តឹងទាស់

#### ១-ពិរុទ្ធជន

ក្នុងករណីដែលសាលក្រមត្រូវបានប្រកាសដោយកំបាំងមុខខ្លួន ពិរុទ្ធជនអាចធ្វើបណ្តឹងទាស់បានតាមមាត្រា៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ យោងតាមមាត្រា៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលក្រមមួយ គឺជាសាលក្រមកំបាំងមុខ ក្នុងករណីដែលជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការ ហើយគ្មានភស្តុតាងបង្ហាញឱ្យឃើញថា សាមីខ្លួនដឹងពីការបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ។ តាមន័យនេះ ប្រសិនបើជនជាប់ចោទអវត្តមាននាពេលសវនាការដែលធ្វើការពិភាក្សាដេញដោលហើយតុលាការពុំមានភស្តុតាងណាបញ្ជាក់ថា ជនជាប់ចោទបានទទួលដំណឹងពីការបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅទេ សាលក្រមដែលប្រកាសដោយតុលាការគឺជាសាលក្រមកំបាំងមុខ ទោះបីជានៅពេលសវនាការប្រកាសសាលក្រម ជនជាប់ចោទមានវត្តមានក៏ដោយ។ ផ្ទុយទៅវិញ ប្រសិនបើជនជាប់ចោទមានវត្តមាននាពេលសវនាការដែលធ្វើការពិភាក្សាដេញដោល សាលក្រមគឺជាសាលក្រមចំពោះមុខទោះបីជានៅពេលប្រកាសសាលក្រម ជនជាប់ចោទអវត្តមានក៏ដោយ។ ក្នុងករណីបែបនេះ សាលក្រមត្រូវ

[31] មាត្រា ៣៦៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[32] មាត្រា ៣៦៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ចាត់ទុកជាចំពោះមុខ ហើយត្រូវជូនដំណឹងទោជនជាប់ចោទ តាមមាត្រា៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយហេតុ ទោះបីជាសាលក្រមត្រូវបានប្រកាសដោយកំបាំងមុខជនជាប់ចោទក៏ដោយ តែជនជាប់ចោទប្រាកដជាបានដឹងពីថ្ងៃដែលត្រូវប្រកាសសាលក្រម ព្រោះថានៅពេលសវនាការដែលធ្វើការពិភាក្សាដេញដោល ប្រធានសវនាការបានជូនដំណឹងដល់ភាគីដែលមានវត្តមាន ពីថ្ងៃដែលត្រូវប្រកាសសាលក្រមរួចហើយ (មាត្រា ៣៩៧)។

ពិរុទ្ធជន (ជនដែលត្រូវបានតុលាការផ្តន្ទាទោស) អាចប្តឹងទាស់នឹងសាលក្រមទាំងមូល ឬក៏កម្រិតការប្តឹងទាស់ ត្រឹមតែសេចក្តីសម្រេចផ្តន្ទាទោស ឬសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី (មាត្រា៣៦៩)។

**២-ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចប្តឹងទាស់នឹងសាលក្រមដែលសម្រេចកំបាំងមុខខ្លួនបាន តាមមាត្រា៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បណ្តឹងទាស់នេះត្រូវកំណត់ទៅលើសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ។

**ខ. រយៈពេលធ្វើបណ្តឹងទាស់**

រយៈពេលសម្រាប់ធ្វើបណ្តឹងទាស់របស់ពិរុទ្ធជន បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ផ្តើមគិត ៖

-ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ

-ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឱ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ។ ពិរុទ្ធជនត្រូវចាត់ទុកថា បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិដែលមានចែងកក្នុងគន្ថីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ)[33] ។

រយៈពេលបណ្តឹងទាស់ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី បណ្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតពី ៖

-ថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ

[33] មាត្រា ៣៦៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម
(មាត្រា២៩៧ មាត្រា៣៧២ មាត្រា៣៦៨ និងមាត្រា៣៨២) នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឱ្យដល់ដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ។ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រមកក្នុងករណីដែលនីតិវិធីនៃការឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិដែលមានចែងកក្នុងគន្លឹទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ)[34]

### គ. ទម្រង់ និងភាពដែលអាចទទួលយកបាននៃបណ្ដឹងទាស់

បណ្ដឹងទាស់ត្រូវធ្វើដោយពាក្យប្ដឹងជាលាយលក្ខណ៍អក្សរ:[35]

នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ នៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ឬ នៅចំពោះមុខប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី។ មេធាវីត្រូវតែមានលិខិតអនុញ្ញាតឱ្យ ធ្វើបណ្ដឹងទាស់។ ប៉ុន្តែ ពិរុទ្ធជនជាអនីតិជន អាចត្រូវតំណាងដោយឪពុក ម្ដាយ ឬអ្នកអាណាព្យាបាល។ ក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

កាលណាបានទទួលពាក្យប្ដឹងទាស់ ព្រះរាជអាជ្ញា អង្គភាពនគរបាល និងកងរាជអាវុធហត្ថ ព្រមទាំងប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន បញ្ជូនបណ្ដឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែលប្រកាសសាលក្រម។

កាលណាអ្នកប្ដឹងទាស់មិនចេះចុះហត្ថលេខាទេ អ្នកប្ដឹងទាស់នេះត្រូវផ្ដិតម្រាមដៃ។

ករណីដែលដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ធ្វើបណ្ដឹងទាស់ បណ្ដឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់។ អ្នកតំណាង ត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្ដឹងទាស់។ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចប្ដឹងទាស់នឹងសាលក្រម ដែលសម្រេចដោយកំបាំងមុខខ្លួនបានដែរ។ បណ្ដឹងទាស់នេះ ត្រូវកំណត់ទៅលើសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ[36]។

---

[34] មាត្រា ៣៧២ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម

(មាត្រា២៩៧ មាត្រា៣៧២ មាត្រា៣៦៨ និងមាត្រា៣៨២) នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[35] មាត្រា ៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[36] មាត្រា ៣៧២ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម

(មាត្រា២៩៧ មាត្រា៣៧២ មាត្រា៣៦៨ និងមាត្រា៣៨២) នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ឃ. អានុភាពនៃបណ្តឹងទាស់**

នៅពេលដែលមានពាក្យបណ្តឹងទាស់ត្រឹមត្រូវ សំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះដោយតុលាការដដែល (មាត្រា៣៧១) ដោយភាគីទាំងអស់នឹងត្រូវបានកោះហៅតាមគំនិតផ្តើមរបស់ព្រះរាជអាជ្ញា។ ក្រោយពីបានពិនិត្យមើលភាពអាចទទួលបាននៃបណ្តឹងទាស់នេះ តុលាការសម្រេចលើអង្គសេចក្តី ជាថ្មីម្តងទៀត។

កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើសាលក្រមទាំងមូល សាលក្រមនេះត្រូវទុកជាអាសារបង់ ការអនុវត្តសាលក្រមត្រូវព្យួរ។ ប៉ុន្តែ ដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាព។ តុលាការនៅតែមានសមត្ថកិច្ចដើម្បីសម្រេចអំពីការដោះលែងជនជាប់ចោទឱ្យមានសេរីភាពវិញ។

កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី មានតែសេចក្តីសម្រេចផ្នែកនេះប៉ុណ្ណោះ ដែលត្រូវទុកជាអាសារបង់ ការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីត្រូវព្យួរ។

សេចក្តីសម្រេចរបស់តុលាការអាចជា សាលក្រមលើកចោលបណ្តឹងទាស់ ដោយសារតែបណ្តឹងទាស់មិនអាចទទួលបាន។ បណ្តឹងទាស់មិនអាចទទួលបាន ដោយសារតែអ្នកដាក់ពាក្យប្តឹងទាស់ជាជនដែលពុំមានសិទ្ធិប្តឹងទាស់ ឬដោយសារតែការដាក់ពាក្យប្តឹងទាស់ធ្វើឡើងផុតរយៈពេលដែលច្បាប់កំណត់។

ករណីសហព័ទ្ធរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ពាក្យប្តឹងទាស់ ជំនួសឱ្យសហព័ទ្ធរបស់ខ្លួនដោយពុំមានលិខិតប្រគល់សិទ្ធិ។

ករណីពិរុទ្ធជនដាក់ពាក្យប្តឹងទាស់ក្នុងរយៈពេល លើសពី ១៥ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹងពីសាលក្រមកំបាំងមុខ។

ករណីដែលដែលអ្នកប្តឹងទាស់ដែលកោះហៅដោយត្រឹមត្រូវ ហើយមិនចូលបង្ហាញខ្លួននៅបេលសវនាការទេ តុលាការប្រកាសថាបណ្តឹងទាស់ទុកជាឯកសារឥតបានការ។ សាលក្រមដែលគេប្តឹងទាស់មិនអាចត្រូវកែប្រែទេ។ សាលក្រមនេះមានអានុភាពទាំងស្រុងចំពោះភាគីទាំងអស់។ អ្នកប្តឹងទាស់នៅមានលទ្ធភាពប្តឹងឧទ្ធរណ៍នៅក្នុងលក្ខខណ្ឌដែលលមានចែងនៅមាត្រា ៣៨២ (រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី) ។

**កថាខណ្ឌទី ១ ៖ បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម**

បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម គឺជាបណ្តឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់ មានន័យថាប្តឹងទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ច ដើម្បីសម្រេចអំពីបណ្តឹងឧទ្ធរណ៍ដែលធ្វើប្រឆាំង នឹងសេចក្តីសម្រេចរបស់តុលាការជាន់ដំបូង ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួនក្នុងរឿងព្រហ្មទណ្ឌ។ មានន័យថា ប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមចុងក្រោយនៃការជំនុំជម្រះរបស់សាលាដំបូងដែលទាមទារឲ្យ សាលាឧទ្ធរណ៍វិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ ភាពមិនត្រឹមត្រូវនៃសាលក្រមរបស់

សាលាដំបូង។ បើបុគ្គលណា មួយដែលមិនសុខចិត្តទៅនឹងសេចក្តីសម្រេចនោះ អាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍បានមុនពេលដែលសាលក្រមនោះចូលជាស្ថាពរ ប្រសិនបើសាលក្រមចូលជាស្ថាពរមិនអាចប្តឹងឧទ្ធរណ៍បានទេ។

### ក.បុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម

បុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម របស់ចៅក្រមជំនុំជម្រះបានរួមមាន[37]៖

- ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ពិរុទ្ធជន
- ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី

ចំណុចពិសេសមួយនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានបើកសិទ្ធិឱ្យបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះបាន ក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ។

### ខ. រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម

- រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា

ការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវតែធ្វើក្នុងរយៈពេល ១(មួយ) ខែ។ ការប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវតែធ្វើក្នុងរយៈពេល ៣(បី) ខែ។ រយៈពេលប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាផ្តើមគិតពីពេលប្រកាសសាលក្រម[38]។

- រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ការប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវតែធ្វើក្នុងរយៈពេល ១(មួយ) ខែ។ បើទោះបីសាលក្រមនេះ ជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពី ពេលប្រកាសសាលក្រមនោះ។ កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកជាចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឱ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ។ មានន័យថាច្បាប់បានកំណត់យ៉ាងច្បាស់ថាបើទោះបីការជូនដំណឹងអំពីសាលក្រមចាត់ទុកថាចំពោះមុខ ធ្វើ

[37] មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[38] មាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

តាមវិធីណាមួយក៏ដោយ ក៏បណ្តឹងឧទ្ធរណ៍នៅតែមានអានុភាពក្នុងការអនុវត្ត។ កាលណាសាលក្រមនោះជាសាលក្រមកំបាំងមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលផុតកំណត់ប្តឹងទាស់[39]។

- រយៈពេលបន្ថែមសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍ៈ បណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុក្នុងករណីដែលភាគីណាមួយបានប្តឹងឧទ្ធរណ៍នៅក្នុង រយៈពេលខាងលើនេះ ភាគីដទៃទៀតមានរយៈពេលបន្ថែម ៧ (ប្រាំពីរ)ថ្ងៃ ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុ ហើយរយៈពេលបន្ថែមនេះផ្តើមគិតពីការផុតរយៈពេលធម្មតា[40]។

- រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងពិរុទ្ធជនក្នុងករណីមានការឃុំខ្លួនក្នុងរឿងឃុំខ្លួនការប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើដោយព្រះរាជអាជ្ញានៅក្នុងរយៈពេល ៤៨(សែសិបប្រាំបី) ម៉ោង ករណីដែលពិរុទ្ធជននៅក្នុងឃុំ និងដោយពិរុទ្ធជនក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ ករណីដែលពីរុទ្ធជននៅក្រៅឃុំ ហើយរយៈពេលនេះ ផ្តើមគិតពីថ្ងៃដែលតុលាការសម្រេចពីការឃុំខ្លួន[41]។

- បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមចាត់របៀប

កាលណាតុលាការ ចេញសាលក្រមចាត់របៀប បណ្តឹងឧទ្ធរណ៍អាចត្រូវទទួលបានភ្លាម ប្រសិនបើសាលក្រមនេះបញ្ចប់នីតិវិធី។ ក្នុងករណីផ្ទុយពីនេះ សាលក្រមចាត់របៀបនឹងអាចត្រូវដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែធ្វើព្រមគ្នាជាមួយសាលក្រមលើអង្គសេចក្តី។ សាលក្រមចាត់របៀប គឺជាសាលក្រមដែលបានបើកការសួរដេញដោលរួចហើយ តែពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់ ឬ មុនពេលសួរដេញដោល មានអញ្ញត្រកម្មបានកើតឡើង ដែលមិនអាចឲ្យចៅក្រមសម្រេចដល់ អង្គសេចក្តីបាន។ សាលក្រមចាត់របៀប មានលក្ខណៈប្លែកគ្នាបន្តិចជាមួយសាលក្រមអង្គសេចក្តី ត្រង់ផ្នែកសំអាងហេតុ និងផ្នែកនៃសេចក្តីសម្រេច[42]។

### គ. ទម្រង់នៃការប្រកាសប្តឹងឧទ្ធរណ៍ចំពោះសាលក្រម

គ.១ ទីកន្លែងដាក់ពាក្យបណ្តឹង

ករណីដែលមាន ការប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាមពាក្យប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។ ក្រឡាបញ្ជីត្រូវចុះលិខិតប្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។ លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអគ្គព្រះរាជអាជ្ញា។

---

[39] មាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម

(មាត្រា២៤៧ មាត្រា៣៧២ មាត្រា៣៦៨ និងមាត្រា៣៨២) នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[40] មាត្រា ៣៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[41] មាត្រា ៣៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[42] មាត្រា ៣៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ច្បាប់មិនបានកំណត់ចំពោះមាត្រាណាមួយឲ្យបានជាក់លាក់ទាក់ទងទៅ និងកិច្ចការក្រឡាបញ្ជីដែលត្រូវបញ្ជូនសំណុំរឿងទៅសាលាដំបូង និងការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ក៏ច្បាប់មិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ផងដែរ។ ប៉ុន្តែឆ្លងការតាមការសិក្សាពីទ្រឹស្តីបញ្ជាក់ថាៈ នៅពេលដែលអគ្គព្រះរាជអាជ្ញាប្រកាសប្ដឹងឧទ្ធរណ៍រួចហើយ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ត្រូវថតចម្លងពាក្យបណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ផ្ញើទៅក្រឡាបញ្ជីនៃសាលាដំបូង។ នៅពេលដែលក្រឡាបញ្ជីនៃតុលាការជាន់ដំបូង បានទទួលពាក្យបណ្ដឹងឧទ្ធរណ៍ របស់អគ្គព្រះរាជអាជ្ញាហើយ ត្រូវរៀបចំធ្វើសេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍នោះ ដោយដាក់ក្នុងសំណុំរឿងមួយច្បាប់ និងធ្វើការរៀបចំសំណុំរឿងទាំងមូលផ្ញើទៅសាលាឧទ្ធរណ៍។

ចំពោះបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើនៅការិយាល័យនៃតុលាការដែលបានប្រកាសសាលក្រម។

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី ហើយមេធាវីត្រូវតែមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្ដឹងឧទ្ធរណ៍។ ចំពោះពិរុទ្ធជនជាអនីតិជនអាចតំណាងដោយ ឪពុកម្ដាយ ឬ អ្នកអាណាព្យាបាលដោយមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចតំណាងដោយមេធាវីសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ហើយអ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្ដឹងឧទ្ធរណ៍ផងដែរ។ ក្រឡាបញ្ជីចុះបណ្ដឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅក្នុងបញ្ជីនៃតុលាការ។ លិខិតប្ដឹងឧទ្ធរណ៍ត្រូវតែចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្ដឹងឧទ្ធរណ៍ ឬអ្នកតំណាង។ លិខិតប្រគល់សិទ្ធិត្រូវភ្ជាប់ជាមួយនឹងលិខិតប្ដឹងឧទ្ធរណ៍។ កាលណាអ្នកប្ដឹងឧទ្ធរណ៍ មិនចេះចុះហត្ថលេខា អ្នកប្ដឹងឧទ្ធរណ៍នេះត្រូវផ្ដិតម្រាមដៃ។

ការប្រកាសបណ្ដឹងឧទ្ធរណ៍ដោយពិរុទ្ធជនដែលនៅជាប់ឃុំ អាចសំដែងឆន្ទៈរបស់ខ្លួនក្នុងការប្ដឹងឧទ្ធរណ៍នៅមុខប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។ ពិរុទ្ធជននេះបំពេញពាក្យប្ដឹងឧទ្ធរណ៍ ដែលត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ហើយពាក្យប្ដឹងឧទ្ធរណ៍ ត្រូវចុះបញ្ជីដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួននៅលើបញ្ជីពិសេស។ ពិរិទ្ធជនចុះហត្ថលេខានៅរឹមនៃបញ្ជីនេះ។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ត្រូវបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍នៅក្នុងរយៈពេលដ៏ខ្លីបំផុតទៅក្រឡាបញ្ជីដែលត្រូវចុះនិទ្ទេសអំពីពាក្យប្ដឹងឧទ្ធរណ៍នេះ នៅលើបញ្ជីប្ដឹងឧទ្ធរណ៍នៃតុលាការជាន់ដំបូង។

គ.២ ការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍

ក្រោយពេលមានបណ្ដឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងត្រូវរៀបចំធ្វើសេចក្ដីចម្លងសំណុំលិខិតដោយបានបញ្ជាក់ត្រឹមត្រូវ តាមច្បាប់ដើមដោយក្រឡាបញ្ជី និងបញ្ជូនទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ក្នុងរយៈពេលដ៏ខ្លីបំផុត ជូនទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍នូវៈ

- សំណុំរឿងនៃនីតិវិធី
- សេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍នីមួយៗដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម
- សេចក្តីចម្លងនៃសាលក្រមដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។

ក្នុងករណី មានបណ្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការស្តីពី ការឃុំខ្លួនជនជាប់ចោទ សំណុំរឿងត្រូវបញ្ជូនក្នុងរយៈពេល ១០(ដប់) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃប្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជំនះបាន ដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូនទៅសាលាឧទ្ធរណ៍។

**ឃ. អានុភាពនៃបណ្តឹងឧទ្ធរណ៍**

នៅក្នុងរយៈពេលប្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបង្អង់សិន។ ប៉ុន្តែជនជាប់ចោទ ដែលជាប់ឃុំ ដែលបានចូលបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ត្រូវនៅក្នុងពន្ធនាគារនៅក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងនៅក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ នោះជនជាប់ចោទត្រូវនៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេច។ ក្នុងករណីដែលតុលាការជាន់ដំបូងបានសម្រេចឲ្យរួចខ្លួន ឬ បានផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេលតិចជាង ឬស្មើនឹងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញាអាចយល់ព្រមដោះលែង ជនជាប់ចោទឲ្យមានសេរីភាព មុនពេលផុតកំណត់នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍។ រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាមិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ។

# ជំពូកទី ៣
# ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់សាលាជម្រះក្តីជាន់ខ្ពស់

## ផ្នែកទី ១ ៖ ការប្តឹងតវ៉ាចំពោះសាលដីកាសាលាឧទ្ធរណ៍

ជាគោលការណ៍បន្ទាប់ពីការប្រកាស អំពីសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍រួចហើយ ភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ប្រសិនបើមិនសុខចិត្តមានសិទ្ធិធ្វើបណ្តឹងប្រឆាំងទៅនឹងសេចក្តីសម្រេច (សាលដីកាសាលាឧទ្ធរណ៍) នោះបាន ដែលការធ្វើបណ្តឹងប្រឆាំងទៅនឹងសាលដីកាសាលាឧទ្ធរណ៍នោះរួមមាន៖

### កថាខណ្ឌទី ១ ៖ បណ្តឹងទាស់ចំពោះសាលដីកាចេញដោយកំបាំងមុខ

បណ្តឹងទាស់ចំពោះសាលដីកាចេញដោយកំបាំងមុខ គឺជាការប្តឹងប្រឆាំងទៅនឹងសាលដីកាដែលបានចេញកំបាំងមុខពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ ការធ្វើបណ្តឹងទាស់នេះគឺមានលក្ខណៈស្រដៀងគ្នាទៅនឹងបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខផងដែរ។

#### ក.បុគ្គលដែលអាចធ្វើបណ្តឹងទាស់

យោងតាមមាត្រា៤០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រភេទនៃសាលដីកា គឺសាលដីកាប្រកាសដោយសាលាឧទ្ធរណ៍ជាសាលដីកាចំពោះមុខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ ឬ ជាសាលដីកាកំបាំងមុខ តាមការវែកញែកដែលអនុវត្តចំសាលក្រមដែលប្រកាសដោយតុលាការជាន់ដំបូង។ តាមន័យនេះការធ្វើបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ដូចគ្នាទៅនឹងសាលដីកាកំបាំងមុខដែរ។

##### ១.ពិរុទ្ធជន

អាចប្តឹងទាស់នឹងសាលដីកាដែលសម្រេចដោយកំបាំងមុខខ្លួន[43]។ ប្រសិនបើពិរុទ្ធជនមិនបានចូលបង្ហាញខ្លួននៅពេលសវនាការ ហើយប្រសិនបើគ្មានភស្តុតាងបង្ហាញឱ្យឃើញថាពិរុទ្ធជនដឹងពីការបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីដីកាកោះហៅទេនោះ សាលដីកាត្រូវប្រកាសដោយកំបាំងមុខពិរុទ្ធជន។

##### ២.ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ក៏អាចប្តឹងទាស់នឹងសាលដីកាកំបាំងមុខខ្លួនបានផងដែរ។ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចប្តឹងទាស់នឹងសាលដីកាដែលសម្រេចកំបាំងមុខខ្លួនបាន តាមមាត្រា៤១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បណ្តឹងទាស់នេះត្រូវកំណត់ទៅលើសម្រេចផ្នែករដ្ឋប្បវេណីនៃសាលដីកាតែប៉ុណ្ណោះ។

#### ខ. រយៈពេលធ្វើបណ្តឹងទាស់

បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ផ្តើមគិត

[43] មាត្រា ៣៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-ពីថ្ងៃជូនដំណឹងអំពីសាលដីកាកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលដីកានេះមិនបានប្រគល់ឱ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ[44]។

-ពីថ្ងៃជូនដំណឹងអំពីសាលដីកាកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលដីកានេះ មិនបានប្រគល់ឱ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ[45]។

### គ. ទម្រង់ និងភាពដែលអាចទទួលយកបាននៃបណ្តឹងទាស់

បណ្តឹងទាស់អាចធ្វើតាមពាក្យប្តឹងលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃសាលឧទ្ធរណ៍ដែលបានសម្រេចចេញសាលដីកា ឬតាមពាក្យប្តឹងជាលាយលក្ខណ៍អក្សរនៅចំពោះមុខអគ្គព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន[46]។

ពិរុទ្ធជនអាចត្រូវតំណាងដោយមេធាវី។ មេធាវីត្រូវតែមានលិខិតអនុញ្ញាតឱ្យធ្វើបណ្តឹងទាស់។ ប៉ុន្តែពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយឪពុក ម្តាយ ឬអ្នកអាណាព្យាបាល។ ក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

កាលណាបានទទួលពាក្យប្តឹងទាស់ អគ្គព្រះរាជអាជ្ញា អង្គភាពនគរបាល និងកងរាជអាវុធហត្ថ ព្រមទាំងប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន បញ្ជូនសំណុំរឿងនោះភ្លាមទៅក្រឡាបញ្ជីនៃសាលឧទ្ធរណ៍រដែលប្រកាសសាលដីកា។ កាលណាអ្នកប្តឹងទាស់មិនចេះចុះហត្ថលេខាទេ អ្នកប្តឹងទាស់នេះត្រូវផ្តិតម្រាមដៃ។

ករណីដែលដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ធ្វើបណ្តឹងទាស់ បណ្តឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃសាលឧទ្ធរណ៍ដែលបានប្រកាសសាលដីកា។ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចត្រូវតំណាងដោយមេធាវីសហព័ទ្ធ ឬញាតិលោហិតផ្ទាល់។ អ្នកតំណាង ត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្តឹងទាស់[47]។

### ឃ. អានុភាពនៃបណ្តឹងទាស់

នៅពេលដែលមានពាក្យបណ្តឹងទាស់ត្រឹមត្រូវ សំណុំរឿងត្រូវបានលើកយកមជំនុំជម្រះដោយសាលាឧទ្ធរណ៍ដដែល (មាត្រា៤១៥) ដោយភាគីទាំងអស់នឹងត្រូវបានកោះហៅតាមគំនិតផ្តើមរបស់

[44] មាត្រា ៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[45] មាត្រា ៤១៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[46] មាត្រា ៤១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[47] មាត្រា ៤១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

អគ្គព្រះរាជអាជ្ញា។ ក្រោយពីបានពិនិត្យមើលភាពអាចទទួលបាននៃបណ្តឹងទាស់នេះ តុលាការសម្រេចលើអង្គសេចក្តី ជាថ្មីម្តងទៀត។

កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើសាលដីកាទាំងមូល សាលដីកានេះត្រូវទុកជាអាសារបង់ ការអនុវត្តសាលដីកាត្រូវព្យួរ។ ប៉ុន្តែ ដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាព។ សាលាឧទ្ធរណ៍នៅតែមានសមត្ថកិច្ចដើម្បីសម្រេចអំពីការដោះលែងឱ្យមានសេរីភាពវិញ។

កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី នោះតែសេចក្តីសម្រេចផ្នែកនេះប៉ុណ្ណោះ ដែលត្រូវទុកជាអាសារបង់ ការអនុវត្តត្រូវព្យួរ។

ចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍អាចជាសាលដីកាលើកចោលបណ្តឹងទាស់ ដោយសារតែបណ្តឹងទាស់មិនអាចទទួលបាន។ បណ្តឹងទាស់មិនអាចទទួលបាន ដោយសារតែអ្នកដាក់ពាក្យប្តឹងទាស់ជាជនដែលពុំមានសិទ្ធិប្តឹងទាស់ ឬដោយសារតែការដាក់ពាក្យប្តឹងទាស់ធ្វើឡើងផុតរយៈពេលដែលច្បាប់កំណត់។

ករណីដែលដែលអ្នកប្តឹងទាស់ដែលកោះហៅដោយត្រឹមត្រូវ ហើយមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ តុលាការប្រកាសថាបណ្តឹងទាស់ត្រូវទុកជាអសារឥតការ។ សាលដីកាដែលគេប្តឹងទាស់ មិនអាចត្រូវកែប្រែទេ។ សាលដីកានេះមានអានុភាពទាំងស្រុងចំពោះគូភាគី។ ប៉ុន្តែពិរុទ្ធ នៅមានលទ្ធភាពអាចប្តឹងតវ៉ាទៅតុលាការកំពូលបាន។

**កថាខណ្ឌទី ១៖ បណ្តឹងសាទុក្ខ**

តុលាការកំពូលមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ[48] ដែលជាតុលាការថ្នាក់ខ្ពស់ជាងគេនៅទូទាំងប្រទេស ហើយមានសត្តកិច្ចដោះស្រាយរឿងក្តីដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមការកំណត់របស់ច្បាប់។ តុលាការកំពូលជាតុលាការដោះស្រាយចុងក្រោយបំផុតដោយមានការទទួលពាក្យបណ្តឹងសាទុក្ខដែលមិនសុខចិត្ត នឹងសាលដីកាសាលាឧទ្ធរណ៍។ ការប្តឹងសាទុក្ខទៅតុលាការកំពូលចេញជាលទ្ធផលក្នុងការផ្ទេរសមត្ថកិច្ច ពិនិត្យឡើងវិញអំពីអង្គច្បាប់ទាំងអស់នៅក្នុងសាលដីកាសាលាឧទ្ធរណ៍ ដែលជាគោលការណ៍ តុលាការកំពូលសម្រេចសេចក្តីតែលើអង្គច្បាប់ប៉ុណ្ណោះ មិនសម្រេចសេចក្តីលើអង្គហេតុទេ មានន័យថា តុលាការកំពូលមិនពិនិត្យ ឬសើរើអង្គហេតុដែលកំណត់ដោយសាលាឧទ្ធរណ៍រួចហើយទេ ប៉ុន្តែតុលាការពិនិត្យមើលថា តើសាលាឧទ្ធរណ៍បានអនុវត្តច្បាប់ត្រឹមត្រូវដែរឬទេ ទៅតាមអង្គហេតុដែលបានរកឃើញនោះ។

បណ្តឹងសាទុក្ខ អាចធ្វើឡើងប្រឆាំងនឹងសាលដីកានៃសភាស៊ើបសួរ ដោយគិតបញ្ចូលទាំងរឿងបត្យាប័ន ព្រមទាំងសាលដីកាដែលសម្រេចជាសមត្ថកិច្ចចុងក្រោយដោយសភាព្រហ្មទណ្ឌនៃ

[48] មាត្រា ៥៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

សាលាឧទ្ធរណ៍ អាចត្រូវប្តឹងសាទុក្ខបាន។ សភាព្រហ្មទណ្ឌនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខ ចំពោះសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន[49]។

**ក.បុគ្គលដែលអាចធ្វើបណ្តឹងសាទុក្ខ**

យោងតាមមាត្រា៤១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងសាទុក្ខអាចត្រូវធ្វើដោយៈ

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ជនជាប់ចោទ ឬពិរុទ្ធជន

-បុគ្គលដែលត្រូវគេទាមទារក្នុងករណីនៃនីតិវិធីបត្យាប័ន

-ដើមបណ្តឹងរដ្ឋប្បវេណី

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

**ខ.មូលហេតុនៃបណ្តឹងសាទុក្ខ**

ជាលក្ខខណ្ឌដែលកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវ ខុសប្លែកពីការប្តឹងទាស់ និងការប្តឹងឧទ្ធរណ៍ដែលបានរៀបរាប់ពីខាងលើរួចហើយនោះ ការធ្វើបណ្តឹងសាទុក្ខត្រូវមានមូលហេតុណាមួយដូចដែលមានចែងនៅក្នុងមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឬនិយាយម្យ៉ាងទៀតថាសភាព្រហ្មទណ្ឌនៃតុលាកំពូលអាចបដិសេធសេចក្តីសម្រេចដែលត្រូវគេប្តឹងសាទុក្ខ តែក្នុងករណីខាងក្រោមតែប៉ុណ្ណោះ ៖

-សមាសភាពមិនស្របច្បាប់នៃតុលាការ

-អសមត្ថកិច្ចនៃតុលាការ

-ការរំលោភអំណាច

-ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់

-ការបំពាន ឬភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិត្រូវទុកជាមោឃៈ

-ការមិនបានសម្រេចលើពាក្យសុំរបស់អយ្យការ ឬភាគីកាលណាពាក្យប្តឹងសុំនេះធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់

-ការបំភ្លៃអង្គហេតុ

-គ្មានសំអាងហេតុ

-ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេច

[49] មាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

ការកំណត់អំពីមូលហេតុជាក់លាក់នៃបណ្តឹងសាទុក្ខ គឺដោយសារតែតុលាការកំពូលជាចៅក្រមអង្គច្បាប់មិនមែនជាចៅក្រមអង្គហេតុឡើយ។ យោងតាមមាត្រា ៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់លាស់ថា "តុលាការកំពូលត្រូវសម្រេចលើបញ្ហាច្បាប់ដែលលើកឡើងដោយអ្នកប្តឹងសាទុក្ខ និងដែលមានរៀបរាប់នៅក្នុងសារណា។

**គ.រយៈពេលធ្វើបណ្តឹងសាទុក្ខ**

បណ្តឹងសាទុក្ខ ត្រូវធ្វើក្នុងរយៈពេលដូចតទៅ:

- ១ (មួយ) ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។
- ១៥ (ដប់ប្រាំ) ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍។
- ៥ (ប្រាំ) ថ្ងៃ ចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន។

កាលណាសាលដីកាដែលប្តឹងសាទុក្ខ ជាសាលដីកាចំពោះមុខ រយៈពេលត្រូវផ្តើមគិតពីការប្រកាសសាលដីកា។ កាលណាសាលដីកាដែលប្តឹងសាទុក្ខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ រយៈពេលត្រូវផ្តើមពីការឱ្យដំណឹង។ កាលណាសាលដីកាសម្រេចដោយកំបាំងមុខ រយៈពេលត្រូវផ្តើមគិតពីការផុតរយៈពេលប្តឹងទាស់[50]។

ចំពោះសាលដីកាចាត់របៀប រយៈពេលនៃបណ្តឹងសាទុក្ខ ត្រូវទទួលបានភ្លាមប្រសិនបើសាលដីកានេះបញ្ចប់នីតិវិធី។ ក្នុងករណីផ្ទុយពីនេះ សាលដីកាចាត់របៀបអាចដាក់ជូនតុលាការកំពូលពិនិត្យជាមួយគ្នានឹងសាលដីកាលើអង្គសេចក្តីតែប៉ុណ្ណោះ[51]។

**ឃ.ទម្រង់នៃការប្រកាសបណ្តឹងសាទុក្ខ**

**ឃ.១.ទីកន្លែងដាក់ពាក្យបណ្តឹង**

ការប្តឹងសាទុក្ខត្រូវធ្វើតាមពាក្យប្តឹង នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានចេញសេចក្តីសម្រេច។ ពាក្យប្តឹងនេះត្រូវចុះក្នុងបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ។ ជាលលក្ខខណ្ឌដែលមានចែងនៅមាត្រា៤២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្នុងមាត្រា ៤២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា ជនជាប់ចោទ ពិរុទ្ធជន និងបុគ្គលដែលត្រូវគេទាមទារក្នុងក្របខ័ណ្ឌនីតិវិធីបត្យាប័នអាចតំណាងដោយមេធាវី។ មេធាវីត្រូមានលិខិតប្រគល់សិទ្ធិឱ្យប្តឹងសាទុក្ខ។ ប៉ុន្តែជនជាប់ចោទ ឬពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយឪពុកម្តាយ ឬអ្នកអាណាព្យាបាល។ ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងសាទុក្ខ។

[50] មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[51] មាត្រា ៤២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងទុក្ខ។

បណ្តឹងសាទុក្ខត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹង ឬតំណាង។ កាលណាអ្នកប្តឹងមិនចេះចុះហត្ថលេខាទេ សាមីខ្លួន ឬអ្នកតំណាត្រូវផ្តិតម្រាមដៃ លិខិតប្រគល់សិទ្ធិត្រូវតែភ្ជាប់ជាមួយនឹងពាក្យសុំប្តឹងសាទុក្ខ។

**ឃ.២.កាបញ្ជូនសំណុំរឿងទៅតុលាការកំពូល**

នៅក្នុងរយៈពេលដ៏ខ្លីបំផុត ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ រៀបចំសំណុំរឿង ហើយបញ្ជូនទៅក្រឡាបញ្ជីតុលាការកំពូល។ នៅពេលដែលសំណុំរឿងបានទៅដល់តុលាការកំពូល ក្រឡាបញ្ជីត្រូវចុះបញ្ជី។ ក្រឡាបញ្ជីនឹងចេញលិខិតជូនដំណឹងអំពីការចុះបញ្ជីសំណុំរឿង និងឱ្យដាក់សារណាដល់គូភាគី។ ជាលក្ខខណ្ឌដែលមានចែងនៅមាត្រា៤២៤ មាត្រា៤២៥ និងមាត្រា៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ខ.អានុភាពនៃបណ្តឹងសាទុក្ខ**

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៤៣៥ "នៅក្នុងរយៈពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខនោះ ការអនុវត្តសាលដីការបស់សាលឧទ្ធរណ៍ត្រូវបង្អង់សិន។ បណ្តឹងសាទុក្ខមានអានុភាពព្យួរ ការអនុវត្តសេចក្តីសម្រេចដែលត្រូវតវ៉ានេះ ត្រូវតែបង្អង់ក្នុងខណៈដែលតុលាការកំពូលមិនទាន់បានសម្រេច។ ប៉ុន្តែ ការអនុវត្តដាក់ពន្ធនាគារមិនត្រូវបង្អង់ទេ នៅក្នុងករណីដែលជនជាប់ចោទបានបង្ហាញខ្លួននៅមុខសាលាឧទ្ធរណ៍ក្នុងឋានៈជាជនជាប់ឃុំនោះ។ ដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាព។ ការឃុំខ្លួនបណ្តោះអាសន្ននៅតែបន្តអនុវត្ត។ បុគ្គលជាប់ឃុំនៅក្នុងក្របខ័ណ្ឌនីតិវិធីបត្យាប័ននៅតែជាប់ឃុំដដែល។ ក្នុងករណីមានការសម្រេចឱ្យរួចខ្លួន ជនជាប់ចោទត្រូវបានដោះលែងឱ្យមានសេរីភាព។

សវនាការជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី១ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាជំនុំជម្រះ មានចៅក្រម ៥ រូប (មាត្រា៥៩ ច្បាប់រៀបចំអង្គការតុលាការ) ហើយសម្រេចសេចក្តីតែលើបញ្ហាគតិយុត្តតែប៉ុណ្ណោះ (មាត្រា៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

បណ្តឹងសាទុក្ខនេះក៏អាចធ្វើឱ្យមានការកែប្រែសាលដីកាសាលាឧទ្ធរណ៍ផងដែរ។ ក្នុងករណីដែលសភាព្រហ្មទណ្ឌនៃតុលាការកំពូល សម្រេចបដិសេធសាលដីការបស់សាលឧទ្ធរណ៍ដែលគេតវ៉ានេះចោលទាំងស្រុង ឬមួយផ្នែក[52] តុលាការកំពូលបញ្ជូនរឿងនិងគូភាគីនៅចំពោះមុខសាលាឧទ្ធរណ៍មួយផ្សេងទៀត ឬនៅចំពោះមុខសាលាឧទ្ធរណ៍ដដែលប៉ុន្តែមានសមាសភាពថ្មីផ្សេងពីសមាសភាពមុន។ ការបដិសេធដោយមានការបង្វិលសំណុំរឿង កាលណាតុលាការកំពូលយល់

[52] មាត្រា ៤៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ឃើញថា អំពើដែលចោទប្រកាន់នោះ ជាបទល្មើសផ្សេងអំពីបទល្មើសនៅក្នុងសេចក្តីសម្រេចដែលគេតវ៉ា ប៉ុន្តែ បទល្មើសនេះត្រូវផ្តន្ទាទោសដូចគ្នា តុលាការកំពូលដោយមិនចាំបាច់ប្រកាសបដិសេធ អាចកែប្រែប្រភេទគតិយុត្តនៃអង្គហេតុជាថ្មី ដោយរក្សាទោសដែលបានប្រកាសហើយ និងសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៅដដែល។ កាលណាតុលាការកំពូលយល់ឃើញថា អំពើដែលចោទប្រកាន់នោះ ជាបទល្មើសផ្សេងពីបទល្មើសនៅក្នុងសេចក្តីសម្រេចដែលគេតវ៉ា ហើយបទល្មើសនេះត្រូវផ្តន្ទាទោសផ្សេងនោះ តុលាការកំពូលត្រូវបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងបង្គាប់ឱ្យបញ្ជូនរឿងទៅសាលាជម្រះក្តីមានសមត្ថកិច្ច ដើម្បីជំនុំជម្រះ។

ផ្ទុយទៅវិញសភាព្រហ្មទណ្ឌនៃតុលាការកំពូលអាច អាចសម្រេចបដិសេធបណ្តឹងសាទុក្ខទាំងស្រុង ឬមួយផ្នែក។ នៅពេលដែលតុលាការកំពូលបដិសេធបណ្តឹងសាទុក្ខ សេចក្តីសម្រេច ឬសាលដីការបស់សាលឧទ្ធរណ៍ត្រូវរក្សាទុក (បន្តមានប្រសិទ្ធិ) និងត្រូវតែយកទៅអនុវត្ត។ បានសេចក្តីសេចក្តីថា ប្រសិនបើបណ្តឹងសាទុក្ខត្រូវបានបដិសេធ នោះសេចក្តីសម្រេចដែលតវ៉ាមានអាជ្ញាអស់ជំនុំ។ អ្នកប្តឹងសាទុក្ខមិនត្រូវបានអនុញ្ញាតឱ្យប្តឹងសាទុក្ខជាថ្មីម្តងទៀត អំពីសាលដីកាដដែលនោះបានទេ។

ករណីបណ្តឹងសាទុក្ខលើកទី២ សភាពេញអង្គ (ក្រុមប្រឹក្សាជំនុំជម្រះ ចៅក្រម ៩រូប)ត្រូវបង្កើតឱ្យមានដំណើរការ ដោយដីកាសម្រេចរបស់ប្រធាតុលាការកំពូល ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទីពីរចំពោះសាលដីការបស់សាលាឧទ្ធរណ៍[53]។ តុលាការកំពូលទទួលសំណុំរឿង បង្វិលមិនអនុលោមតាមសាលដីកាទីមួយ របស់តុលាការកំពូលទេ ហើយប្រសិនបើមធ្យោបាយដដែលត្រូវបានលើកយកមកធ្វើជាសំអាងសម្រាប់បណ្តឹងសាទុក្ខលើទីពីរ តុលាការជំនុំជម្រះជាសភាពេញអង្គនោះសម្រេចសេចក្តីលលើអង្គហេតុ និងអង្គច្បាប់ ដោយចេញសាលដីកាស្ថាពរមួយ[54]។

## ផ្នែកទី ២ ៖ បណ្តឹងសើរើរឿងក្តីព្រហ្មទណ្ឌ

ដើម្បីងាយស្រួលដល់ការសិក្សាអំពីការបណ្តឹងសើរើរឿងក្តីព្រហ្មទណ្ឌ យើងខ្ញុំបានធ្វើការសិក្សាទៅលើ សញ្ញាណទូទៅនៃបណ្តឹងសើរើ ក្នុងកថាខណ្ឌទី១ និងគោលការណ៍ទូទៅនៃបណ្តឹងសើរើ ក្នុងកថាខណ្ឌទី២ ដូចខាងក្រោម៖

### កថាខណ្ឌទី ១ ៖ សញ្ញាណទូទៅនៃបណ្តឹងសើរើ

បណ្តឹងសើរើគឺជានីតិវិធីចុងក្រោយសម្រាប់អ្នកដែលបានទទួលការកាត់ទោសថាមានទោសពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមតាមសាលក្រម ឬសាលដីការបស់តុលាការកម្ពុជាដែលបានក្លាយជាស្ថាពរ

[53] មាត្រា ៦២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[54] មាត្រា ៤៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

និងមានអំណាចដាច់ខាតទៅហើយ។ អាចនិយាយបានម្យ៉ាងទៀតថាជនដែលបានកាត់ទោសថាមានទោសអាចបើកសំណុំរឿងឡើងវិញដោយប្រើវិធីមួយផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់របស់កម្ពុជា។ បណ្តឹងសើរើ គឺជាផ្លូវតវ៉ាមួយប្រឆាំងនឹងសាលក្រម និងសាលដីកាដែលស្ថាពរ ហើយដែលមានអាជ្ញាអស់ជំនុំ ព្រោះរយៈពេលកំណត់សម្រាប់ប្តឹងឧទ្ធរណ៍ ឬសារទុក្ខបានបញ្ចប់ ឬក៏សិទ្ធិប្តឹងឧទ្ធរណ៍ ឬសាទុក្ខត្រូវបានប្រើប្រាស់អស់ហើយ "ក្លាយជាស្ថាពរ" ហើយដោយសារសាលក្រម ឬសាលដីកានោះក្លាយទៅជាស្ថាពរ ជាហេតុរាំងមិនឱ្យចាត់វិធានការអ្វីបន្តលើរឿងដដែល "មានអាជ្ញាអស់ជំនុំ"។

**ក-និយមន័យ**

បណ្តឹងសើរើគឺជាបណ្តឹងតវ៉ាមួយដែលប្រឆាំងទៅនឹងសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពររួចហើយ ហើយដែលមានអាជ្ញាអស់ជំនុំមានន័យថាកាត់ក្តីរួច និងបានចូលជាស្ថាពរហើយ សភាពេញអង្គនៃតុលាការកំពូលមានសមត្ថកិច្ចលើបណ្តឹងសើរើនេះ[55]។ បណ្តឹងសើរើអាចត្រូវធ្វើបាននៅក្នុងរឿងព្រហ្មទណ្ឌ ទោះបីតុលាការដែលបានសម្រេចនោះជាតុលាការណាក៏ដោយ និងទោះបីទោសដែលបានប្រកាសនោះជាទោសអ្វីក៏ដោយ។[56] កាលណារយៈពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខបានកន្លងហួសមានន័យថា សាលក្រម ឬ សាលដីកាចូលជាស្ថាពរ និងបង្កើតឱ្យមានអាជ្ញាអស់ជំនុំ។

យោងតាមមាត្រា៤៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "សើរើអាចត្រូវធ្វើបាននៅក្នុងរឿងព្រហ្មទណ្ឌ ទោះបីតុលាការដែលបានសម្រេចនោះជាតុលាការណាក៏ដោយ និងទោះបីទោសដែលបានប្រកាសនោះជាទោសអ្វីក៏ដោយ"។ គោលបំណងតែមួយគត់ក្នុងការធ្វើបណ្តឹងសើរើគឺដើម្បីបញ្ជាក់ពីភាពសុចរិត ស្លូតត្រង់របស់ទណ្ឌិតឡើងវិញ ហើយមានតែតុលាការកំពូលទេ ដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះលើបណ្តឹងសើរើ (មាត្រា៤៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កថាខណ្ឌទី២ សភាពេញអង្គនៃតុលាការកំពូលមានសមត្ថកិច្ចលើបណ្តឹងសើរើ។

**ខ-បុគ្គលដែលអាចប្តឹងសើរើរឿងក្តីជាសិទ្ធិរបស់**

-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

-ទណ្ឌិត ឬ អ្នកតំណាងស្របច្បាប់ប្រសិនបើទណ្ឌិតនេះជាអសមត្ថជន

-សហព័ទ្ធឪពុកម្តាយកូន និងជាទូទៅជនណាដែលមានប្រយោជន៍ខាងសម្ភារៈ ឬខាងផ្លូវចិត្តក្នុងការលុបបំបាត់ ឬខាងផ្លូវចិត្តក្នុងការលុបបំបាត់ទណ្ឌកម្មនេះ ក្នុងករណីដែលទណ្ឌិតបានទទួលមរណភាព ឬបាត់ខ្លួន អាចធ្វើបណ្តឹងទៅសភាពេញអង្គនៃតុលាការកំពូលក្នុងការជំនុំជម្រះបណ្តឹងសើរើនេះ។

---

[55] មាត្រា៤៤៣ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[56] មាត្រា៤៤៤ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មុននឹងទៅប្ដឹងតុលាការកំពូល អាចសុំដល់អគ្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីឱ្យធ្វើការស្រាវជ្រាវបន្ថែម[57]។

**គ-មូលហេតុនៃការប្ដឹងសើរើ**

ជាគោលការណ៍ បណ្ដឹងសើរើអាចធ្វើឡើងបន្ទាប់ពីមានសាលក្រម ឬ សាលដីកា ស្ថាពរណាមួយដែលបានកាត់សេចក្ដីមានលក្ខណៈពុំត្រឹមត្រូវតាមច្បាប់។ ដូច្នេះហើយ ទើបច្បាប់បើកផ្លូវឱ្យភាគីពាក់ព័ន្ធអាចប្ដឹងតវ៉ាចំពោះសាលក្រម ឬ សាលដីកាស្ថាពរទាំងនោះបាន។ ក្នុងរឿងក្ដីព្រហ្មទណ្ឌច្បាប់បានបើកផ្លូវជាច្រើនសម្រាប់ការសុំសើរើ ចំពោះការមិនសុខចិត្តទៅនឹងសេចក្ដីសម្រេចរបស់តុលាការណាមួយ។ បណ្ដឹងសើរើ គឺជាផ្លូវតវ៉ាពិសេសមួយ ដែលបណ្ដឹងសើរើអាចអនុញ្ញាតបានតែក្នុងករណីដែលចែងដោយច្បាប់ប៉ុណ្ណោះ។ អនុលោមតាមមាត្រា៤៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងអំពីករណីបើកការសើរើរឿងក្ដីអាចធ្វើបាន៖

-កាលបើក្រោយពីការផ្ដន្ទាទោសពីបទមនុស្សឃាតមានលេចតម្រុយយ៉ាងគ្រប់គ្រាន់ ដែលអនុញ្ញាតឱ្យគិតថាជនរងគ្រោះនោះនៅរស់រានមានជីវិតនៅឡើយ។

-កាលណាជនជាប់ចោទពីរនាក់ត្រូវបានផ្ដន្ទាទោស ចំពោះបទល្មើសដដែលនោះដោយការផ្ដន្ទាទោសទាំងពីរនេះមិនចុះសម្រុងគ្នាទេ។

-កាលណាសាក្សីណាមួយត្រូវបានផ្ដន្ទាទោសពីបទល្មើស ធ្វើជាសាក្សីដោយក្លែងប្រឆាំងនឹងជនជាប់ចោទ។

-កាលណាមានអង្គហេតុថ្មី ឬលិខិត ឬភស្តុតាងថ្មីដែលនាំឱ្យគេសង្ស័យលើពិរុទ្ធភាពនៃទណ្ឌិត។

**កថាខណ្ឌទី ២ ៖ គោលការណ៍ទូទៅនៃបណ្ដឹងសើរើ**

ពាក្យប្ដឹងសើរើត្រូវចុះក្នុងបញ្ជីដោយក្រឡាបញ្ជីនៃតុលាការកំពូល។ សំណុំរឿងនៃបណ្ដឹងសើរើ អាចពិនិត្យមើលបាននៅការិយាល័យក្រឡាបញ្ជីតុលាការកំពូលដោយអ្នកប្ដឹងសុំសើរើ និងមេធាវីរបស់ខ្លួន ហើយអាចសុំថតសំណុំរឿងនេះបាន។

កាលណាបណ្ដឹងសុំសើរើ ធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សំណុំរឿងអាចពិនិត្យមើលបានដោយទណ្ឌិត និងមេធាវីរបស់ខ្លួន ក្នុងករណីទណ្ឌិតបាត់ខ្លួន សំណុំរឿងអាចត្រូវពិនិត្យមើលបានដោយសហព័ទ្ធឪពុកម្ដាយ ឬកូនរបស់ខ្លួនបាន[58]។

---

[57] មាត្រា៤៤៦ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[58] មាត្រា៤៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

**ក-ការដាក់ពាក្យបណ្តឹងសើរើ**

ពាក្យប្តឹងសុំសើរើត្រូវចុះក្នុងបញ្ជីដោយក្រឡាបញ្ជី នៃតុលាការកំពូល។ សំណុំរឿងនៃបណ្តឹងសើរើ អាចពិនិត្យមើលបាននៅការិយាល័យក្រឡាបញ្ជី នៃតុលាការកំពូលដោយអ្នកប្តឹងសុំសើរើ និងមេធាវីរបស់ខ្លួន (មេធាវីអាចចម្លងសំណុំរឿងនេះបាន)។ កាលណាបណ្តឹងសុំបានធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សំណុំរឿងអាចពិនិត្យមើលបានដោយទណ្ឌិត និងមេធាវីរបស់ខ្លួន។ ក្នុងករណីទណ្ឌិតបាត់ខ្លួន សំណុំរឿងអាចត្រូវពិនិត្យមើលបានដោយសហព័ទ្ធ ឪពុក ម្តាយ ឬ កូនរបស់ខ្លួនបាន[59]។

**ខ-អានុភាពនៃបណ្តឹងសើរើ**

ក្រឡាបញ្ជីផ្តល់ដំណឹងដល់ដើមបណ្តឹងថាខ្លួនមានរយៈពេល ៣០ (សាមសិប) ថ្ងៃ ដើម្បីបំពេញពាក្យប្តឹងរបស់ខ្លួន ជាលក្ខណៈពិសេស ពាក្យបណ្តឹងនេះអាចពន្យារដោយប្រធានតុលាការកំពូល។ ផុតរយៈពេលនេះ ប្រធានតុលាការកំពូលចាត់តាំងចៅក្រមរបាយការណ៍ម្នាក់ដើម្បីធ្វើរបាយការណ៍ បន្ទាប់ពីធ្វើរបាយការណ៍រួចសំណុំរឿងនោះត្រូវបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ។

**គ-ការបញ្ជូនសំណុំរឿងទៅតុលាការកំពូល**

កាលបើសភាព្រហ្មទណ្ឌសម្រេចថា បណ្តឹងសើរើអាចទទួលយកបាននោះ សភាព្រហ្មទណ្ឌត្រូវបញ្ជូនសំណុំរឿងនៃបណ្តឹងសើរើនេះ ទៅតុលាការកំពូល ដើម្បីជំនុំជម្រះជាសភាពេញអង្គ ដោយសម្រេចទៅលើអង្គហេតុ និងអង្គច្បាប់ដោយសាលដីកាស្ថាពរ។[60]

**គ.១.នីតិវិធីក្នុងចំណាត់ការសំណុំរឿង**

សំណុំរឿងត្រូវបញ្ជូនមកកាន់ការិយាល័យរដ្ឋបាលទូទៅ នៃអគ្គលេខាធិការដ្ឋានតុលាការកំពូល បន្ទាប់មកដាក់គម្របនិងចុះលេខសំណុំរឿងទៅតាមប្រភេទនៃរឿងក្តីនីមួយ។

ក្រោយពីចុះលេខសំណុំរឿងរួច ត្រូវបញ្ជូនទៅឯកឧត្តមប្រធានតុលាការកំពូលដើម្បីធ្វើការចាត់តាំងចៅក្រមទៅតាមលេខរៀង ហើយបញ្ជូនទៅកាន់សភាព្រហ្មទណ្ឌនិងធ្វើការបែងចែកឱ្យទៅក្រឡាបញ្ជីនៃចៅក្រមរបាយការណ៍ដើម្បីតាក់តែងរបាយការណ៍ ស្របទៅតាមនីតិវិធីរបស់តុលាការកំពូល។ ក្រឡាបញ្ជីធ្វើការជូនដំណឹងទៅដើមបណ្តឹងថា ខ្លួនមានរយៈពេល៣០ (សាមសិប) ថ្ងៃ ដើម្បីបំពេញពាក្យប្តឹងរបស់ខ្លួន ហើយប្រសិនបើមានបញ្ហា ឬមានការយឺតយ៉ាវណាមួយ ភាគីអ្នកស្នើសុំនោះអាចដាក់ពាក្យសុំពន្យារដោយប្រធានតុលាការកំពូល។ផុតរយៈពេលនេះប្រធានតុលាការកំពូលធ្វើការចាត់តាំងចៅក្រមរបាយការណ៍ម្នាក់ និងបញ្ជូនសំណុំរឿងទៅចៅក្រមនេះ ដោយមានភ្ជាប់សារណាទៅជាមួយ។ កាលណាសំណុំរឿងត្រូវបានបញ្ជូនមកដល់ ចៅក្រមរបាយការណ៍ធ្វើរបាយការណ៍

[59] មាត្រា៤៤៨ ក្រមនីតិវិធីព្រហ្មទណ្ឌ

[60] មាត្រា ៤៥០នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ជាលាយលក្ខណ៍អក្សរ ត្រូវរៀបរាប់អំពី នីតិវិធីនិងរឿងហេតុ មូលហេតុដែលដើមបណ្តឹងសើរើ ទាមទារ អំពីទម្រង់ និងគតិច្បាប់របស់ចៅក្រម បន្ទាប់មកដាក់របាយការណ៍ចូលក្នុងសំណុំរឿង រួច បញ្ជូនទៅកាន់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ[61]។

### គ.២.តួនាទីក្រឡាបញ្ជីក្នុងរឿងក្តីសើរើ

ក្រឡាបញ្ជីត្រូវត្រួតពិនិត្យពាក្យបណ្តឹងសើរើប្រសិនបើខ្វះកាលបរិច្ឆេទ និងហត្ថលេខា ឬ ស្នាមមេដៃរបស់ទណ្ឌិត ឬអ្នកតំណាង ក្រឡាបញ្ជីត្រូវជូនដំណឹងទៅម្ចាស់បណ្តឹងដើម្បីធ្វើការកែ តម្រូវឡើងវិញ។ ក្រឡាបញ្ជីត្រូវបន្តនីតិវិធីឱ្យបានឆាប់រហ័ស ដើម្បីបញ្ជូនទៅចៅក្រមចាត់ការបន្ត ប្រសិនបើមានមេធាវីចង់មកតំណាងដោយអាណត្តិឱ្យទណ្ឌិត ក្រឡាបញ្ជីត្រូវជូន ដំណឹងទៅមេធាវី ដើម្បីមកដាក់ពាក្យការពារ ព្រមទាំងភ្ជាប់មកជាមួយនូវលិខិតផ្ទេរសិទ្ធិ ឬ លិខិតពឹងពាក់មេធាវីដើម្បី ដាក់នៅក្នុងសំណុំរឿងទុកជាឯកសារ។ ក្រឡាបញ្ជីត្រូវចុះហត្ថលេខានៅលើសេចក្តីសុំប្តឹងសើរើ ក្រឡាបញ្ជីមានភារៈកិច្ចកត់ត្រាកំណត់ហេតុ នៅក្នុងដំណាក់កាលសវនាការតុលាការកំពូល។ បន្ទាប់ ពី បញ្ចប់ការពិភាក្សាដេញដោល ក្រឡាបញ្ជីត្រូវតាក់តែងសាលដីកា ឬដីកាសម្រេច ដោយមានចុះ ហត្ថលេខាផងដែរ។

### គ.៣.ការកំណត់កាលបរិច្ឆេទសវនាការ

ប្រសិនបើតុលាការកំពូលយល់ឃើញថា រឿងនោះល្មមជំនុំជម្រះបានតុលាការកំពូលសម្រេច ពីបណ្តឹងសើរើតាមសាលដីកាមួយដែលមិនអាចតវ៉ាបាន។[62]ប្រធានតុលាការកំពូលកំណត់កាល បរិច្ឆេទសវនាការ និងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញា អំពីកាលបរិច្ឆេទនៃសវនាការ នេះ។ អគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់អ្នកប្តឹងសើរើ និងមេធាវី ដូចបាន ចែងនៅមាត្រា៤៣៣ (ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការចំពោះភាគី)។ ប្រសិនបើបណ្តឹង សើរើត្រូវបានធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីកាលបរិច្ឆេទនៃ សវនាការដល់ទណ្ឌិត ឬដល់គ្រួសារ[63]។

### ឃ-ការជំនុំជម្រះនៃសំណុំរឿងសើរើ

កាលបើសភាព្រហ្មទណ្ឌសម្រេចថា បណ្តឹងសើរើអាចទទួលយកបាននោះ សភាត្រូវបញ្ជូន សំណុំរឿងនៃបណ្តឹងសើរើទៅតុលាការកំពូល ដើម្បីជំនុំជម្រះជាសភាពេញអង្គ និងសម្រេចលើអង្គ ហេតុ និងអង្គច្បាប់ដោយសាលដីកាស្ថាពរ។

[61] មាត្រា ៤៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[62] មាត្រា ៤៥២ កថាខណ្ឌទី១នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[63] មាត្រា ៤៥១ កថាខណ្ឌទី១នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

### ឃ.១.ការជូនដំណឹងអំពីកាលបរិច្ឆេទជំនុំជម្រះ

ដើម្បីឱ្យទណ្ឌិត សាក្សី និងមេធាវីការពារក្ដីឱ្យទណ្ឌិតមានភាពងាយស្រួល ក្នុងការចូលខ្លួននីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ របស់តុលាការកំពូល។ ប្រធានតុលាការកំពូលកំណត់កាលបរិច្ឆេទនៃសវនាការ និងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញា ហើយអគ្គព្រះរាជអាជ្ញាឱ្យដំណឹងអំពីកាលបរិច្ឆេទនេះដល់ភាគី និងមេធាវី។ ការឱ្យដំណឹងដល់ជនជាប់ចោទដែលជាប់ឃុំ ដល់ពិរុទ្ធជនដែលឃុំខ្លួន ឬ ដល់បុគ្គលដែលទាមទារ (ដើមបណ្ដឹងសើរើ) ត្រូវធ្វើឡើងតាមរបៀបដូចតទៅៈ

-ដោយផ្ទាល់មាត់ ឬ

-តាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។[64]

### ឃ.២.ការពិភាក្សារដេញដោល

ប្រសិនបើតុលាការកំពូលយល់ឃើញថា រឿងនោះធ្ងន់ធ្ងរល្មមនឹងអាចយកមកជំនុំ ជម្រះបានតុលាការកំពូលសម្រេចពីបណ្ដឹងសើរើតាមសាលដីកាមួយដែលមិនអាចតវ៉ាបានទេ។[65] ក្រោយពីបានពិនិត្យទៅលើសំណុំរឿងរួច ក្រុមប្រឹក្សាជំនុំជម្រះបើកការជំនុំជម្រះ និងពិភាក្សាដេញដោល ប្រព្រឹត្តទៅនៅក្នុងសវនាការជាសាធារណៈ។ តុលាការស្ដាប់សេចក្ដីរាយការណ៍របស់ចៅក្រមរបាយការណ៍ រួចស្ដាប់មេធាវីរបស់ម្ចាស់បណ្ដឹងសើរើ កាលណាបណ្ដឹងសើរើបានធ្វើដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តុលាការស្ដាប់ មេធាវីរបស់ទណ្ឌិត ឬគ្រួសារ។ ប្រសិនបើយល់ឃើញថាមានប្រយោជន៍តុលាការស្ដាប់ ចម្លើយរបស់ទណ្ឌិត។

តុលាការស្ដាប់សេចក្ដីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញា។ មេធាវីរបស់អ្នកប្ដឹងអាចនិយាយម្ដងទៀតបាន[66]។

### ខ-សារប្រយោជន៍នៃបណ្តឹងសើរើ

បណ្ដឹងសើរើទទួលបានប្រយោជន៍ ឱ្យផ្អាកការអនុវត្តទណ្ឌកម្មបានគ្រប់ពេលវេលា ហើយតុលាការកំពូលនឹងសម្រេចតាមសាលដីកាដែលមានសំអាងហេតុ។ ម្យ៉ាងវិញទៀត សភាព្រហ្មទណ្ឌនៃតុលាការកំពូលដែលបានទទួលពាក្យបណ្ដឹងសើរើ អាចសម្រេចព្យួរការអនុវត្តទោសបាន ប្រសិនបើមានមូលហេតុណាមួយច្បាស់លាស់។[67] មានន័យថា កាលណាភស្តុតាងណាមួយដែលត្រូវបានលើកយកមកបង្ហាញ មានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់គូភាគី ហើយស្របទៅតាមការពិនិត្យតាមរយៈអង្គហេតុ និងអង្គច្បាប់ដែលតុលាធ្លាប់ បានពិនិត្យ និងសម្រេចនាពេលកន្លងមក ដូច្នេះការដែលធ្វើនីតិវិធីនៃបណ្ដឹងសើរើនេះ

[64] មាត្រា ៤៣៣ កថាខណ្ឌទី២នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[65] មាត្រា ៤៥២ កថាខណ្ឌទី១នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[66] មាត្រា ៤៥១ កថាខណ្ឌទី២នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[67] មាត្រា ៤៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

មានប្រយោជន៍ទៅដល់ជនជាប់ចោទ ឬទណ្ឌិត ដែលទទួលបានការបង្អង់ការអនុវត្តទោសបាន។ ក្នុងការសម្រេចសេចក្តីផ្អាកការអនុវត្តទណ្ឌកម្មនេះ ក្រោយពីបានទទួលរឿងក្តីប្តឹងសើរើ តុលាការកំពូលជំនុំជម្រះជាសភាពេញអង្គ គឺអាចបង្គាប់ឱ្យផ្អាកការអនុវត្តទណ្ឌកម្មបានគ្រប់ពេលវេលា។[68]

**ច-សិទ្ធិទទួលបានជំនួយផ្នែកច្បាប់**

ក្នុងការទទួលបាន ឬ មិនទទួលបានជំនួយផ្លូវច្បាប់ ជានិច្ចជាកាលកំណត់ថាតើបុគ្គលម្នាក់ អាចទទួលបាននីតិវិធីរឿងក្តីពាក់ព័ន្ធនានា ឬអាចចូលរួមក្នុងនីតិវិធីទាំងនេះ បានប្រកបដោយអត្ថន័យ។ នៅក្នុងនីតិវិធីរឿងក្តីព្រហ្មទណ្ឌ រដ្ឋត្រូវបានលើកទឹកចិត្តឱ្យផ្តល់ជំនួយ ផ្នែកច្បាប់ដោយឥតគិតថ្លៃដល់បុគ្គល ដែលគ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងដំណើរការរឿងក្តីរបស់ ខ្លួនក្នុងនីតិវិធីរបស់តុលាការកំពូល។ ហេតុដូច្នេះហើយ ទើបបានជារដ្ឋមានកាតព្វកិច្ចផ្តល់ជំនួយផ្នែកច្បាប់ ដោយមានកិច្ចធានាក្នុងការដោះស្រាយប្រកបដោយប្រសិទ្ធភាពក្នុងបណ្តឹង សើរើរបស់ខ្លួនស្របទៅតាមបញ្ញត្តិច្បាប់។[69]

[68] មាត្រា ៤៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[69] មាត្រា១៤នៃសេចក្តីពន្យល់ទូទៅកតិកាសញ្ញាអន្តរជាតិនៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ លើការសិក្សាលិខិតតូបករណ៍គតិយុត្ត ជាពិសេសទៅលើសកម្មភាព និងទ្រឹស្តីដែលបានសិក្សាកន្លងមក ដែលមានការទាក់ទងទៅនឹងប្រធានបទ "បណ្តឹងតវ៉ាក្នុងរឿងក្តីព្រហ្មទណ្ឌ" ហើយស្របជាមួយគ្នានេះដែរតាមទិន្នន័យដែលបានមកពីប្រភពឯកសារមួយចំនួន ដែលទទួលបានមកពី បទដ្ឋានគតិយុត្តដែលនៅជាធរមាន ក៏ដូចជាការសាកសួរដោយផ្ទាល់ពីសំណាក់ សាស្ត្រាចារ្យផ្នែកច្បាប់ លោកចៅក្រម ក្រឡាបញ្ជី និងមន្ត្រីនានាដែលបម្រើការនៅក្នុងសាលាដំបូងរាជធានីភ្នំពេញ។ ជាទូទៅយើងឃើញពីការអនុវត្តជាក់ស្តែង នៅពេលមានបណ្តឹងតវ៉ាចំពោះរឿងក្តីព្រហ្មទណ្ឌកើតមានឡើង គឺជាគោលការណ៍ត្រូវគិតអំពីសិទ្ធិ និងប្រយោជន៍របស់អ្នកប្តឹង រួមទាំងពេលវេលាក្នុងការប្តឹងផងដែរ។ ម្យ៉ាងទៀតក៏បានសបញ្ជាក់ឲ្យឃើញអំពីសិទ្ធិ និងករណីយកិច្ចរបស់ភាគីក្នុងរឿងក្តីព្រហ្មទណ្ឌដែលត្រូវគោរព និងអនុវត្តតាមបទប្បញ្ញត្តដែលច្បាប់បានតម្រូវ។

ជាការពិតណាស់ បន្ទាប់ពីបានសិក្សាស្វែងយល់អំពី ប្រធានបទខាងលើរួចមក បានបញ្ជាក់ឲ្យឃើញថា ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌបានកំណត់មកយ៉ាងច្បាស់ និងយកចិត្តទុកដាក់យ៉ាងល្អិតល្អន់ទៅលើការប្តឹងតវ៉ារបស់ភាគីក្នុងរឿងក្តីព្រហ្មទណ្ឌ ក្នុងដំណាក់កាលនីមួយៗចាប់ពីតុលាការជាន់ទាបរហូតដល់តុលាការជាន់ខ្ពស់ ទាក់ទងអំពីសិទ្ធិ ករណីយកិច្ច និងផលប្រយោជន៍របស់ភាគីមិនឲ្យមានការបាត់បង់ និងគិតគូររយៈពេលនៃការប្តឹងក្នុងដំណាក់កាលនៃតុលាការនីមួយៗ។ ម្យ៉ាងទៀតក្នុងនេះក៏បានបង្ហាញពីអ្នកតំណាងសិទ្ធិឲ្យដល់ភាគី ដែលច្បាប់បានទទួលស្គាល់ផងដែរ។ សរុបមក តាមរយៈការសិក្សា និងការស្រាវជ្រាវនូវប្រធានបទស្តីពី "បណ្តឹងតវ៉ាក្នុងរឿងក្តីព្រហ្មទណ្ឌ" ខាងលើបានបង្ហាញពីគោលបំណង និងគោលការណ៍ដែលច្បាប់បានកំណត់ចំពោះរឿងក្តីព្រហ្មទណ្ឌនីមួយៗទៅតាមស្ថានភាព និងប្រភេទនៃបណ្តឹង។ ក៏ដូចជាបានបង្ហាញពីរបៀបក្នុងការប្តឹងតវ៉ា និងប្រឆាំងទៅនឹងសាលក្រម សាលដីកា ឬ សេចក្តីសម្រេច របស់ ចៅក្រមក្នុងដំណាក់កាលនីមួយៗទៅតាមនីតិវិធីនៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលនៅជាធរមាន និងកំពុងតែប្រើប្រាស់សព្វថ្ងៃ។

ម្យ៉ាងវិញទៀត គ្រប់ស្នាដៃទាំងអស់ វាមិនមែនសុទ្ធតែត្រឹមត្រូវបានគ្រប់ជ្រុងជ្រោយនោះឡើយ ហេតុដូចនេះ សូមលោកគ្រូ អ្នកគ្រូ ក៏ដូចជាសាស្ត្រាចារ្យច្បាប់ទាំងអស់មេត្តាចូលរួមកែតម្រូវ និងលើកស្ទួយដើម្បីឲ្យកិច្ចការស្រាវជ្រាវមួយនេះប្រកបដោយភាពល្អប្រសើរ និងទុកជាឯកសារមួយសម្រាប់ធ្វើជាការស្រាវជ្រាវ និងសម្រាប់ឲ្យនិស្សិត ឬ បញ្ញាវន្តដទៃទៀតបានសិក្សា យកជាគំរូ ឬ យក

ជាគំនិតក្នុងការស្រាវជ្រាវ ឬ សម្រាប់ដល់ប្រជាជនខ្មែរដែលពុំចេះច្បាប់ និងអាចមានលទ្ធភាពក្នុងការប្តឹងតវ៉ាក្នុងរឿងក្តីព្រហ្មទណ្ឌបើសិនជាខ្លួនស្ថិតនៅក្នុងស្ថានភាពមួយដែលអយុត្តិធម៌ ឬ សាលក្រម សាលដីកា ឬ សេចក្តីសម្រេចដែលចេញដោយចៅក្រម មានភាពលំអៀង ឬ មិនត្រឹមត្រូវដែលធ្វើឲ្យខ្លួនខាតបង់ប្រយោជន៍ជាដើម។

ដូច្នេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចការស្រាវជ្រាវមួយនេះ និងមានប្រសិទ្ធិភាពក្នុងការស្វែងយល់ចង់ដឹងពីបញ្ហាដែលទាក់ទងទៅនឹងវិស័យតុលាការ និងការប្តឹងតវ៉ាទៅតាមស្ថានភាពនីមួយៗ និងពេលវេលាដែលច្បាប់តម្រូវ។

# អនុសាសន៍

ការផ្តល់អនុសាសន៍ខាងក្រោមនេះ គឺក្នុងន័យមួយគ្រាន់តែជាការចូលរួមចំណែកក្នុងការផ្តល់ជាគំនិតយោបល់មួយ បន្ទាប់ពីបានសិក្សាទ្រឹស្តីអស់រយៈកាលកន្លងមកនៅសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំសង្ឃឹមថា វាជាគំនិតយោបល់មួយដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍នូវវិស័យច្បាប់ខ្មែរឲ្យមានការរីកចម្រើន និងបន្ថែមការយល់ដឹងចំពោះរឿងក្តីដែលឈានទៅដល់ការប្តឹងទៅឧទ្ធរណ៍ និងការដាក់ពាក្យបណ្តឹង ដើម្បីកុំឲ្យខុសឆ្គង និងហួសពេលវេលាដែលច្បាប់បានកំណត់។ ម្យ៉ាងវិញទៀត ក្រសួង គួរតែធ្វើការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌដល់ប្រជាពលរដ្ឋខ្មែរឲ្យបានដឹង និងការដាក់ពាក្យបណ្តឹងឲ្យបានត្រឹមត្រូវ និងស្របជាមួយពេលវេលាដែលច្បាប់បានកំណត់។ ចៀសវាងការភាន់ច្រឡំ និងការយឺតយ៉ាវ ដែលអាចធ្វើឲ្យហួសពេលវេលាក្នុងប្តឹង និងខាតបង់ប្រយោជន៍ដល់ភាគីនៃរឿព្រហ្មទណ្ឌ។

ដើម្បីចូលរួមកែលម្អនូវសកម្មភាពការងាររបស់តុលាការឲ្យមានប្រសិទ្ធិភាព និងពន្លឿនដល់ការបញ្ជូនបណ្តឹងរបស់ភាគីនៃរឿងក្តីព្រហ្មទណ្ឌឲ្យបានទាន់ពេលវេលា ហើយយើងខ្ញុំសូមចូលរួមចំណែកក្នុងការផ្តល់មតិដូចខាងកក្រោម៖

- បង្កើនភាពសហការរវាងតុលាការ និងស្ថាប័នដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីបង្កភាពងាយស្រួលដល់ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាព ជាក់ស្តែងទាក់ទងជាមួយការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ និងការបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ ដែលត្រូវការជាចាំបាច់នូវមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនដូចជា អាជ្ញាសាលា មន្ត្រីប្រៃសនីយ៍ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។
- បង្កើនប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ដែលមានស្រាប់នោះ តាមរយៈការបង្កើតធនធានមនុស្ស ការផ្តល់សម្ភារៈការិយាល័យ សម្ភារៈបច្ចេកទេស កញ្ចប់ថវិការគ្រប់គ្រាន់ និងធ្វើការអប់រំផ្សព្វផ្សយច្បាប់ដល់មន្ត្រីអនុវត្តច្បាប់ និងប្រជាពលរដ្ឋសាមញ្ញ។

## ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ ឆ្នាំ១៩៩៣
- ព្រះរាជក្រម នស/រកម/០៧១៤/០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។
- ព្រះរាជក្រម នស/រកម/០៨០៧/០២៤ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
- ព្រះរាជក្រម នស/រកម/០៦១៣/០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣។
- សៀវភៅមេរៀន នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៥។
- សៀវភៅមេរៀន នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកស្រី ឌី លីឡា និងលោក ខាន់ សុខា។
- វីដេអូកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ដែលពន្យល់ដោយឯកឧត្តមកើត រិទ្ធិ , ឯកឧត្តម ផូវ សំភី ឯកឧត្តម ប៊ុន ហុន ។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

១-ដីកាតម្កល់រឿងទុកឥតចាត់ការ
២- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន
៣-ដីកាបង្គាប់ឲ្យឃុំខ្លួន
៤- ដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន
៥- ពាក្យបណ្តឹងឧទ្ធរណ៍ (ប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្ន)
៦- សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍
៧- សាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍
៨- ពាក្យបណ្តឹងសាទុក្ខ (ប្តឹងសាទុក្ខនឹងសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍)
៩- សេចក្តីសុំប្តឹងសាទុក្ខ
១០- សាលដីកាតុលាការកំពូល
១១- សេចក្តីចម្លងបណ្តឹងទាស់
១២- ពាក្យបណ្តឹងទាស់
១៣- សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍
១៤- ពាក្យបណ្តឹងឧទ្ធរណ៍
១៥- ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន
១៦- ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ
១៧- សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍
១៨- ពាក្យបណ្តឹងឧទ្ធរណ៍
១៩- ដីកាសម្រេចដោះលែងឲ្យនៅក្រៅឃុំ
២០- សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍
២១- សាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍
២២- គំរូសាលក្រមព្រហ្មទណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ: .................... រ.យ.ត/

## ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង ............ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ:១២១៩ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងព័ស្តុតាងនានា។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

- យល់ឃើញថា៖

១. អវត្តមានបទល្មើស

១.១. ☐ អវត្តមានបទល្មើស

២.ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

២.១. ☐ ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត

៣.១. ☐ ការដកពាក្យបណ្តឹង

៣.២. ☐ ការលើកលែងទោសជាទូទៅ

៣.៣. ☐ មរណភាពជនល្មើស

៣.៤. ☐ ផុតអាជ្ញាយុកាល

៣.៥. ☐ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៣.៦. ☐ អាជ្ញាអស់ជំនុំ

៣.៧. ☐ ការសម្របសម្រួលជាមួយរដ្ឋ

៣.៨. ☐ ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល

៣.៩. ☐ អភ័យឯកសិទ្ធិ

៣.១០. ☐ អនិយតភាពនៃនីតិវិធី

៣.១១. ☐ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[១]

៤. ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

៤.១. ☐ ការស្វែងរកមិនបានផល

៤.២. ☐ ការបោះបង់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង[២]

៤.៣. ☐ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយធ្ងន់ការដឹងខុសត្រូវ

៤.៤. ☐ ការខកខានរបស់ដើមបណ្ដឹង

៤.៥. ☐ អាកប្បកិរិយារបស់ជនរងគ្រោះ

៤.៦. ☐ ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

៤.៧. ☐ និយតកម្មដោយឯកឯង[៣]

៤.៨. ☐ ព្យសនកម្ម ឬ ការរំខានតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១. ☐ ការជួសជុលការខូចខាតដោយ/ដល់អនីតិជន

៥.២. ☐ សន្ទានកម្ម[៤]

៥.៣. ☐ អធិបញ្ញាផ្ដល់ការព្យាបាល

៥.៤. ☐ ជនរងគ្រោះ/ដើមបណ្ដឹងបោះបង់ពាក្យបណ្ដឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

៥.៥. ☐ និយតកម្មតាមសំណើរបស់ព្រះរាជអាជ្ញា

៥.៦. ☐ ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[៥]

៥.៧. ☐ ការកំណត់ទិសដៅចំពោះចេតនាសម្ព័ន្ធនៃសុខភាពនៃសង្គម ឬ វិជ្ជាជីវៈ

៥.៨. ☐ ការសម្រុះសម្រួលព្រហ្មទណ្ឌ[៦]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១. ☐ ការចោទប្រកាន់ ឬ ទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

៧.១. ☐ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១. ☐ ការផ្ដល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ការសង្កេតផ្សេងៗ:**

-ឃើញថា: កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ១៧ និង០០ នាទីល្ងាច ឈ្មោះ A កំពុងនៅក្នុងផ្ទះម្ដាយស្ថិតនៅផ្ទះគ្មានលេខ ភូមិព្រែកថ្មី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ស្រាប់តែឈ្មោះ B ភេទប្រុស និងកូនប្រុសស្រីចំនួនពីរនាក់បានមកដល់ផ្ទះម្ដាយរបស់ឈ្មោះ A ហើយស្រែកហៅឱ្យឈ្មោះ A ចេញមកដោះស្រាយរឿងប្រាក់ដែលបានខាតបង់ក្នុងការផ្គត់ផ្គង់សម្ភារដល់ការដ្ឋានសាងសង់ផ្ទះ ដោយស្រែកខ្លាំងៗធ្វើឱ្យអ្នកជិតខាងផ្អើលចេញមកមើល ពេលនោះឈ្មោះ A បានប្រាប់ថារឿងខូចខាតចាំទៅនិយាយជាមួយមេធាវី

ទៅ ហើយក៏ដើរសំដៅទៅរថយន្ត ស្រាប់តែឈ្មោះ B ចាប់ក្របួចករភរិយារបស់ឈ្មោះ A ទាញមិនព្រមឱ្យឡើងរថយន្ត តែត្រូវឈ្មោះ A គៀសដៃចេញហើយឡើងរថយន្តជាមួយប្រពន្ធទៅបាត់។

-បានឃើញ ចម្លើយរបស់មេធាវីតំណាងឱ្យដើមបណ្តឹង ថា ឈ្មោះ B បានប្រព្រឹត្តអំពើដូចការរៀបរាប់របស់កូនក្តីខ្លួនក្នុងពាក្យប្តឹងពិតប្រាកដមែន។

-បានឃើញ ចម្លើយរបស់ជនសង្ស័យឈ្មោះ B ភេទប្រុស ថា ឈ្មោះ A បានយកគ្រឿងសំណង់ពីដេប៉ូខ្លួនហើយនៅខ្វះលុយខ្លួនចំនួន ៣៤០៨៥ ដុល្លារ(បីម៉ឺនបួនពាន់ប៉ែតសិបប្រាំដុល្លារ) មិនព្រមដោះស្រាយចៃដន្យខ្លួនបានជួបគាត់(A)នៅផ្ទះម្តាយរបស់គាត់ ពេលនោះខ្លួនក៏សួរនាំនិងទារប្រាក់ដែលនៅខ្វះ តែឈ្មោះ A មិននិយាយអីជាមួយខ្លួន ហើយក៏ដើរគេចសំដៅទៅរថយន្តរបស់គាត់ ឃើញដូចនោះខ្លួនក៏ទៅពាំងពីមុខកុំឱ្យឈ្មោះ A ចូលរថយន្តដើម្បីនិយាយគ្នាសិន តែត្រូវឈ្មោះ A ចាប់ក្រិចកដៃខ្លួនបណ្តាលឱ្យមានស្នាមផងដែរ។

-បានឃើញ ពាក្យប្តឹងចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ឈ្មោះ **អេន ស៊ីនីន** ថា ឈ្មោះ កាក់ **ឡុង** គ្រាន់តែក្របួចកអាវទាញខ្លួនមិនឱ្យចូលរថយន្តប៉ុណ្ណោះ ពុំបានបង្កឱ្យខ្លួនមានរបួសស្នាមអ្វីនោះទេ ។

-ឯកសារផ្សេងៗទៀតពាក់ព័ន្ធនឹងសំណុំរឿង ។

<u>**យល់ឃើញថា**</u>

-កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០១៨ ឈ្មោះ B ពិតជាបានជួបឈ្មោះ ដោយចៃដន្យនៅផ្ទះគ្មានលេខស្ថិតនៅភូមិព្រែកថ្មី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រាកដមែន ហើយក៏បានទាមទារប្រាក់ដែលឈ្មោះ B នៅជំពាក់ថ្លៃទិញសម្ភារសំណង់ចំនួន ៣៤.០៨៥ ដុល្លារ ប៉ុន្តែខណៈនោះឈ្មោះ អេន ស៊ីនីន ពុំព្រមនិយាយស្តីជាមួយ ហើយបម្រុងឡើងលើរថយន្តដើម្បីគេចពីការទទួលខុសត្រូវ តែត្រូវឈ្មោះ B រារាំង និងចាប់ទាញឈ្មោះ A ដោយមិនបានប្រើហិង្សាអ្វីឡើយ ហើយក៏មិនមានព្យសនកម្មអ្វីកើតឡើងលើឈ្មោះ អេន ស៊ីនីន ដែរ។

-គ្មានធាតុផ្សំ និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោះ B ភេទប្រុស អាយុ ៥៨ឆ្នាំ ពីបទ : ហិង្សាស្រាលកាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨ នៅចំណុចភូមិផ្ទះគ្មានលេខ ភូមិព្រែកថ្មី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ បទល្មើសដែលមានបញ្ញត្តិតាមមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ។

-ដូច្នេះគប្បីតម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ១២១៩ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ទុកឥតចាត់ការតាមមាត្រា ៤០ និងមាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>**ហេតុដូច្នេះសម្រេច**</u>

-តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ១២១៩ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ទុកឥតចាត់ការ។

ថ្ងៃ....................ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី............ ខែ ឧសភា ឆ្នាំ២០១៨

**ជ.ព្រះរាជអាជ្ញា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣

សាលាដំបូងក្រុងភ្នំពេញ

*****

មន្ទីរស៊ើបសួរ

សំណុំរឿងលេខ : ១៨៨

ចុះថ្ងៃទី : ២៥-០១-២០០៩

លេខស៊ើបសួរ : ១២៨

ចុះថ្ងៃទី : ២៧-០១-២០០៩

លេខ : ...262.........ត ព្រ

# ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន

( មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ )

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងក្រុងភ្នំពេញ អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ : ១៨៣ អយក ចុះថ្ងៃទី២៧ ខែ មករា ឆ្នាំ២០០៩

បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនិងឈ្មោះ : ស្រី ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ សញ្ជាតិអាមេរិក ទីកន្លែងកំណើតស្រុកអូរជ្រៅ ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃ នៅសហរដ្ឋអាមេរិក មុខរបរលក់ដូរ ឪពុកឈ្មោះ ម្តាយឈ្មោះ ។ ប្តីឈ្មោះ មានកូន០២នាក់ ជានីតិជន ទោសពីមុន គ្មាន ។

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ពីបទ : **រំលោភលើសេចក្តីទុកចិត្ត** ។

តាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ១៨៣ អយក ចុះថ្ងៃទី២៧ខែ មករា ឆ្នាំ ២០០៩ ។

បានឃើញមាត្រា ២០៣ , មាត្រា ២០៤ , មាត្រា ២០៥ និងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ជននេះត្រូវបានចោទប្រកាន់ពីបទ

-យល់ឃើញថា ការពិភាក្សាដេញដោលចំពោះមុខត្រូវបានធ្វើឡើងតាមនីតិវិធីរួចរាល់ហើយ

-យល់ឃើញថា កាតព្វកិច្ចទាំងឡាយនៃការត្រួតពិនិត្យ តាមផ្លូវតុលាការមានលក្ខណៈមិនគ្រប់គ្រាន់ដោយធៀប និង គោលដៅដែលមានចែងនៅក្នុងមាត្រា ២០៣, ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-យល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ គឺជាមធ្យោបាយតែមួយគត់ដើម្បី :

-រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

-រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ

-រារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

-ការពារជនត្រូវចោទ

-បង្ការបទល្មើសកុំឱ្យកើតជាថ្មី

-ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

-បញ្ឈប់បទល្មើស

-ធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពី បទល្មើសដោយយោងតាម ហេតុផលខាងលើនេះ

## សម្រេច

ឃុំខ្លួនជនត្រូវចោទឈ្មោះ ជាបណ្តោះអាសន្ន ហើយយើងនិងបង្គាប់ឱ្យឃុំខ្លួន ជននេះ តាមអំណាចដីកាបង្គាប់ឱ្យឃុំខ្លួន ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩

**បានទទួលដំណឹងរួចហើយ** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

-បានជូនដំណឹងដល់ជនត្រូវចោទ **ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងក្រុងភ្នំពេញ**
*****
មន្ទីរស៊ើបសួរ
**សំណុំរឿងលេខ : ១៨៨**
**ចុះថ្ងៃទី : ២៥-០១-២០០៩**
**លេខស៊ើបសួរ : ១២៨**
**ចុះថ្ងៃទី : ២៧-០១-២០០៩**
លេខ : ......២១៤..........ត ព្រ

# ដីកាបង្គាប់ឱ្យឃុំខ្លួន

( មាត្រា ២១៩ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ )

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងក្រុងភ្នំពេញ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៤៣ អយគ ចុះថ្ងៃទី ២៧-០១-២០០៩ ។

បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនិង :

ឈ្មោះ ភេទស្រី អាយុ ៥២ ឆ្នាំ ជាតិ ខ្មែរ សញ្ជាតិអាមេរិក ទីកន្លែងកំណើតស្រុកអូរជ្រៅ ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃ នៅសហរដ្ឋអាមេរិក មុខរបរលក់ដូរ ឪពុកឈ្មោះ ម្តាយឈ្មោះ ប្តីឈ្មោះ មានកូន០២នាក់ ជានីតិជន ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

ចាប់ខ្លួនពីថ្ងៃ ២៣-០១-២០០៩ ។

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ពីបទ :រំលោភលើសេចក្តីទុកចិត្ត តាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៤៣ អយគ ចុះថ្ងៃទី ២៧-០១-២០០៩ ។

បានឃើញមាត្រា ២០៣ ,មាត្រា ២០៤ , មាត្រា ២០៥ និងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បានឃើញដីកាសម្រេច ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ.[illegible].ចុះថ្ងៃទី២៧ ខែ មករា ឆ្នាំ ២០០៩

## សម្រេច

បញ្ជាឱ្យភ្នាក់ងារមានសមត្ថកិច្ចនៃកំលាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទដែល មានឈ្មោះ ភេទស្រី អាយុ ៥២ ឆ្នាំ ទៅពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ( ម២ ) ដោយអនុវត្តឱ្យបានត្រឹមត្រូវ តាមនីតិវិធីនៃច្បាប់ ។

បង្គាប់ឱ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ( ម២ ) ទទួលជននេះ និងឃុំជននេះ រហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។

បង្គាប់ឱ្យគ្រប់ភ្នាក់ងារនៃកម្លាំងសាធារណៈ ទាំងអស់នៅពេលត្រូវបានបង្ហាញដីកានេះ សហការអនុវត្តឱ្យបានល្អ នៅក្នុងករណីចាំបាច់ ។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៩

**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងក្រុងភ្នំពេញ

លេខ : 205...

# ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងក្រុងភ្នំពេញ

-បានឃើញច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ ។

-បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស រកម ០៧០៨ ០២៤ ចុះថ្ងៃទី ១០-០៨-២០០៧ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ១៨៨ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៩ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ១៤៣ អយគ ចុះថ្ងៃទី ២៧-០១-២០០៩ របស់តំណាងអយ្យការអមសាលាដំបូងក្រុងភ្នំពេញ ។

-បានឃើញពាក្យសុំនៅក្រៅឃុំបណ្ដោះអាសន្នរបស់ជនជាប់ចោទឈ្មោះ ចុះថ្ងៃទី ៣០-០១-២០០៩ ។

-ក្រោយពីបានពិនិត្យសំណុំរឿងចប់ ។

## យល់ឃើញថា :

-បទល្មើសជាបទមជ្ឈិម ការស៊ើបអង្កេតទើបចាប់ផ្តើមបារម្ភពីការរត់គេចខ្លួនរបស់ជនជាប់ចោទ ។

-ជនជាប់ចោទពុំមានទីលំនៅក្នុងប្រទេសកម្ពុជា ។

-គប្បីមិនអនុញ្ញាតឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ។

## ហេតុដូច្នេះសំរេច :

១-បដិសេធពាក្យសុំរបស់ជនជាប់ចោទឈ្មោះ ចុះថ្ងៃទី ៣០-០១-២០០៩ ចោលជាអសារបង់ ។

២-បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ ភេទស្រី អាយុ៥២ឆ្នាំ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២១៤ ត.ព្រ ចុះថ្ងៃទី ២៨-០១-២០០៩ របស់សាលាដំបូងក្រុងភ្នំពេញបន្តទៀត ។

-បើកផ្លូវប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

ភ្នំពេញ ថ្ងៃទី០៦ ខែ កុម្ភៈ ឆ្នាំ២០០៩

**ចៅក្រមស៊ើបសួរ**

TIMBRE FISCAL ៥០០ រៀល

TIMBRE FISCAL ១០០ រៀល

ក្រឡាការក្រុងភ្នំពេញ
ទទួល
លេខ 62
ថ្ងៃទី 16 ខែ 02 ឆ្នាំ 2009
ម៉ោង 4h15

2/01

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្តឹងឧទ្ធរណ៍

ខ្ញុំបាទ                    **ជាមេធាវីនៃក្រុមមេធាវី ទណ្ណា និង សហការ** អត្តលេខ ៤៩៤ ការិយាល័យផ្ទះលេខ ២១៨ ផ្លូវ ១៩ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ ក្រុងភ្នំពេញ ជាមេធាវីការពារក្តី អោយឈ្មោះ                ។

**សូមគោរពជូន**

**ឯកឧត្តមប្រធាន សាលាដំបូងក្រុងភ្នំពេញ**

**សូមធានាជ្រាបខ**

**កម្មវត្ថុ** : សុំប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចមិនអនុញ្ញាតអោយនៅក្រៅឃុំបណ្តោះអាសន្នលេខ ២០៥៧ ត.ព្រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូក្រុងភ្នំពេញ ។

**យោង** : -សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៨ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៩ របស់សាលាដំបូងក្រុភ្នំពេញ ។

-ដីកាសម្រេចមិនអនុញ្ញាតអោយនៅក្រៅឃុំបណ្តោះអាសន្នលេខ ២០៥៧ ត.ព្រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូក្រុងភ្នំពេញ។

-ពាក្យពឹងពាក់មេធាវី ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៩ របស់ឈ្មោះ                ។

-ដីកាទទួស្គាល់មេធាវីលេខ ១៤៧០ តព្រ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៩ របស់ក្រៅក្រមស៊ើបសួរ ។

-មាត្រា ២១៧ , ២៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជំរាបជូន **ឯកឧត្តម** មេត្តាជ្រាបថា : ដោយសារការចេញដីកាសម្រេចមិនអនុញ្ញាតអោយនៅក្រៅឃុំបណ្តោះអាសន្នលេខ ២០៥៧ ត.ព្រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់ចៅក្រមស៊ើបសួរ កូនក្តីខ្ញុំបាទមិនអាចទទួយកបានឡើយ ព្រោះមិនអនុញ្ញាតអោយកូនក្តីខ្ញុំបាទនៅក្រៅឃុំបណ្តោះអាសន្នពុំសមហេតុផល ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាបញ្ជូនសំណុំរឿងដូចបានចុះក្នុងកម្មវត្ថុខាងលើទៅសាលាឧទ្ធរណ៍តាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

**ហត្ថលេខា និង ត្រា**

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.

(7)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងក្រុងភ្នំពេញ

លេខ: ...62...

ចុះថ្ងៃទី16..ខែ02..ឆ្នាំ២០០៩

សំណុំរឿង ព្រហ្មទណ្ឌ

លេខ: ...188...

ចុះថ្ងៃទី.25.ខែ01..ឆ្នាំ២០០៦

# សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍

********

ឆ្នាំពីរពាន់ប្រាំបួន ខែ..កុម្ភៈ..ថ្ងៃទី..ដប់ប្រាំមួយ..វេលាម៉ោង..បួន..ដប់ប្រាំនាទី

យើង ធន់ វណ្ណធឿន ក្រឡាបញ្ជី នៃសាលាដំបូងក្រុងភ្នំពេញ ។

បានទទួល/ឃើញឈ្មោះ... [illegible] ...

..............................................................................

..............................................................................

ចូលមកចំពោះមុខយើង នៅការិយាល័យក្រឡាបញ្ជីនៃសាលាដំបូងក្រុងភ្នំពេញ ។
ហើយសុំប្តឹងឧទ្ធរណ៍នឹង [illegible] ...លេខ..2057..[illegible]
ចុះថ្ងៃទី..06..ខែ..កុម្ភៈ..ឆ្នាំ..2009..ត្រង់ចំណុច [illegible]
[illegible]

ក្រែងពុំប្រាកដ យើងបានសូត្រសេចក្តីនេះឱ្យឈ្មោះ ... ...............
..............................................ស្តាប់ ហើយឱ្យចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង ។

**អ្នកប្តឹង**
ស្នាមមេដៃ ~~ឬ ហត្ថលេខា~~
[illegible]

**ក្រឡាបញ្ជី**
ហត្ថលេខា

បានឃើញ
ភ្នំពេញ ថ្ងៃទី ..16.. ខែ ..កុម្ភៈ.. ឆ្នាំ ២០០៩
ប្រធានសាលាដំបូង

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ..16.. ខែ ..កុម្ភៈ.. ឆ្នាំ ២០០៩
ក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

សមាសស៊ើបសួរ
សំណុំរឿងព្រហ្មទណ្ឌ
លេខ:៣៩/២៣-០២-២០០៩
សាលដីកា
លេខ:០៨(ឈ)/០៦-០៣-២០០៩

## សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជារសាធារណៈ នៅថ្ងៃទី០៦-០៣-២០០៩ ដោយមានសមាសភាពដូចខាងក្រោមនេះ :

**ក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម ជាប្រធាន

ឯកឧត្តម ចៅក្រមប្រឹក្សា

លោក ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក

**ក្រឡាបញ្ជីសវនាការ**

លោក

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ:៣៩ ចុះថ្ងៃទី២៣-០២-២០០៩ :

-ជនជាប់ចោទឈ្មោះ ៖ ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ទីលំនៅសព្វថ្ងៃសហរដ្ឋអាមេរិក ឪពុកឈ្មោះ ម្តាយឈ្មោះ ប្តីឈ្មោះ មានកូន ២នាក់ ទោសពីមុនគ្មាន ។

ចាប់ខ្លួនថ្ងៃទី២៨-០១-២០០៩ ឃុំខ្លួនថ្ងៃទី២៨-០១-២០០៩

មេធាវីការពារលោក ៖

ជាប់ចោទពីបទ: រំលោភលើសេចក្តីទុកចិត្ត ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ២E$_0$ ផ្លូវ១៧២ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ៖ ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិកំពង់ក្របី ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

## ឯរឿងហេតុមានដូចតទៅៈ

កាលពីឆ្នាំ១៩៩៧ រហូតដល់ឆ្នាំ២០០៤ ឈ្មោះ ភេទស្រី អាយុ៥២ឆ្នាំ មានទីលំនៅសហរដ្ឋអាមេរិក បានរកស៊ីជាមួយឈ្មោះ និង ឈ្មោះ មានទីលំនៅប្រទេសកម្ពុជា ពុំដែលមានបញ្ហាអ្វីឡើយ ក្នុងការរកស៊ីផ្ទេរកន្លងមក ។ លុះដល់ឆ្នាំ២០០៥-២០០៦ ឈ្មោះ ពុំបានផ្ទេរប្រាក់សរុបចំនួនប្រហែលម្ភៃពីរម៉ឺន មកឱ្យឈ្មោះ និងឈ្មោះ ឡើយ ។ លុះដល់ថ្ងៃទី១៨-០១-២០០៩ បានមកកម្ពុជា ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង ។

-បានឃើញដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ២១៤ ចុះថ្ងៃទី២៨-០១-២០០៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងក្រុងភ្នំពេញ ។

-បានឃើញដីកាសម្រេច ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខៈ២៦២ តព្រ ចុះថ្ងៃទី២៨-០១-២០០៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងក្រុងភ្នំពេញ ។

-បានឃើញដីកាសម្រេចមិនអនុញ្ញាតិ ឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខៈ២០៥៧ តព្រ ចុះថ្ងៃទី០៦-០២-២០០៩ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-បដិសេធពាក្យសុំរបស់ជនជាប់ចោទឈ្មោះ ចុះថ្ងៃទី៣០-០១-២០០៩ ចោលជាអសារបង់ ។

២-បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ ភេទស្រី អាយុ៥២ឆ្នាំ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ២១៤ តព្រ ចុះថ្ងៃទី២៨-០១-២០០៩ របស់សាលាដំបូងក្រុងភ្នំពេញ បន្តទៀត ។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី២៤-០២-២០០៩ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ (អវត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ (អវត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ (អវត្តមាន)

-មេធាវីលោក ការពារឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានៈ កូនក្តីខ្លួនមានជាតិដើមខ្មែរ សញ្ជាតិអាមេរិក ហើយមានផ្ទះនៅទឹកថ្លា កូនក្តីខ្លួនរកស៊ីផ្ទេរលុយពីអាមេរិកមកស្រុកខ្មែរ ហើយក៏ត្រូវគេយអាមេរិកចាប់រឿងរកស៊ីលុយ ។ ចំពោះរឿងពាក់ព័ន្ធនឹង វិញ គឺកូនក្តីខ្លួនបានបង់ប្រាក់ចំនួន ៤០០០០ដុល្លាអាមេរិក ឱ្យឈ្មោះ វិញហើយ ដោយឈ្មោះនេះបានទទួលស្គាល់ទៀតផង ។ យោងតាមច្បាប់ចាស់ គឺហួសអាជ្ញាយុកាលនៃបទល្មើស ហើយនេះជាបទល្មើសនៅសហរដ្ឋអាមេរិក មិនមែន

បទល្មើសនៅស្រុកខ្មែរឡើយ ចំពោះកំណត់ហេតុឃាត់ខ្លួនកូនក្តីខ្លួនវិញ គឺគ្មានដីកាពីតុលាការឡើយ គឺឃាត់ដោយលិខិតរបស់លោក តែប៉ុណ្ណោះ ។

សំណូមពរ សុំឱ្យកូនក្តីខ្លួននៅក្រៅឃុំបណ្តោះអាសន្នសិន ដើម្បីរកភស្តុតាងកខុសត្រូវ អំពីបញ្ហាបទល្មើសនេះ ។

## តំណាងមហាអយ្យការសន្និដ្ឋានថាៈ

តម្កល់ដីកាសំរេចមិនអនុញ្ញាតិ ឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខៈ២០៥៧ តព្រ ចុះថ្ងៃទី០៦-០២-២០០៩ ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មហាអយ្យការ

-ក្រោយពីបានពិនិត្យពិចារណា និង ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សភាស៊ើបសួរ

## យល់ឃើញថា

-យល់ឃើញថាៈ បណ្តឹងឧទ្ធរណ៍លេខៈ៦២ ចុះថ្ងៃទី១៦-០២-២០០៩ របស់លោកមេធាវី ការពារឱ្យឈ្មោះ ប្តឹងមិនសុខចិត្តនឹងដីកាសំរេចមិនអនុញ្ញាតិ ឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខៈ២០៥៧ តព្រ ចុះថ្ងៃទី០៦-០២-២០០៩ ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះមកជំនុំជម្រះបាន ។

-យល់ឃើញថាៈ រឿងនេះជារឿងមជ្ឈឹមក៏ពិតមែន តែនៅមានលក្ខណៈស្មុគ្រស្មាញ មានព្យសនកម្មមានទំហំធំ ហើយជនត្រូវចោទមានលំនៅ៧សហរដ្ឋអាមេរិក បើតុលាការឱ្យនៅក្រៅឃុំ ធ្វើឱ្យមានការលំបាកដល់ការស៊ើបអង្កេត ។

-យល់ឃើញថាៈ រឿងក្តីនេះចៅក្រមស៊ើបសួរសាលាដំបូងក្រុងភ្នំពេញ កំពុងចាត់ការស៊ើបសួរតាមនីតិវិធីនៅឡើយ ។

-យល់ឃើញថាៈ ដីកាសំរេចមិនអនុញ្ញាតិ ឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខៈ២០៥៧ តព្រ ចុះថ្ងៃទី០៦-០២-២០០៩ មានលក្ខណៈត្រឹមត្រូវតាមទំរង់នឹងគតិច្បាប់ហើយ គប្បីសាលាឧទ្ធរណ៍ តម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ សភាស៊ើបសួរ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខៈ៦២ ចុះថ្ងៃទី១៦-០២-២០០៩ របស់លោកមេធាវី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់ដីកាសំរេចមិនអនុញ្ញាតិ ឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខ:២០៥៧ ឥព្រ ចុះថ្ងៃទី០៦-០២-២០០៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះប្រកាសជាអសាធារណ: នៅថ្ងៃទី០៦-០៣-២០០៩ បើកផ្លូវសាទុក្ខ ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា ៖ |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី 06 ខែមីនា ឆ្នាំ២០០៩

បានឃើញ

ប្រធានក្រុមប្រឹក្សា

ក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

11 MAR 2009

492 34

## ពាក្យបណ្តឹងសាទុក្ខ

ខ្ញុំបាទ   **ជាមេធាវីនៃក្រុមមេធាវី ចណ្ណា និង សហការ** អត្តលេខ ៤៩៤ ការិយាល័យផ្ទះលេខ ២១៨ ផ្លូវ ១៩ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ ក្រុងភ្នំពេញ ជាមេធាវីការពារក្តី អោយឈ្មោះ   ។

### សូមគោរពចូលមក

### ឯកឧត្តមប្រធាន សាលាឧទ្ធរណ៍

<u>**សូមធានជ្រាបថា**</u>

**<u>កម្មវត្ថុ</u>** : សុំប្តឹងសាទុក្ខ និងសាលដីកាលេខ [illegible] ចុះថ្ងៃទី 6.3.2009 របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ [illegible]

**<u>យោង</u>** : -សំណុំរឿងព្រហ្មទណ្ឌលេខ ៣៩ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់សាលាឧទ្ធរណ៍ ។

-សាលដីកាលេខ [illegible] ចុះថ្ងៃទី 6.3.09 របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ។

-ពាក្យពឹងពាក់មេធាវី ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៩ របស់ឈ្មោះ   ។

-ដីកាទទួលស្គាល់មេធាវីលេខ ១៤៧០ គព្រ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៩ របស់ចៅក្រមស៊ើបសួរ ។

-មាត្រា ២១៧ , ២៤៥ , ៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជំរាបជូន **ឯកឧត្តម** មេត្តាជ្រាបថា : ដោយសារការមិនអនុញ្ញាតអោយកូនក្តីខ្ញុំបាទ នៅក្រៅឃុំបណ្តោះអាសន្ន ដោយពុំសមហេតុផល ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាបញ្ជូនសំណុំរឿងដូចបានចុះក្នុងកម្មវត្ថុខាងលើទៅតុលាការកំពូល តាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៩

**ហត្ថលេខា និង ត្រា**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*******

សាលាខណ្ឌទួលគោកភ្នំពេញ

លេខៈ...[illegible]... ចុះថ្ងៃទី...១១.........

ខែ...[illegible]... ឆ្នាំ...២០០៧.......

រឿង...[illegible].........

លេខៈ...[illegible]... ចុះថ្ងៃទី...[illegible].....

ខែ...[illegible]... ឆ្នាំ...២០០៧.......

# សេចក្តីសុំប្តឹងសាទុក្ខ

ឆ្នាំពីរពាន់...[illegible]... ខែ...[illegible]... ថ្ងៃទី...[illegible]... វេលាម៉ោង...[illegible]...

យើង ........................ក្រឡាបញ្ជីសាលាខណ្ឌទួលគោកភ្នំពេញ ។

បានឃើញឈ្មោះ...[illegible]...

ចូលមកចំពោះមុខយើងនៅសាលាខណ្ឌទួលគោកភ្នំពេញ ។ ហើយសុំប្តឹងសាទុក្ខនឹងសាលដីកាលេខ...[illegible]...

ចុះថ្ងៃទី...[illegible]... ខែ...[illegible]... ឆ្នាំ២០០...[illegible]... ត្រង់ចំណុច...[illegible]...

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

ក្រែងពុំប្រាកដ យើងបានសូត្រសេចក្តីនេះអោយឈ្មោះ.......................................

ស្តាប់ ហើយអោយចុះហត្ថលេខា រឺ ផ្តិតមេដៃជាមួយយើង ។

អ្នកប្តឹង

ស្នាមមេដៃស្តាំ

ក្រឡាបញ្ជីសាលាខណ្ឌទួលគោកភ្នំពេញ

ហត្ថលេខា

.......................................................................................................

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

បានចំលងចេញត្រឹមត្រូវតាមច្បាប់ដើម ។

សាលាខណ្ឌទួលគោក ថ្ងៃទី...[illegible]... ខែ...[illegible]... ឆ្នាំ២០០...[illegible]...

ក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ **តាងនាមប្រជារាស្ត្រខ្មែរ**

លេខ : ៦០ **តុលាការកំពូល**

ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩

<u>សាលដីកា</u> បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៩

លេខ : ៤៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៩

១- ឯកឧត្តម ប្រធាន

២- លោក ចៅក្រម

៣- លោក ចៅក្រម

៤- លោក ចៅក្រមរបាយការណ៍

៥- លោក ចៅក្រម

ក្រឡាបញ្ជី

លោកស្រី ថូ ណារី

តំណាងមហាអយ្យការ

លោក ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ០៨"ឈ" ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៦០ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ របស់តុលាការកំពូល ។

-ជនជាប់ចោទឈ្មោះ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ កើតនៅ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ទីលំនៅសហរដ្ឋអាមេរិក ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ " ប្តីឈ្មោះ មានកូន២នាក់ ទោសពីមុនគ្មាន ។ ចាប់ខ្លួនថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ ឃុំខ្លួនថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ ។

មានមេធាវីលោក

**<u>ត្រូវជាប់ចោទពីបទ</u> :** រំលោភលើសេចក្តីទុកចិត្ត ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហេង សុវណ្ណារិទ្ធិ "ជាចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ២E0 ផ្លូវលេខ១៧២ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ "ជាចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅ ភូមិកំពង់ក្របី ស្រុកស្វាយចេក ខេត្តបាត់ដំបង ។

-កាលពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ២០០៤ ឈ្មោះ ភេទស្រី អាយុ៥២ឆ្នាំ មានទីលំនៅ អចិន្ត្រៃយ៍បច្ចុប្បន្ននៅសហរដ្ឋអាមេរិក បានរកស៊ីជាមួយឈ្មោះ និងឈ្មោះ មានទីលំនៅប្រទេសកម្ពុជា ពុំដែលមានបញ្ហាអ្វីឡើយ ក្នុងការរកស៊ីផ្ញើរប្រាក់គន្លងមក ។ លុះដល់ឆ្នាំ២០០៥-២០០៦ ឈ្មោះ ពុំបានផ្ញើរប្រាក់សរុបចំនួនប្រហែលម្ភៃពីរម៉ឺន មកអោយឈ្មោះ និងឈ្មោះ ឡើយ ដោយសារតែសហរដ្ឋអាមេរិកបានចាប់យកអស់ ហើយបានផ្តន្ទាទោសដាក់ពន្ធនាគារអស់រយៈពេល០៦ខែ នៅសហរដ្ឋអាមេរិក តាមលិខិតលេខ.....................។ លុះដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៩ ឈ្មោះ បានមកកម្ពុជា ត្រូវបានសមត្ថកិច្ចចាប់ខ្លួនតែម្តង ។

-បានឃើញដីការសំរេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខ២០៥៧ត.ព្រ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងក្រុងភ្នំពេញ ដែលបានសំរេច :

១-បដិសេធពាក្យសុំរបស់ជនជាប់ចោទឈ្មោះ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ចោលជាអសារបង់ ។

២-បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ ភេទស្រី អាយុ៥២ឆ្នាំ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ២១៤ ត.ព្រ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ របស់សាលាដំបូងក្រុងភ្នំពេញ បន្តទៀត ។

-បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ របស់លោកមេធាវីការពារឱ្យឈ្មោះ ប្តឹងមិនសុខចិត្តនឹងដីការសំរេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខ២០៥៧ត.ព្រ ចុះថ្ងៃទី០៦ខែកុម្ភៈឆ្នាំ២០០៩របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា : តំកល់ដីកាសំរេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខ២០៥៧ តព្រ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ទុកជាបានការដដែល ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៨"ឈ" ចុះថ្ងៃទី០៦ ខែមីនាឆ្នាំ២០០៩របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៦២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ របស់លោកមេធាវី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់ដីកាសំរេចមិនអនុញ្ញាតិ អោយនៅក្រៅឃុំបណ្តោះអាសន្នលេខ២០៥៧ ត.ព្រ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះប្រកាសជាអសាធារណៈ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៧១ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ របស់លោក មេធាវីការពារឱ្យឈ្មោះ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០៨"ឈ" ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩ របស់ឈ្មោះ 'ជាម្ចាស់បណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ របស់ឈ្មោះ និងឈ្មោះ "ជាចុងបណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : ពុំមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ពីបទ : រំលោភលើសេចក្តីទុកចិត្តឡើយ ។

អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសំរេច ។

-បានស្តាប់ក្រឡាបញ្ជីអានសារណាការពារ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩ របស់ឈ្មោះ ជុំ ម៉ាលីស នាពេលជំនុំជំរះ ។

-បានស្តាប់ចំលើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ នាពេលជំនុំជំរះ ថា : ខ្ញុំបាទរកស៊ីជាមួយគាត់ផ្ទេរប្រាក់ពីសហរដ្ឋអាមេរិក មកស្រុកខ្មែរក្នុងអំឡុងឆ្នាំ២០០០ រហូតមក ដែលមានឈ្មោះ នេះគឺជាអ្នកទទួលយកប្រាក់ និងប្រមូលប្រាក់ពីអតិថិជនអ្នកនៅសហរដ្ឋអាមេរិក រួចហើយ Fax រាយឈ្មោះចំនួនលុយមកស្រុកខ្មែរ ។ ដែលខ្ញុំបាទ និងប្រពន្ធជាអ្នកទទួលចែកចាយប្រាក់នៅស្រុកខ្មែរ និងជាអ្នកចុះបញ្ជី ។ ម្យ៉ាងទៀតគាត់ឱ្យមូលប្បទានប័ត្រដែលមានចុះហត្ថលេខាដោយឈ្មោះ បានប្រគល់ឱ្យខ្ញុំបាទទាំង២នាក់ ប្តីប្រពន្ធនៅស្រុកខ្មែរ ហើយថានឹងបញ្ចូលលុយមកតាមក្រោយ ពេលគាត់ទៅដល់សហរដ្ឋអាមេរិក ។ តាមពិតមូលប្បទានប័ត្រនេះមិនមានប្រាក់មួយសេនឡើយ នេះជាភស្តុតាងមួយដែលជនល្មើសបានប្រព្រឹត្តបទល្មើស ឆបោកមកលើ រូបខ្ញុំទាំងពីរនាក់ប្តីប្រពន្ធ ពិតប្រាកដមែន ។

សំណូមពរ : សូមឯកឧត្តមប្រធាន មេត្តាជួយរកយុត្តិធម៌ដល់ខ្ញុំបាទ ដែលជាជនរងគ្រោះផង ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ការពារឱ្យជនជាប់ចោទ នាពេលជំនុំជំរះ ថា : នៅឆ្នាំ១៩៩៧ ដល់ ២០០៥ ភាគី បានរកស៊ីជាមួយកូនក្តីរបស់ខ្ញុំបាទ រហូតដល់ឆ្នាំ២០០៥ កូនក្តីរបស់ខ្ញុំជាប់ពន្ធនាគារនៅសហរដ្ឋអាមេរិក ។ ខ្ញុំបាទសូមលើកយកអង្គហេតុមានចំណុចដូចជា :

+ការដាក់ពាក្យបណ្តឹងវាហួសអាជ្ញាយុកាលនៃបណ្តឹង ។

+នៅព្រលានយន្តហោះ ប៉ូលីសបានឃាត់កូនក្តីរបស់ខ្ញុំដោយគ្មានដីកាទេ ។

+ក្រឡាបញ្ជីធ្វើកំណត់នៅឆ្នាំ២០០៩ តែលោកក្រឡាបញ្ជីចូលធ្វើការមេធាវីនៅឆ្នាំ២០០៨ វាខុសពីការស៊ើបអង្កេតទាំងអស់ សូមតុលាការពិចារណា ។ កូនក្តីរបស់ខ្ញុំមានសេរីភាពវិញហើយ ត្រឡប់ទៅប្រទេសអាមេរិកហើយ ។

សំណូមពរ : មេត្តាតំកល់ស៊ាំងមុនអង្គសេចក្តីលេខ០១"ខ" ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៩ ទុកជាបានការ ។ និងបដិសេធសាលដីកាសាលាឧទ្ធរណ៍លេខ០៨"ឈ" ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ ចោលជាអសារបង់ ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : គ្មានយោបល់បន្ថែមទៀតទេ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់អ្នកស្រី ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋាន របស់មេធាវីជនត្រូវចោទ .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា : បណ្តឹងសាទុក្ខលេខ៧១ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ របស់ឈ្មោះ ជាមេធាវី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍ ក៏ដូចសាលាដំបូងក្រុងភ្នំពេញដែរ សំរេចមិនអនុញ្ញាតិអោយជនត្រូវចោទនៅក្រៅឃុំជាបណ្តោះអាសន្ននោះ ជាការមិនត្រឹមត្រូវទេ ពីព្រោះថា បទចោទជាបទមជ្ឈិម ហើយក៏ពុំទាន់មានភស្តុតាងចូនល្មម និងច្បាស់លាស់ថា ឈ្មោះ ប្រព្រឹត្តដូចបទចោទនៅឡើយទេ ដែលការឃុំខ្លួនជនត្រូវចោទអាចប៉ះពាល់ដល់សិទ្ធិបុគ្គលរបស់ជនត្រូវចោទ ។

-យល់ឃើញថា : ជនត្រូវចោទបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា : សាលដីកាព្រហ្មទណ្ឌលេខ០៨"ឈ" ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនត្រូវចោទ**

**ប៉ុន្តែចាត់ទុកជាចំពោះមុខ :**

១-ទទួលបណ្តឹងសាទុក្ខលេខ៧១ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ របស់លោកមេធាវី ម៉ក់ ប៊ុណ្ណា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ០៨"ឈ" ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-អនុញ្ញាតអោយឈ្មោះ ភេទស្រី អាយុ៥២ឆ្នាំ នៅក្រៅឃុំ ជាបណ្តោះអាសន្ន បើសិនឈ្មោះនេះមិនត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

៤-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៦០ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងសំណុំរឿងនៃអង្គសេចក្តី ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៥ ។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|

---

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០០៥

ក្រឡាបញ្ជី

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០០៥

ជ.ប្រធានតុលាការកំពូល

អនុប្រធាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស.៥២

ម្បូងរាជធានីភ្នំពេញ

# សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍

ខែសីហា ឆ្នាំ២០១៧
ព្រហ្មទណ្ឌ
២៥
ា ខែវិច្ឆិកា ឆ្នាំ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំពីរខែសីហាថ្ងៃទីប្រាំបួន វេលាម៉ោងប្រាំបួននិងសែសិបបួននាទី។

យើង ជាក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញលោក ជាមេធាវីការពារឱ្យឈ្មោះ ភេទស្រី អាយុ៦០ឆ្នាំ ។

ចូលមកចំពោះមុខយើងនៅការិយាល័យក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ ហើយសុំប្តឹង **ទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ: ១២៨៧ "ច១" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧** គ្រង់ចំណុច: នៃសេចក្តីសម្រេចទាំងមូល។

| **អ្នកប្តឹង** | **ក្រឡាបញ្ជី** |
|---|---|
| ផ្តិតមេដៃ | ហត្ថលេខា |

---

| **បានឃើញ** | |
|---|---|
| ភ្នំពេញ,ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ | **បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម** |
| **ជ.ប្រធានសាលាដំបូង** | ភ្នំពេញ,ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ |
| **អនុប្រធាន** | **ក្រឡាបញ្ជី** |

10.8.2017

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ការិយាល័យមេធាវី ខេ អិន ស៊ី**
*K N.C LAW OFFICE*

## ពាក្យបណ្ដឹងទាស់

ខ្ញុំមេធាវី , ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខៈ ៦៦៨ ជាអ្នកតំណាងដោយអាណត្តិអោយឈ្មោះ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៨៦២៥ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**សូមគោរពជូន**
**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** :ប្ដឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ១២៩៧ (ប១) ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំនុចទាំងមូលនៃសេចក្ដីសម្រេច ។

**យោង** :-ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
-ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី
-លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ០៣ ខែ០៨ ឆ្នាំ២០១៧ របស់ឈ្មោះ ង៉ែត មុំ ។
-សាលក្រមព្រហ្មទណ្ឌលេខ ១២៩៧ (ប១) ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**មូលហេតុ** : ការសម្រេចរបស់តុលាការបានធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់កូនក្ដីខ្ញុំយ៉ាងធ្ងន់ធ្ងរដោយមិនបានពិចារណាទៅលើភស្តុតាងនិងកំណត់ហេតុរបស់ចៅក្រមស៊ើបសួរនោះឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** ទទួលនូវពាក្យបណ្ដឹងទាស់របស់ខ្ញុំ និងចាត់វិធានការតាមនីតិវិធីច្បាប់ ដោយអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧
**មេធាវីតំណាងដោយអាណត្តិ**

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**ជូនភ្ជាប់មកជាមួយនូវៈ**
-លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ (ច្បាប់ដើម) ។

មេធាវី

ផ្ទះលេខ ១១៣E០ ផ្លូវលេខ ១៣៨ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ: ០១៧ ៣៣៨ ០៣៣ , ០១២ ៣៧៩ ៦៣៣ , ០៨៩ ២២១ ៥៦៧
... Tel: 017 338 033, 012 379 633, 089 221 567

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស.៥៣

ដំបូងរាជធានីភ្នំពេញ

## សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍

ក
ខែមីនា ឆ្នាំ២០១៨
ព្រហ្មទណ្ឌ
១៥
ខែវិច្ឆិកា ឆ្នាំ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំបី ខែមីនា ថ្ងៃទីម្ភៃបី វេលាម៉ោងដប់និងម្ភៃប្រាំពីរនាទី។

យើង ជាក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញឈ្មោះ **យ៉ង់ ធី** ភេទប្រុស អាយុ៥០ឆ្នាំ នឹងឈ្មោះ **វ៉េត មុំ** ភេទស្រី អាយុ៥៩ឆ្នាំ ចូលមកចំពោះមុខយើងនៅការិយាល័យក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ ហើយសុំប្ដឹង**ឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ៨០៧ "ច១"** ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ **ត្រង់ចំណុចៈ នៃសេចក្ដីសម្រេចទាំងមូល។**

ក្រឡាបញ្ជី

ហត្ថលេខា

---

បានឃើញ

ថ្ងៃសុក្រ ០៨កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ភ្នំពេញ,ថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០១៨

ជ.ប្រធានសាលាដំបូង

អនុប្រធាន

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ០៨កើត ខែចេត្រ ឆ្នាំរកាន ព្វស័ក ព.ស ២៥៦១

ភ្នំពេញ,ថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០១៨

ក្រឡាបញ្ជី

៦០៣
៦៣-០៣-...៨
១០ ៦៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

<u>ពាក្យបណ្តឹងឧទ្ធរណ៍</u>

ខ្ញុំឈ្មោះ កេទប្រុស អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ និប្រពន្ធឈ្មោះ អាយុ ៥៩ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ៩៥៥ ផ្លូវ២៧B ភូមិស្លែងលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាភាគីដើមបណ្តឹងសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦២៥ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

<u>សូមគោរពជូន</u>

លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ

<u>**កម្មវត្ថុ**</u> : សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨០៧ ច(១) ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំនុចទាំងមូលនៃសេចក្តីសម្រេចរបស់សាលក្រម ។

<u>**យោង**</u> : -ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៦២៥ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

-សាលក្រមព្រហ្មទណ្ឌលេខ ៨០៧ ច(១) ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

<u>**មូលហេតុ**</u> : ការសម្រេចរបស់លោកចៅក្រមទទួលបន្ទុកមិនបានពិចារណាឱ្យល្អិតល្អន់លើភស្តុតាងនោះទេ គឺធ្វើឡើងដោយផ្ទុយនឹងគតិច្បាប់ទាំងស្រុងធ្វើអោយប៉ះពាល់ដល់ ផលប្រយោជន៍របស់យើងខ្ញុំយ៉ាងធ្ងន់ធ្ងរបំផុត ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** ទទួលយកនូវពាក្យបណ្តឹងឧទ្ធរណ៍របស់យើងខ្ញុំតាមកំណត់ច្បាប់តាមការគួរ ។

សូម **លោកប្រធាន** ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៨

**ស្នាមមេដៃស្តាំ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ស"

លេខ ....30៦.......ដ.ព.ស

# ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញ មាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៩៧៣៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៧៨៧ អ.យ.ឃ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ ៣៨៩៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨។

បានឃើញ កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩។

ក្រោយពីបានសួរចម្លើយជនត្រូវចោទចប់សព្វគ្រប់ និងពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ៖

## ហេតុដូច្នេះសម្រេច

-មិនឃុំខ្លួនឈ្មោះ ភេទ ប្រុស អាយុ ៥៧ ឆ្នាំ ជនជាតិ ខ្មែរ ទីកន្លែងកំណើតនៅភូមិភ្នំ ឃុំលើកដែក ខេត្តកណ្ដាល អាសយដ្ឋាននៅផ្ទះលេខH71 ផ្លូវលេខ១៤ ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ មានកូន ៣ នាក់ ឪពុកឈ្មោះ ម្ដាយឈ្មោះ ទោសពីមុន គ្មាន។

ដែលបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន តាមបញ្ញត្តិមាត្រា២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ និងនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧។

**បានទទួលដំណឹង**

ថ្ងៃព្រហស្បតិ៍ ១២កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩

